# ស្នាព្រះហស្ថ

## ក្រោយបន្ទស់

នៃ

សម្តេចព្រះមហាសុមេធាធិបតី

# ជួន ណាត

ជោតញ្ញាណោ

ព្រះសង្ឃរាជថ្នាក់ទី ១

គណៈមហានិកាយ

ព.ស ២៥១៣ - គ.ស ១៩៧០

# ស្នាព្រះហស្ថ

## ក្រោយបង្អស់

នៃ

សម្តេចព្រះមហាសុមេធាធិបតី

# ជួន ណាត

## ជោតញ្ញាណោ

ព្រះសង្ឃរាជថ្នាក់ទី ១

**គណៈមហានិកាយ**

ព.ស ២៥១៣ - គ.ស ១៩៧០

ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ ទ៉ាត តិរក្ស

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១.  ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប

២.  ប្រស្នា គិហិប្រតិបត្តិពិស្តារ ( សុង ស៊ីវ ,ឈឹម ទូច )

៣ .  ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )

៤ .  អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )

៥ .  ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ,ប៊ុត សាវង្ស )ភិក្ខុ សាន សុជា (

៦ .  ជីវិតកថា ម៉ិញ )សាវ៉ាន ( ថ្មី

៧ .  ធម្មប្រទីប ) ប្រជុំកងធម៌ យិន វន់ (

៨ .  រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )

៩.  រឿង នគរកាយ ( ចាប ពិន )

១០. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )

១១. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )

១២. ត្រៃកូដធម៌ ( សុង ស៊ីវ )

១៣. ឱវាទបាតិមោក្ខ ( ចាប ពិន )

១៤. កម្រងកំណាព្យ ថ្មី ( ហ៊ិម ឆាន់ )

១៥. ឧបនីយតិសូត្រ ( ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ )

១៦. ធម្មទេស ៤ យ៉ាង ( ម៉ិញ សាវ៉ាន ) ថ្មី

១៧. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmer-Français ( វ៉ាត ភិរក្ស )ថ្មី



# មាតិការឿង


១. ព្រះបរមឆាយាលក្ខណ៍សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ ..................... ទំព័រ

២. ព្រះរាជបណ្តាំនៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ............................. ០០

៣. អារម្ភកថារបស់សហជិវិន នង លន់ អ្នកទទួលព្រះរាជបណ្តាំ..................................... ០០

៤. ឧទ្ទិសកថា........................................................................................................ ០០

៥. អត្ថបទព្រះរាជនិពន្ធនៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ.................... ១៣

៦. ព្រះរាជជីវប្បវត្តិសង្ខេបនៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ................. ៨៧

៧. គុណសោកកថារបស់សហជីវិន ព្រិន្ទបាលឯក **ជា ម៉ូរ**........................................ ៩៩

៨. សមាសភាពចូលរួម............................................................................................ ១០១

៩. ឧទ្ទិសកថានៃអ្នកមានសទ្ធាចេញថ្លៃបោះពុម្ពចែកជាធម្មទាន.................................... ១០២







**ព.ស ២៤២៧ - ២៥១៣**

## រូបំជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

*" រីរូបនៃសព្វសត្វ　　　តែងវិបត្តិចាស់ជរា*
*ឯនាមនិងគោត្តា　　　ឥតជរាដូចរូបឡើយ ។*
*សូន្យបាត់តែរូបទៅ　　　កេរ្តិ៍ឈ្មោះនៅជិតបង្កើយ*
*បើគេមិនតោះតើយ　　　គេអាចស្គាល់យូរអង្វែង។ "*

# ពាក្យប្រារព្ធ

មូលហេតុដែលឲ្យខ្ញុំព្រះករុណា, ខ្ញុំបាទសរសេរចម្លងសៀវភៅនេះឡើងវិញ, គឺខ្ញុំព្រះករុណា, ខ្ញុំបាទយល់ឃើញថា " **ស្នាព្រះហស្តក្រោយបង្អស់ នៃសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ** " របស់ព្រះអង្គស្ទើរតែរលប់បាត់អស់ និងពិបាកអានផង ។ ខ្ញុំព្រះករុណា, ខ្ញុំបាទមិនមែនជាអ្នកចេះដឹង ដែលអាចតែងឬអធិប្បាយ វែកញែក សរសេរ ពន្យល់អ្វីផងនោះទេ គ្រាន់តែជា " **កូនខ្មែរ** " មួយរូបដែលមានការស្រឡាញ់ ពេញចិត្តចំពោះប្រពៃណី វប្បធម៌ អក្សរសាស្ត្រជាតិ ជឿជ្រះថ្លាក្នុងព្រះពុទ្ធសាសនា និងនឹកឃើញជានិច្ចចំពោះគុណូបការៈនៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ ដែលព្រះអង្គបានព្យាយាមត្រួសត្រាយនិពន្ធ ចងក្រង ជាក្បួនច្បាប់ ទុកសំរាប់ទូន្មានប្រៀនប្រដៅ អប់រំ ដល់កូនចៅជំនាន់ក្រោយឲ្យមាន សតិ ប្រាជ្ញា ស្មារតី ភ្លឺស្វាង ដើម្បីកសាងខ្លួនឲ្យបានឋិតនៅក្នុង " **គុណធម៌** " ។

ដូចនេះ ទូលបង្គំយើងខ្ញុំជា កូនចៅជំនាន់ក្រោយ សូមលំអោនកាយប្រណមទូលថ្វាយដល់សម្តេចជាអម្ចាស់សូមទ្រង់ព្រះបរមរាជានុញ្ញាត ដើម្បីចម្លងបោះផ្សាយឡើងវិញ នូវសៀវភៅ " **ស្នាព្រះហស្តក្រោយបង្អស់ នៃសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ** " នេះ ។

ក្នុងការចម្លងឡើងវិញនេះ ខ្ញុំព្រះករុណា, ខ្ញុំបាទបានផ្លាស់អត្ថបទព្រះរាជនិពន្ធ យកមកដាក់តាម លេខរៀង ថ្ងៃ ខែ ដែលព្រះអង្គបានសរសេរ ហើយពាក្យកាព្យវិញ ខ្ញុំព្រះករុណា, ខ្ញុំបាទ ក៏បានរៀបសរសេរ តាមលំនាំរបស់ពាក្យកាព្យនៃ " **ច្បាប់ផ្សេងៗ** " ដែរដើម្បីឲ្យងាយស្រួលដល់ការអាន ។

ទន្ទឹមនេះដែរ ខ្ញុំព្រះករុណា, ខ្ញុំសូមទានមេត្តាខន្តីអភ័យទោសរាល់កំហុសឆ្គងដោយ អក្ខរាវិរុទ្ធ ពាក្យធម៌ បាលី ដែលភ្លាំងភ្លាត់ ដោយប្រការណា សូមទានព្រះករុណាម្ចាស់ព្រម ទាំងលោក-អ្នកអាន ទាំងឡាយមេត្តាអនុគ្រោះ ហើយជួយជួសជុល កែតម្រូវឲ្យបានល្អត្រឹមត្រូវផង ដើម្បីជាកិច្ចអនុគ្រោះចំពោះព្រះពុទ្ធសាសនា ។

ចម្លងចប់នៅក្រុងម៉ុងរេអាល, ថ្ងៃ ៣ ១៥ ៤ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៥៥២
ត្រូវនឹងថ្ងៃអង្គារ ទី ១០ ខែ មីនា គ.ស. ២០០៩

**អ្នកសរសេរចម្លង**
**វ៉ាត តិរក្ស**

ក្រសួងព្រះសង្ឃរាជ
គណៈមហានិកាយ

វត្តឧណ្ណាលោម

ស្មៀន នង លន់,

អាត្មាបានឆ្លៀតរៀបរៀងអត្ថបទខ្លីៗនេះ បើអស់លោកគណៈកម្មាធិការមិនយល់ទាស់ទេ ត្រូវចុះក្នុងទស្សនាវដ្ដីពន្លឺពុទ្ធចក្រភាគណាខ្លះៗ តាមការលៃលកចុះ ។ ប៉ុន្តែត្រូវផ្ញើវិញ្ញាសាពុម្ពទៅឲ្យអាត្មាពិនិត្យខ្លួន ព្រោះក្រែងនឹងមានខុសប្ដូរខ្លះ ។

ឯតួអក្សរ បើត្រូវការយកតួណាៗ របស់លោក ហង្ស វី ចុះក៏ស្រួលណាស់ ។

២០-៧-៦៨

អក្សរសង្ខេបដែលចុះ៖

*ប.អ.ស. គឺបណ្ឌិតអក្សរសាស្ត្រ

*អ.ម.រ. គឺអភិធជមហារដ្ឋគុរុ

ចុះសម្រាប់ជាសញ្ញាទៅក្នុងអនាគត, ពុំមែនសម្រាប់បង្អួតគេក្នុងបច្ចុប្បន្ននេះទេ ។

បើមានឱកាស នឹងចេះតែរៀបរៀងតៗទៅទៀត ឲ្យខ្លីៗបែបនេះ ។

ក្រសួងព្រះសង្ឃរាជ

គណៈមហានិកាយ

# បណ្ដាំ

វត្តឧណ្ណាលោម

ស្មៀន នង លន់,

អត្ថបទទាំងអស់ដែលអាត្មាបានឆ្លៀតរៀបរៀង ផ្ញើមកឲ្យសម្រាប់ចុះក្នុងទស្សនាវដ្ដីពន្លឺពុទ្ធចក្រនោះ បើចុះក្នុង ១ សៀវភៅតែត្រឹម ១ អត្ថបទឃើញថា យូរឆ្នាំទើប អស់, ឃើញ ថាបើចុះក្នុង ១ សៀវភៅ ៣ អត្ថបទបន្តគ្នា ឬចុះ ២ អត្ថបទ ប៉ុន្តែឲ្យ ឆ្ងាយពីគ្នានោះ ឃើញថាឥតបើមានទាស់ឆ្គងអ្វីទេ ពីព្រោះអត្ថបទខ្លីៗ។ គួរពីគ្រោះនឹង អស់លោកគណៈកម្មាធិការមើល, តើអស់លោកនឹងមានយោបល់យ៉ាងណា?

អត្ថបទទាំងអស់នោះ, បើអំណើះឥតពីអាត្មាទៅ, ត្រូវប្រមូលរួបរួមបោះជា សៀវភៅ ១ ក្បាលឲ្យមានឆាយាលក្ខណ៍នៃអាត្មាផង ចែកក្នុងឱកាសបុណ្យឈាបនកិច្ចសពអាត្មា ដើម្បីទុកជាកេរ្តិ៍វែងឆ្ងាយទៅក្នុងអនាគតកាល ( សូមឲ្យរួបរួមបោះ ពុម្ពកុំខាន! ) ។

រូបំជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

"រីរូបនៃសព្វសត្វ តែងវិបត្តិចាស់ជរា ឯនាមនិងគោត្តា ឥតជរាដូចរូបឡើយ ។ សូន្យបាត់តែរូបទៅ កេរ្តិ៍ឈ្មោះនៅជិតបង្កើយ បើគេមិនតោះតើយ គេអាចស្គាល់យូរអង្វែង ។"

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃចន្ទ្រទី ២៩ ខែកក្កដា ១៩៦៨ ព.ស.២៥១២

សម្ដេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ

ហ.អ.ស - អ.ម.រ

ទូលបង្គំជាខ្ញុំ សូមទទួលព្រះរាជឱង្ការតម្កល់លើត្បូង
ដោយសេចក្ដីគោរពដ៏ជ្រាលជ្រៅ ហើយនឹងចាត់ការ
ថ្វាយល្អងធូលីព្រះបាទតាមរាជបណ្ដាំនេះ ។

នង លន់

# អារម្ភកថា

សម្ដេចព្រះមហាសុមេធាធិបតីព្រះបរមនាម **ជួន ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជគណៈមហានិកាយ សូម្បីព្រះអង្គមានវ័យជរាទៅហើយ នៅតែមានព្រះមហាវិរិយភាពដ៏ខ្ជាប់ខ្ជួនក្នុងការបម្រើជាតិ ពិសេសក្នុងផ្នែកអក្សរសាស្ត្រជាតិ ឥតនឿយណាយព្រះកាយពលសោះ ។ សម្ដេចទ្រង់ឆ្លៀតពេលដ៏មានតម្លៃរបស់ព្រះអង្គដកស្រង់ពុទ្ធភាសិត និងបុរាណភាសិត ពន្យល់ជាពាក្យរាយ និងពាក្យកាព្យ ទុកឲ្យបច្ឆាជនសិក្សាងាយយល់ងាយចាំ ហើយទ្រង់ប្រោសព្រះរាជទានមកខ្ញុំឲ្យចុះផ្សាយក្នុងទស្សនាវដ្ដីពន្លឺពុទ្ធចក្ររបស់ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ ដែលមានព្រះអង្គសម្ដេចបានបង្កបង្កើតឡើងតាមសេចក្ដីសម្រេចរបស់សន្និសីទអន្តរជាតិនៅក្រុងកោលម្បូ ( លង្កាទ្វីប ) ។

នៅថ្ងៃចន្ទ្រទី ២៩ កក្កដា ព.ស. ២៥១២ គ.ស. ១៩៦៨ ខ្ញុំបានទទួលនូវព្រះចំណារផ្ទាល់ព្រះហស្តជាព្រះបណ្ដាំថា " ...បើអំណឹះតតពីអាត្មាទៅ, ត្រូវប្រមូលរួបរួមបោះជាសៀវភៅ ១ ក្បាល ឲ្យមានឆាយាលក្ខណ៍ផង ចែកក្នុងឱកាសបុណ្យឈាបនកិច្ចសពអាត្មា ដើម្បីទុកជាកេរ្តិ៍វែងឆ្ងាយក្នុងអនាគតកាល ( សុំឲ្យរួបរួមបោះពុម្ពកុំខាន ! )... " ។

លុះមកដល់ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី, សម្ដេចទ្រង់សោយព្រះទិវង្គត នៅព្រះដំណាក់វត្តឧណ្ណាលោម ដោយស្ងប់ស្ងៀម ធ្វើឲ្យខ្ញុំមានសេចក្ដីនឹកអាឡោះអាល័យ សោកស្ដាយយ៉ាងក្រៀមក្រំជាទីបំផុត។

បពិត្រសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ទូលព្រះបង្គំជាខ្ញុំសូមទទួលព្រះរាជឱង្ការតម្កល់លើត្បូង ហើយនឹងចាត់ការបោះពុម្ពគោរពដ៏ជ្រាលជ្រៅតាមព្រះរាជបំណងនៃល្អងធូលីព្រះបាទ ។ ទូលបង្គំជាខ្ញុំសូមព្រះបរមរាជានុញ្ញាត ឲ្យនាមសៀវភៅនេះថា " **ស្នាព្រះហស្តក្រោយបង្អស់នៃសម្ដេច ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជគណៈមហានិកាយ** " ។

ដោយអំណាចផលានិសង្សនៃធម្មទាន ជាមហាកុសលវិសេសវិសាលនេះ សូមព្រះវិបាកវិញ្ញាណនៃសម្ដេចជាអម្ចាស់ បានទៅសម្កាតក្នុងសុគតិសួគ៌ទេវលោកកុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញ, ថ្ងៃទី ៣ មករា ព.ស. ២៥១៣ គ.ស. ១៩៧០

**ខេង លន់**

# ឧទ្ទិសកថា

យើងខ្ញុំព្រះករុណា, យើងខ្ញុំ សូមលើកយកផលានិសង្សដែលកើតឡើងពីធម្មទាននេះ ឧទ្ទិសជូនចំពោះ និងប្រគេនចែកជូន ដល់លោកអ្នកដ៏មានគុណទាំងឡាយមាន ជីដូន ជីតា មាតា បិតា គ្រូឧបជ្ឈាយាចារ្យ ញាតិកា លោកអ្នកប្រាជ្ញ កវី ជាបុព្វការីជនទាំងអស់ សូមលោកទាំងនោះ បានទៅកើតក្នុងសុគតិភព ប្រកបដោយសេចក្ដីសុខចម្រើន ជានិច្ចនិរន្តរ៍ ។



# គារវបុគ្គល ១០ ចំពូក

**ពុទ្ធោ បច្ចេកពុទ្ធោ ច　　អរហា អគ្គសាវកោ**
**មាតា បិតា គរុ សត្ថា　　ទាយកោ ធម្មទេសកោ**
**បណ្ឌិតេហិ ឥមេ ទស　　ន ទុព្ភន្តីតិ ជានិយា ។**

## ពាក្យកាព្យឲ្យស្មើនឹងគាថា
## បទព្រហ្មគីតិ

*ព្រះពុទ្ធព្រះបច្ចេក　　និងឯកអគ្គារហា*
*អគ្គសាវកា　　និងមាតាបិតាផង ។*
*គ្រូនិងសាស្ត្រាចារ្យ　　និងទាយកឥតមោះហ្មង*
*និងអ្នកទេស្នាផង　　កុំយង់ឃ្នងឆ្គងប្រមាថ ។*
*បុគ្គលទាំងដប់នេះ　　ប្រាជ្ញគួរិះរេសំអាត*
*ត្រូវកុំបីប្រមាថ　　គួរឱហាតឲ្យចងចាំ ។*
*ថាមិនត្រូវប្រទូស្ត　　ឬរឹងរូសធ្វើឲ្យឆ្គាំ*
*ឆ្គងខុសក្រែងនឹងនាំ　　ឲ្យបានទុក្ខឃើញទាន់ភ្នែក។*
*ខ្ញុំតែងពាក្យកាព្យនេះ　　ដោយរិះរេមិនរារែក*
*មិនតែងចេញឲ្យប្លែក　　ពីគាថាបាលីឡើយ ។*
*អ្នកណាបានគោរព　　បុគ្គលដប់ពុំតោះតើយ*
*តាមបែបខាងលើហើយ　　អ្នកនោះរែងជួបក្តីសុខ ។*
*មានរឿងតំណាលថា　　ពួកទេព្តានិរទុក្ខ*
*ព្រះឥន្ទ្រជាប្រមុខ　　តែងសំពះទិសទាំងដប់ ។*

គឺទិសទាំងប្រាំបី ទិសក្រោមលើដោយសព្វគ្រប់
លើកអម្រាមទាំងដប់ ប្រណមឆ្ពោះជននានា ។
ដែលគេបានប្រព្រឹត្ត សុចរិតឥតសង្កា
ទោះនៅត្រង់ទីណា ក៏ដោយចុះឥតរើសមុខ ។
ថាសូមឲ្យជននោះ បានរវាតឃ្លាតចាកទុក្ខ
តាំងពីនេះទៅមុខ សូមបានសុខអាយុវែង ។
ព្រោះហេតុនោះបានជា ព្រះសាស្តាបានសំដែង
ថាជនទាំងនោះឯង ទោះទេព្តាក៏រាប់អាន ។
ទេព្តាទាំងតូចធំ តែងបង្គំមករាល់ប្រាណ
ឆ្ពោះជនទាំងប៉ុន្មាន ដែលបានកាន់សីលនិងធម៌។
ហេតុនេះសាធុជន កុំទំរន់គួរត្រេកអរ
ឆ្ពោះធម៌ដ៏បវរ ដែលព្រះពុទ្ធទ្រង់សរសើរ ។៚

**វត្តខុណ្ឌាលោម ក្រុងភ្នំពេញ, ថ្ងៃសុក្រ ទី១៩ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណា ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# យសាភិវឌ្ឍកជន

## " ជនអ្នកចម្រុងចម្រើនដោយយស "

**ឧដ្ឋានវតោ សតី មតោ**
**សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវនោ**
**អប្បមត្តស្ស យសោភិវឌ្ឍតិ ។**

*យសតែងចម្រើនដល់ជន ៖*

១. *អ្នកមានព្យាយាមរឹងប៉ឹងម៉ឺងម៉ាត់ ;*

២. *អ្នកមានស្មារតីខ្ជាប់ខ្ជួនមិនភ្លេចភ្លាត់ ;*

៣. *អ្នកមានការងារស្អាត ហ្មត់ហ្មង ;*

៤. *អ្នករិះរេពិចារណាត្រាតែយល់ ឲ្យបានសព្វគ្រប់សិនហើយទើបធ្វើអ្វីៗ ;*

៥. *អ្នកសង្រួមឥន្ទ្រិយស្រគត់ស្រគំសមរម្យមិនឆ្គង ;*

៦. *អ្នកចិញ្ចឹមជីវិតត្រឹមត្រូវតាមគន្លងធម៌ ;*

៧. *អ្នកមិនប្រមាទគឺប្រុងប្រយ័ត្នស្មារតីជានិច្ច មិនលុះលង់ក្នុងការធ្វេសប្រហែស, (ដោយបរិយាយថា " អ្នកមានសតិ - សម្បជញ្ញៈ ជានិច្ច ") ;*

## អត្ថន័យពាក្យថា យស

**១. ឥស្សរិយៈ** *គឺភាវៈជាធំឬមានបុណ្យស័ក្តិ ;*

**២. ភោគទ្រព្យ** *គឺមានទ្រព្យធនច្រើន ;*

**៣. សម្មានៈ** *គឺមានអ្នកដទៃរាប់អានច្រើន ;*

៤. កិត្តិ មានកេរ្តិ៍ឈ្មោះល្អ គេស្ងើចសរសើរច្រើន ;
ទាំង ៤ នេះហៅថា យស ។ ៦ ឥស្សរិយយស គឺ យសនៃអ្នកមានបុណ្យស័ក្តិ ។
គ្រឿងឥស្សរិយយស គឺវត្ថុប្រាស់ជាគ្រឿងលើកតម្កើងអ្នកមានឥស្សរិយៈ ។

## ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៩

វីជនណា មានព្យាយាម ដ៏មុឺងម៉ាត់
ប៉ុងប្រយ័ត្ន តាំងស្មារតី ខ្មីរក្សា
មានការស្អាត មិនគ្រោតគ្រាត មិនខ្ជីខ្ជា
ពិចារណា ឲ្យឃើញសិន ហើយទើបធ្វើ ។
ប្រឹងសង្រួម នូវឥន្ទ្រីយ៍ សមរម្យពិត
មានជីវិត រស់នៅស្រួល ដោយធម៌ស្មើ
មិនប្រមាទ ឲ្យឃ្លៀងឃ្លាត វិវង់អើពើ
ជននោះបើ នៅទីណា តែងមានយស ។ល។



# ភាសិតបុរាណថា:

## " ស័ក្តិពុំស្មើយស នារូអ្នកខ្ពង់ខ្ពស់ ពុំស្មើចិត្តជា "

### ពាក្យកាព្យបញ្ជាក់សុភាសិតនេះ

### បទកាកគតិ

*ភាសិតចាស់ថា នរូអ្នកណា មានស័ក្តិខ្ពង់ខ្ពស់*
*មានត្រឹមតែស័ក្តិ ប៉ុន្តែឥតយស ច្រើនតែរលស់*
*កេរ្តិ៍ឈ្មោះទៅឯង ។*

*រីអ្នកមានជាតិ ត្រកូលអាមាត្រ មន្ត្រីជាក់ស្តែង*
*មានចិត្តអាក្រក់ តក់ម៉ក់ស្លាក់ស្លែង មានគេខ្លាចក្រែង*
*ប៉ុន្តែគេស្អប់ ។*

*នរូអ្នកណា ឥតមានសភា ប៉ុន្តែមានទ្រព្យ*
*មានគេរាប់អាន ជុំវិញគ្រប់សព្វ ដប់អ្នកទាំងដប់*
*សឹងមូលចូលគ្នា ។*

*ព្រោះគេមានចិត្ត មេត្តាអាណិត ប្រណីហៅរក*
*ស៊ីចុះមិនគិត ជេរទៅហៅមក អ្នកផងចូលជ្រក*
*បំពេញយសឲ្យ ។ល។*

**វត្តខ្ទណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យ ទី២១ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**

# នវសំខ្យា និង បញ្ចសំខ្យា

**អ អា ឥ ឮ ឧ ឩ ឯ ឱ ញ ន** *អក្សរ ១០ តួនេះទុកថាជា សូន្យ ( ០ ) ហៅថា*
*០ ០ ០ ០ ០ ០ ០ ០ ០ ០* *សុញ្ញសំខ្យា ឬសូន្យសំខ្យា ។*
**ក ខ គ ឃ ង ច ឆ ជ ឈ** *អក្សរ ៩ តួនេះជា នវសំខ្យា ។*
*១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩*
**ដ ឋ ឌ ឍ ណ ត ថ ទ ធ** *អក្សរ ៩ តួនេះជា នវសំខ្យា ។*
*១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩*
**ប ផ ព ភ ម** *អក្សរ ៥ តួនេះជាបញ្ចសំខ្យា ។*
*១ ២ ៣ ៤ ៥*
**យ រ ល វ គ ប ស ហ ឡ** *អក្សរ ៩ តួនេះជា នវសំខ្យា ។*
*១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩*

*ត្រូវរាប់ថយក្រោយជាងរាប, ដូចជា* **មាឃវស្សានិ**
*៥ ៤*
*អស់វស្សាទាំងឡាយ ៤៥,* **ពុទ្ធសកេ ខយាមរេ** *ក្នុងពុទ្ធសករាជ ២៥១២ ;*
*២ ១ ៥ ២*
**គ្រិស្តសកេ ឬ កិដ្ឋសកេ ឧិតាធយេ** *ក្នុងគ្រិស្តសករាជ ១៩៦៨ ។*
*៨ ៦ ៩ ១*

*ព្រះគន្ថរចនាចារ្យ បានចងបាលីទុកជាឧទាហរណ៍ខាងក្រោមនេះ ទុកឲ្យអ្នកបាលីបានចេះតៗគ្នាមកថា ៖*

**អនញ្ញាកខ្ទី** *២១.០០០ គឺព្រះវិន័យមាន ២១.០០០ ព្រះធម្មក្ខន្ធ ;*
*០ ០ ០ ១ ២*

**ទ្វេនានភារី** ២១.០០០ គឺព្រះសូត្រមាន ២១.០០០ ព្រះធម្មក្ខន្ធ ;

០ ០ ០ ១ ២

**ទ្វេនានរវេ** ៤២.០០០ គឺព្រះអភិធម្មមាន ៤២.០០០ ព្រះធម្មក្ខន្ធ ;

០ ០ ០ ២ ៤

**ទ្វេនានខាហា** ៨៤.០០០ ( រួមជាបិដកទាំងបីមាន ៨៤.០០០ ព្រះធម្មក្ខន្ធ គឺ

០ ០ ០ ៤ ៨ ព្រះធម៌វិន័យមាន៨៤.០០០ ព្រះធម្មក្ខន្ធ ) ។

## លោកតែងជាគាថាបថ្យាវត្តថា ៖

**អនញ្ញានចិរី ភូមិ** ផែនដីមានកម្រាស់ ២៤០.០០០ យោជន៍;

០ ០ ០ ០ ៤ ២

**អនញ្ញាខាធិ ខុទធិ** ទឹកសមុទ្រ ( ត្រង់ដែលជ្រៅណាស់ ) មានជម្រៅ ៨៤.០០០

០ ០ ០ ៤ ៨ យោជន៍; ( **ខុទធិ** កាត់បទសន្ធិជា **ខ+ ឧទធិ** " សមុទ្រ " គឺ **ខ** អាគម ដែលចុះថែមមកសម្រួលគាថាជា **ជ- គណៈ** ) ;

**អនញ្ញាទុតិយោ មេរុ** ភ្នំមេរុ គឺភ្នំព្រះសុមេរុមានកម្ពស់ ១៦៨.០០០ យោជន៍;

០ ០ ០ ៨ ៦ ១ **តស្សាកម្បិត្ថ តេជសា** ក៏កក្រើករំពើកដោយតេជៈនៃព្រះសម្មា- សម្ពុទ្ធអង្គនោះ ( ក្នុងកាលដែលមានមហាស្ចារ្យម្តងៗ ) ។

ពាក្យថា **យោជន៍** ក្នុងទីនេះសំដៅយកខ្នាត ៧ ហត្ថ ដោយគណនា ឬ វាស់ពីក្រោមឡើងលើឬក៏ពីលើចុះទៅក្រោម គឺ ៧ ហត្ថ ហៅថាមួយយោជន៍ដូចបាលីដែលធ្លាប់តែ មានក្នុងរឿងខ្លះថា **យោជនសត្តុព្វេធោ មហានិគ្រោធរុក្ខោ** ដើមជ្រៃធំមានកម្ពស់ ៧ យោជន៍ គឺមានកម្ពស់ ៤៩ ហត្ថ ( ហត្ថមជ្ឈិមបុរស គឺហត្ថ ខ្នាត ) ។

*មិនពិបាកយល់ប៉ុន្មានទេ, ខ្ញុំនិយាយត្រឹមតែប៉ុណ្ណោះ អស់លោក - អ្នករៀនបាលី ឬ សំស្ក្រឹតដែលពុំទាន់បានចេះសំខ្យាបែបនេះ ក៏ល្មមសិក្សាឲ្យចេះនឹងបានហើយ ។*

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យ ទី២១ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# អបាយមុខ

ពាក្យថា អបាយមុខ នេះជាភាសាសំស្ក្រឹតនិងបាលី, បើរើសើឲ្យឃើញរូបសព្ទ មាន ៣ ផ្នែកគឺ **អប** ( អៈប៉ៈ ) " ប្រាស, ទាសចេញ, ឃ្លាតចេញ ", **អាយ** ( អាយ៉ៈ ) " សេចក្ដីចម្រើន ", **មុខ** ( មុខៈ ) " ប្រមុខ, ប្រធាន, ប្រភព " រួមភ្ជាប់គ្នាជា **អបាយមុខ** ប្រែថា " ហេតុជាប្រមុខនៃការប្រាសចាកសេចក្ដីចំរើន គឺហេតុជាប្រធាននៃសេចក្ដីវិនាស "។

ព្រះពុទ្ធសាសនាប្រាប់ថា អបាយមុខ, ដោយសង្ខេប មាន ៤ យ៉ាងគឺ៖

**១. ឥត្ថីធុត្ត** ការលេងស្រី ;

**២. សុរាធុត្ត** ការលេងស្រា ;

**៣. អក្ខធុត្ត** ការលេងល្បែងភ្នាល់ ឬ ល្បែងស៊ីសង ;

**៤. បាបមិត្រ** មានជនប្រព្រឹត្តអាក្រក់ជាមិត្រ ;

ទាំង ៤ យ៉ាងនេះ ជាប្រមុខនៃការហិនហោចឬសេចក្ដីវិនាស ។ បណ្ដា អបាយមុខទាំង ៤ យ៉ាងនេះ, បុគ្គលណាញៀនជាប់ទោះត្រង់អបាយមុខណាក៏ដោយ, បុគ្គលនោះក៏រមែងតែដល់នូវការហិនហោច ឬ វិនាសទ្រព្យធន បើមិនច្រើនក៏តិច ពុំដែលខានឡើយ ។

## ពាក្យកាព្យឲ្យងាយចាំ

## បទពាក្យ ៧

អបាយមុខជម្រុកហិន សង្កិនឲ្យក្ដៅដួងហឫទ័យ
ច្រើននាំអ្នកលេងឲ្យសន្សៃ យប់ថ្ងៃដេកព្រួយនឹកស្ដាយក្រោយ។
កំពុងប្រព្រឹត្តងងឹតឈឹង លុះដល់វំពឹងឃើញញឹកញយ
ទើបបានយល់ច្បាស់ថាខ្លួនឆ្គាយ ជួនក៏បណ្ដោយដេញដើងទៀត ។
ដេញដើងលុះត្រាតែលិចលង់ វិងវឹតតែល្វង់ទ្រូងចង្អៀត
អ្នកខ្លះម្ដីងហើយនៅតែឆ្លៀត អង្រៀតនឹងស្លាប់ទើបថយក្រោយ។

ទំរាំភ្ញាក់ខ្លួនជួនអស់ទ្រព្យ ជួនកាលធ្លាក់ជាប់ដល់រូបខ្សោយ
កើតរោគឈឺចាប់ស្លាប់បណ្ដោយ គួរឲ្យព្រឺខ្លាចអបាយមុខ ។
ហេតុនោះយុវនៃយុវតី នាងអ្នកប្រុសស្រីគួរខ្លាចទុក
ឲ្យហើយពីក្មេងទាន់មានសុខ ត្រូវខំសម្រុកប្រឹងរៀនសូត្រ ។
នាងអ្នកចូររៀនកុំធុញទ្រាន់ ទាន់វ័យនៅក្មេងត្រូវខំស្ទូត
ស្ទូតរៀនឲ្យទាល់តែរហូត បានដល់កោះត្រើយសីមសំរាក ។
វិទ្យាជាទ្រព្យដ៏ចម្បង កន្លងលើសលែងឥតទ្រព្យសាក
ជាទ្រព្យស្រាលផងមិនលំបាក វេចជាបង្វេចស្ពាយពុនវេរ ។
ទៅមកយកជាប់ទៅជាមួយ វិទ្យាអាចជួយឃើញទាន់ភ្នែក
ចង់បានអ្វីៗវិទ្យាស្រែក ហៅទ្រព្យប្លែកៗឲ្យចូលមក ។៚

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃចន្ទ ទី២២ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្ដេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# មិត្រមិនបោះបង់មិត្រ

**ឧស្សវេ ព្យសនេ ចេវ ទុព្ភិក្ខេ សត្តុវិគ្គហេ**
**រាជទ្វារេ សុសានេ ច យោតិដ្ឋតិ ស ពន្ធុ វេ ។**

*ក្នុងទីឬកាល៦គឺ៖*

*១. ក្នុងទីលេងមហោស្រព ( កណ្តាលវាលដែលពួកមនុស្សអ្នកមើលច្រើនតែបែកខ្ញែកគ្នា គឺអ្នកខ្លះឈរ ត្រង់ណេះ អ្នកខ្លះអង្គុយត្រង់ណោះ ) ;*

*២. ក្នុងកាលមានការវិនាសអន្តរាយទ្រព្យ ធនជាដើម ;*

*៣. ក្នុងទុព្ភិក្ខកាល គឺគ្រាអំណត់អត់ឃ្លាន ;*

*៤. ក្នុងពេលដែលជាប់ចំណោមសត្រូវ ;*

*៥. នៅទីជិតរាជទ្វារ គឺជិតទ្វារព្រះរាជវាំង ( ដែលគេតែងតែខ្លាច ) ;*

*៦. ក្នុងទីស្មសាន គឺព្រៃខ្មោច ( ដែលគេយកខ្មោចស្រស់ៗទៅផ្តេកផ្តួលចោល គួរគេខ្លាច ) ;*

*ទាំង ៦ នេះ, បើអ្នកណាឈរ គឺមិនបោះបង់គ្នាឬមិនរត់ចោលគ្នា អាចនៅកំដរគ្នា ឬហៅរកប្រមែប្រមូលគ្នីគ្នាឲ្យដឹងថាអ្នកណានៅ អ្នកណាបាត់, អ្នកនោះឯង លោកហៅថា ផៅពង្ស គឺជាញាតិជាមិត្រស្និទ្ធជាទឡ្ហមិត្រ គួររាប់រកយកជាគ្នាតរៀងទៅ ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទព្រហ្មគីតិ

*ក្នុងហេតុទាំងប្រាំមួយ គឺមួយទីលេងមហោស្រព*
*ពីរពេលវិនាសទ្រព្យ បីបានភប់លើទុព្ភិក្ស ។*

ប្អូនមានសត្រូវព័ទ្ធ ប្រាំមាត់ទ្វារហ្លួងគួរភ្លឹក
ប្រាំមួយពេលយប់ព្រឹក ចូលទៅក្នុងព្រៃស្មសាន ។
ជនណាស្មារតីរឹង ចិត្តនឹងធឹងចេះរាប់អាន
ជននោះឈ្មោះថាបាន នាមប្រាកដជាថៅពង្ស ។
ស៊ូប្តូរផ្តាច់ជាមួយ ក្នុងក្តីព្រួយមិនបោះបង់
ជាមិត្រចិត្តស្មោះត្រង់ គួររាប់រកយកជាគ្នា ។
ជនណាចេះរាប់អាន តែពេលមានក្តីសុខជា
ពេលព្រួយបោះបង់គ្នា ជននោះជាអ្នកទុស្តមិត្រ ។
ប្រាជ្ញលោកឲ្យចៀសវាង ត្រូវឲ្យរាងលែងជិតស្និទ្ធ
កុំរាប់ឲ្យបានចិត្ត កុំស្និតយកជាគ្នាឡើយ ។
សង្គ្រោះអ្នកសូមទាន គ្រាន់នឹងបានបុណ្យជាត្រើយ
សង្គ្រោះជនចិត្តស្បើយ ឥតផលឡើយបានតែទោស ។៚

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃចន្ទ ទី២២ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# ប្រមាទ និង មិនប្រមាទ

**អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ យេ បមត្តា យថាមតា ។**

*សេចក្តីមិនប្រមាទ គឺការមិនធ្វេសស្មារតី ជាផ្លូវនៃអមតនិព្វាន, សេចក្តីប្រមាទ គឺការធ្វេសស្មារតី ជាផ្លូវនៃមច្ចុ គឺការស្លាប់កើត - កើតស្លាប់, ជនទាំងឡាយណាមិនប្រមាទ ជនទាំងនោះឈ្មោះថាមិនស្លាប់, ជនទាំងឡាយណាប្រមាទ ជននោះឈ្មោះថាដូចជាស្លាប់ស្រេចទៅហើយ ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទកាកគតិ

*វិក្តីប្រយ័ត្ន មិនឲ្យភ្លាំងភ្លាត់ វិបត្តិស្មារតី*
*ជាផ្លូវអម្រឹត វិសិដ្ឋឥតភ័យ ឥតទុក្ខសោកអ្វី*
*កើតមានទៀតឡើយ។*

*វិក្តីប្រហែស ស្មារតីភ្លេចធ្វេស គំនិតតោះតើយ*
*ជាផ្លូវមច្ចុ ស្លាប់កើតឥតស្បើយ ឥតកោះឥតត្រើយ*
*វិលកើតវិលស្លាប់ ។*

*នរូអ្នកណា មានចិត្តក្លៀវក្លា ប្រញឹកប្រញាប់*
*ខំប្រឹងប្រព្រឹត្ត ពិតតាមធម៌ច្បាប់ អ្នកនោះទើបស្លាប់*
*ហើយដូចនៅរស់ ។*

នរូអ្នកណា អាប់ឥតប្រាជ្ញា ប្រមាទស្រស់ៗ
ភ្លេចភ្ញាក់ស្មារតី រាល់ថ្ងៃទាំងអស់ អ្នកនោះនៅរស់
ដោយដកដង្ហើម ។

ព្រះពុទ្ធទ្រង់ប្រាប់ ថាដូចជាស្លាប់ ស្រេចហើយគួរខ្ពើម
ទោះបីនៅរស់ ដោយសារដង្ហើម អ្នកប្រាជ្ញលោកផ្អើម
ស្មើរក្អួតចង្អោរ ។

ជនផងគួរគិត គួរផ្ចង់គំនិត គួរកាត់គួរកោរ
គួរគេចជៀសវាង គួររាងគួរស្ញោរ រំងាស់ចិត្តចោរ
លួចប្លន់កុសល ។

យើងជាសាមញ្ញ នៅមានក្តីក្នាញ់ គ្នាន់ខឹងរចល់
ក៏ពិតមែនហើយ ប៉ុន្តែកុំខ្វល់ គួរប្រឹងតំកល់
ចិត្តកុំប្រមាទ ។

គួរប្រឹងប្រយ័ត្ន ស្មារតីកុំភ្លាត់ កុំភ្លេចឱវាទ
អ្នកប្រាជ្ញទាំងឡាយ មានព្រះជាអាទិ៍ កុំឲ្យឃ្លៀងឃ្លាត
ចាកធម៌សុចរិត ។៚

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអង្គារ ទី២៣ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# ព្រះពុទ្ធោវាទ

## " ប្រាប់អំពីជនដែលគួរសេពគប់និងដែលមិនគួរសេពគប់ "

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**
**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។**

*បុគ្គលមិនគួរសេពគប់បាបមិត្រឡើយ, បុគ្គលមិនគួរសេពគប់ បុរសអធម[១] គឺបុរសលាមក ( ឬស្ត្រី លាមកា ) ឡើយ, បុគ្គលគួរសេពគប់កល្យាណមិត្រ, គួរសេពគប់បុរសឧត្តម ( ឬស្ត្រីឧត្តមា ) ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៧

*បុគ្គលពុំគួរសេពគប់មិត្រ ចិត្តបាបទុច្ចរិតអាក្រក់ក្រៃ*
*បុរសអធម[១]ឥតតម្លៃ លាមកចង្រៃកុំសេពគប់ ។*
*គួរសេពគប់តែមិត្រកល្យាណ មានចិត្តក្សេមក្សាន្តឥតឧបទ្រព*
*បុរសឧត្តមសមទាំងគ្រប់ គួរតែសេពគប់កុំបោះបង់ ។*
*គប់ពាលពាលនាំទៅរកខុស គប់ប្រាជ្ញជាប្រុសកាន់ពេញអង្គ*
*ឬស្រីដែលមានចិត្តផ្ចិតផ្ចង់ ស្លូតត្រង់នាំត្រង់មករកត្រូវ ។*

---

*(១) អធម អានថា អៈធំ ដូច និយម, មធ្យមដែរ កុំអានថា អៈធមិ ។*

វីការសេពគប់នេះតែងឆ្លង	នោះឥតបំណាងឲ្យខុសផ្លូវ
ក៏តែងជិតដោយតាមគ្នាទៅ	ពុំនៅនិត្យតាមធម្មតាឡើយ ។
មនុស្សខ្ចូកឃ្វាលសេះឥតខ្ចូកសោះ	សេះបោះជំហានតាមរឿយៗ
ដោយវាហាត់តាមពុំកន្តើយ	ពុំយូរលង់ឡើយសេះខ្ចូកដែរ ។
ព្រោះវាហាត់ធ្វើតាមគង្វាល	ដាលរាលឲ្យចិត្តវាងាក់បែរ
វាដើរប៉ាក់ពើកៗដែរ	ព្រោះតែយល់ថាគេបង្ហាត់ ។
ទោះបីជាតិឈើជាតិលតា	វាសេពគប់គ្នាត្រាតែកាត់
ឆ្លងតាមគ្នាវាមិនបាច់ហាត់	តែងបាត់ភាពដើមខ្លះពុំខាន ។
ជាតិល្វីងលាយគ្នានឹងជាតិផ្អែម	ធ្វើជាបង្អែមប្រើការបាន
ព្រោះការសេពគប់អាចរុញច្រាន	ភាពដើមប៉ុន្មានឲ្យប្រែក្លាយ ។ល។

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអង្គារ ទី២៣ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**

# សុទ្ធាសុទ្ធិ

**អត្តនា ច កតំ បាបំ　　អត្តនា សង្កិលិស្សតិ**
**អត្តនា អកតំ បាបំ　　អត្តនា ច វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ　　នាញ្ញោ អញ្ញំ វិសោធយេ ។**

*បាបដែលគេធ្វើហើយខ្លួនឯង នឹងសៅហ្មងខ្លួនឯង, បាបដែលគេមិនធ្វើហើយ ខ្លួនឯងរមែងបរិសុទ្ធខ្លួនឯង, បរិសុទ្ធនិងមិនបរិសុទ្ធ ប្រាកដជាក់ច្បាស់ឯងៗ, ឯអ្នកដទៃមិនគប្បីសម្អាតឲ្យអ្នកដទៃបានឡើយ ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទកាកគតិ

*វិបុណ្យនិងបាប　　រែងមានសភាព　　កើតពីការធ្វើ*
*គឺខ្លួនរាល់ខ្លួន　　សម្រេចអំពើ　　បើជនណាធ្វើ*
*ជននោះរងផល　　។*

*ផលសុខផលទុក្ខ　　រែងតែចេញមុខ　　តាមពេលត្រូវផ្តល់*
*ចេញតាមលំអាន　　កុសលាកុសល　　ឥតអ្វីណាផ្តល់*
*ក្រៅពីនោះទេ　　។*

*ស្អាតនិងមិនស្អាត　　ជាក់ច្បាស់ពេញខ្នាត　　នៃកម្មបុព្វេ*
*ឥតអ្នកដទៃ　　ក្រៅពីខ្លួនទេ　　ជនខ្លះធ្វេសធ្វេ*
*មិនជឿកម្មផល　　។*

*ទោះកម្មចេញមុខ ឲ្យសុខឲ្យទុក្ខ ក៏ដឹងមិនដល់*
*ពុំដឹងថាកម្ម ទេតើផ្តល់ផល ពុំគួរឆ្ងៃឆ្ងល់*
*ពុំយល់ច្បោះឡើយ ។*
*ព្រះពុទ្ធទ្រង់ប្រាប់ គួរតាំងចិត្តស្តាប់ កុំធ្វើតោះតើយ*
*ត្រូវប្រើការពិត ពិនិត្យរឿយៗ ចិត្តស្មៀមព្រងើយ*
*ធ្វើម្តេចនឹងយល់ ។៚*

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអង្គារ ទី២៣ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**
**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**
**ប.អ.ស - អ.ម.រ**



# អំពើអាក្រក់ឆក់ចិត្តឲ្យងាយធ្វើ

**សុករានិ អសាធូនិ អត្តនោ អហិតានិ ច**
**យំវេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។**

*អសាធុកម្ម គឺអំពើរបស់អសប្បុរសទាំងឡាយ ជាអំពើឥតផលប្រយោជន៍ដល់ខ្លួន គេងាយធ្វើទេ, ឯអំពើណាជាសាធុកម្មរបស់សប្បុរស ដែលជាអំពើផ្តល់ផលប្រយោជន៍ ( ដល់ខ្លួន ) អំពើនោះឯងគេពិបាកធ្វើណាស់ គឺមិនងាយនឹងធ្វើកើតទេ ។*

## ពាក្យកាព្យឲ្យងាយចាំ

### បទពាក្យ ៩

*កម្មអាក្រក់ តែងទាញឆក់ ចិត្តជនផង*
*ឲ្យកន្លង ផុតប្រយោជន៍ របស់ខ្លួន*
*គេពុំខ្លាច គេអាចហ៊ាន ធ្វើផ្ទួនៗ*
*ទោះបីខ្លួន បានវិនាស ក៏ពុំរាង ។*
*រីកម្មណា ជាសាធុ ល្អប្រពៃ*
*មានកម្រៃ អាចនាំខ្លួន ឲ្យចៀសវាង*
*ផុតចាកទោស ឥតរឺស ក៏អ្នកនាង*
*ខ្លះច្រើនឃ្លាង កម្របាន ធ្វើកម្មនោះ។៚*

# ព្រះបរមពុទ្ធោវាទមួយយ៉ាងថា ៖

**សុករំ សាធុនា សាធុ   សាធុ បាបេន ទុក្ករំ**
**បាបំ បាបេន សុករំ   បាបមរិយេហិ ទុក្ករំ ។**

*សាធុកម្ម គឺអំពើជាកុសល ជនជាសប្បុរសងាយធ្វើកើត, សាធុកម្ម ជនចិត្តបាបពិបាកធ្វើណាស់ គឺមិនងាយនឹងធ្វើកើតទេ, អំពើបាបជនចិត្តបាបងាយធ្វើកើត, អំពើ បាបអរិយជន គឺជនអ្នកប្រសើរដោយសីលធម៌ ពិបាកធ្វើណាស់ គឺមិនងាយនឹងហ៊ានប្រថុយធ្វើឡើយ ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៩

| | | |
|---|---|---|
| *សាធុជន* | *ស្រឡាញ់បុណ្យ* | *ងាយធ្វើបុណ្យ* |
| *ឯទុជ៌ន* | *ចិត្តទំរន់* | *ធ្វើពុំកើត* |
| *បើបាបវិញ* | *គេងាយធ្វើ* | *ពុំញញើត* |
| *អ្នកប្រាជ្ញឆើត* | *ធ្វើពុំកើត* | *ព្រោះខ្ពើមបាប ។៚* |

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃពុធ ទី២៨ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**
**សម្ដេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**
**ប.អ.ស - អ.ម.រ**



# ផលានិសង្សសុចរិត

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**ឯសានិសំសោ ធម្មេ[១] សុចិណ្ណេ**
**ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។**

*សុចរិតធម៌ តែងរក្សានូវអ្នកប្រព្រឹត្តសុចរិតធម៌ ( នោះឯង ), សុចរិតធម៌ដែលគេបានសន្សំល្អហើយ តែងនាំយកសេចក្តីសុខមកផ្តល់ផលឲ្យ, នេះជាអានិសង្សនៃ[១] ធម៌ដែលគេបានអប់រំសន្សំហើយ, អ្នកប្រព្រឹត្តធម៌រមែងតែមិនទៅកាន់ទុគ្គតិឡើយ ។*

## ពាក្យកាព្យឲ្យងាយចាំ

### បទពាក្យ ៩

*ធម៌សុចរិត តាមការណ៍ពិត តែងរក្សា*
*នូវជនណា ដែលប្រព្រឹត្ត នូវធម៌នោះ*
*ធម៌សុចរិត ដែលបណ្ឌិត សន្សំស្មោះ*
*ពុំដែលផ្សោះ តែងនាំសុខ មកផ្តល់ឲ្យ ។*
*នេះគឺជា អានិសង្ស ការផ្គងចិត្ត*
*ខំប្រព្រឹត្ត សន្សំធម៌ ពុំដែលធ្លោយ*

(១) *សាម្យត្ថេ ភុម្មំ*

វិបុគ្គល អ្នកប្រព្រឹត្ត ធម៌ពុំខ្សោយ<br>
លុះជាតិក្រោយ តែងបានសោយ សុខសួគ៌ ។<br>
រឿងពីព្រេង ព្រះសម្តែង ប្រាប់បញ្ជាក់<br>
ថាមានអ្នក ប្រព្រឹត្តធម៌ សុចរិតា<br>
ពូជធម្មបាល ឥតមានសល់ រូបជនណា<br>
ទាំងអស់គ្នា សុទ្ធតែមាន អាយុវែង ។<br>
ជនណាបាន ប្រព្រឹត្តធម៌ នេះទៀងទាត់<br>
ពុំដែលភ្លាត់ តែងរស់នៅ យូរអង្វែង<br>
ដូចភាសិត ដែលព្រះពុទ្ធ ទ្រង់សម្តែង<br>
ជននោះឯង តែងបានសុខ ប្រសើរហោង ។៚

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃពុធ ទី ២៤ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណា ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# បុរាណភាសិត

## “ និយាយអំពីក្រ ៥ យ៉ាង ”

## ក្រកិច្ច, ក្រកល, ក្រដឹង, ក្រយល់, ក្រវៃច្នៃទាស់

ក្រទាំងប្រាំយ៉ាងនេះមានអត្ថន័យថា៖

១. ក្រកិច្ច គឺការអ្វីៗដែលគេត្រូវធ្វើ ហៅថាកិច្ច, កិច្ចនេះក្រ ពុំមែនងាយទេ ;

២. ក្រកល គឺឧបាយកម្លាយហេតុការណ៍ណាមួយ ហៅថាកល, កលនេះក៏ ក្រ ;

៣. ក្រដឹង គឺការដឹងរឿងហេតុអ្វីក៏ក្រ ព្រោះពុំងាយបានដឹងជាក់ប្រាកដទេ ច្រើនតែដឹងលំៗស្រាលៗ ;

៤. ក្រយល់ ការយល់ចេះក៏ក្រ ព្រោះច្រើនតែបានដឹង ប៉ុន្តែពុំយល់ ដូចគេសួរថា អ្នកបានដឹងរឿងហ្នឹងទេ ? ឆ្លើយថាដឹង ; ចុះយល់ទេ តើរឿងហ្នឹងយ៉ាងម៉េច ? ខ្ញុំពុំយល់ទេ ;

៥. ក្រវៃច្នៃទាស់ ការទទឹងទាស់ ឲ្យគេទាស់គាំងភ្លាម ត្រូវតាមការណ៍ពិត ឬត្រូវតាមផ្លូវច្បាប់ញ៉ាំងគេឲ្យស្លូវសាក ឬតវ៉ាថាម៉េចទៅទៀតពុំកើត ហៅថា វៃច្នៃទាស់, វៃច្នៃទាស់នេះក៏ក្រណាស់ ជាងក្រទាំង ៤ ខាងលើទៅទៀត ។

ដោយហេតុនេះបានជាបុរាណភាសិតថា **ក្រ** ។

# ពាក្យកាព្យឲ្យងាយចាំ

## បទកាកគតិ

ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រវៃឆ្មៃទាស់
ទាំងប្រាំនេះសុទ្ធ តែក្រទាំងអស់ ប្រាជ្ញាស្រួចស្រស់
ទើបក្រឃ្លាតបាន ។

ខ្វះការអប់រំ រមែងច្រឡំ ខ្លះៗពុំខាន
បើលុះតែខំ អប់រំឲ្យមាន ការថ្នឹកទើបបាន
រួចផុតចាកក្រ ។

កុំយល់ថាងាយ ទោះការសម្វាយ សុទ្ធតែកម្រ
លុះតែបានរៀន បានស្តាប់តៗ ទើបបានការក្រ
ក្លាយជាងាយខ្លះ ។

ទោះកិច្ចតូចទេ ខ្វះការវិះរេ ធ្វើទៅតែងខ្វះ
ទោះធ្វើទៅកើត ក៏មិនស្អាតជ្រះ ព្រោះពាក្យថាខ្វះ
ផ្ទុយនឹងគ្រប់គ្រាន់ ។

ចំណែកខាងកល ឧបាយក្រយល់ ក៏ច្រើនតែភ័ន្ត
ជួនកាលគំនិត វង្វេងវង្វាន់ ជួនកាលស្លស្លន់
យល់ខុសទទេ ។

បើប្រើតាមកល ដែលគិតពុំយល់ ខ្វះការវិះរេ
ចេះតែស្មានៗ បំពានធ្វេសធ្វេ ឬតាមតែគេ
នាំខុសជាត្រូវ ។

វិបការដឹង បើគ្មានដំណឹង ក៏ឥតមានផ្លូវ
ណាប្រាប់ឲ្យដឹង មីងមាំងស្រមូវ ការខុសឬត្រូវ
ក៏ឥតបានដឹង ។

ការដឹងក៏ក្រ បើគ្មានតំណ តជាដំណឹង
ឥតមានគំនិត ងងឹតសូន្យឈឹង ហេតុនោះការដឹង
ក៏ឈ្មោះថាក្រ ។

ចំណែកខាងយល់ ជាការអំពល់ មួយដ៏កម្រ
បើគ្រាន់តែដឹង ដោយឮតៗ ប៉ុន្តែខ្លួនស
ប្រាប់ថាពុំយល់ ។

ដូចគេសួរថា តើអ្នករាល់គ្នា យល់ឬពុំយល់
រឿងដែលខ្លួនដឹង ដំណឹងសល់វ៉ល់ ខ្លួនថាពុំយល់
ខ្ញុំគ្រាន់តែដឹង ។

ហេតុនេះការយល់ លុះតែអំពល់ គិតពេញទំហឹង
បើឥតគំនិត វិះរេជញ្ជឹង ក៏គ្រាន់តែដឹង
កម្របានយល់ ។

បវែវច្រៃទាស់ ក្រជាងទាំងអស់ ព្រោះច្រើនលើសកល់
នៅតាំងជ្រែងោ ដោយគិតមិនដល់ ក៏នៅស្រងល់
ដោះស្រាយមិនរួច ។

នៅពេលជំនុំ ឬគេមកជុំ គេតាំងផ្ដើមផ្ដួច
គេសួរបញ្ហា ណាមួយក្របួច បងឆ្លើយពុំរួច
នៅផ្ទឹងតែម្ដង ។

បើមានប្រាជ្ញា រហ័សក្លៀវក្លា គំនិតហ្មត់ហ្មង
ឆ្លើយបានភ្លាមភ្លែត ត្រដែតកន្លង អ្នកសួរអត់សង
សួរសបវិញទៀត ។

ហេតុនេះបានជា ចាស់លោកពោលថា ការណ៍នេះចង្អៀត
កម្រមានអ្នក ឈ្លាសវៃឆ្លាក់ឆ្លៀត គេសួរថែមទៀត
ពុំអាចឆ្លើយឆ្លង ។

បើរឿងនោះធំ អាចនឹងរលំ ខូចការតែម្តង
ហេតុនេះបានជា ព្រឹទ្ធាចារ្យផង អ្នកចេះហ្មត់ហ្មង
ពោលទុកថាក្រ ។

ក្រវៃច្នៃទាស់ លើសក្រទាំងអស់ ហៅពេញជាក្រ
លុះតែរៀនគិត ឲ្យបានល្អិតល្អ នោះទើបក្តីក្រ
នេះឃ្លាតចេញឆ្ងាយ ។៚

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃពុធ ទី ២៤ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# កតញ្ញុតា

## " នាវានៃអ្នកដឹងគុណ "

### បទកាកគតិ

កតញ្ញុតា មានន័យប្រាប់ថា ជនកតញ្ញូ
ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះជាគ្រូ
ប្រាប់ឲ្យតបគុណ ។

មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ
ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ
ដែលត្រូវសាបព្រោះ។

បណ្តុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឲ្យមានមោះ
បុណ្យនឹងកើតកើន ចម្រើនឥតខ្ចោះ ត្រូវមានចិត្តស្មោះ
កុំលប់គុណចោល ។

កុំគ្រាន់តែថា មាតាបិតា មានគុណជាគោល
មាត់ថាត្រូវតប គុណកុំច្បោលៗ ធ្វើដែរស្រោលៗ
សោះតែគេថា ។

ជនអ្នកតបគុណ ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេស្នា
សរសើរញឹកញយ មានក្នុងសាស្ត្រា គម្ពីរដីកា
គួរយើងចងចាំ ។

ចេះចាំហើយធ្វើ ដោយចិត្តអើពើ ឲ្យស៊ប់ឲ្យស៊ាំ
ឲ្យស្និទ្ធនឹងគុណ គុណតែងថែទាំ ពុំមែនខ្វេចខ្វាំ
ព្រោះតបគុណទេ ។

ជនមានចិត្តខ្សោយ ច្រើនតែឆ្វេសឆ្វោយ រមិលគុណគេ
អាងព្រេងសំណាង ពីក្នុងបុព្វេ ប្រហែសធ្វេសទ្វេ
ព្រងើយកន្តើយ ។

អ្នកប្រាជ្ញប្រាប់ថា ជនប្រុសស្រីណា លុបគុណចោលហើយ
ជនប្រុសស្រីនោះ ពុំមានសុខស្បើយ យូរប៉ុន្មានឡើយ
រៃងតែធ្លាក់ខ្លួន ។

កំពុងបានសុខ ស្រាប់តែមានទុក្ខ ចេញមុខផ្ទួនៗ
ឲ្យផលកំណាច ឃោរឃៅឥតស្ងួន ទោសមកពីខ្លួន
រមិលគុណគេ ។

ទេព្តាគេខឹង ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ
ទោសបច្ចុប្បន្ន ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ
បើមានក៏ផ្អាក ។

ទោសរមិលគុណ រារាំងមុខបុណ្យ ព្រេងឲ្យសំរាក
បង្អង់ឈប់សិន បាបថ្មីវិបាក ឲ្យផលឥតស្រាក
ព្រោះបានឱកាស ។

បុណ្យបាបចាស់ថ្មី តែងតែរំពៃ ពុំមែនផ្តេសផ្តាស
កាលមានចន្លោះ ត្រូវពេលសស្រាស ហាក់ដូចប្រកាស
ប្រាប់ថាត្រូវអញ ។

ចេញមុខផ្តល់ផល សុខទុក្ខឲ្យដល់ ជនដែលកកាញ់
កសាងបង្កើត កំណើតជាអញ អញជាសម្លាញ់
ត្រូវអញឲ្យផល ។

រីបុណ្យនិងបាប ដែលមានសភាព ជាកម្មតែងផ្តល់
សុខទុក្ខឲ្យជន អ្នកធ្វើឲ្យដល់ នូវក្តីសល់វ៉ល់
ឬក្តីសុខសាន្ត ។

បាបតែងរារាំង បុណ្យឲ្យនៅគាំង ផ្អាកសិនពុំបាន
ចេញមុខឲ្យផល ជាសុខសម្រាន្ត អ្នកធ្វើតែងបាន
ទទួលរងទុក្ខ ។

បុណ្យក៏រារាំង បាបឲ្យនៅគាំង ផ្អាកពុំចេញមុខ
ព្រោះមានឱកាស បុណ្យផ្តល់ក្តីសុខ សុទ្ធតែមានមុខ
ទីទៃពីគ្នា ។

ហេតុនេះគួរជន កុំនៅទម្រន់ ក្នុងក្តីខ្ជិលច្រអូស
គួរកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថា
អ្នកស្រឡាញ់ខ្លួន ៕៚



# អកតញ្ញូឥតគ្រូប្រដៅកើត

**អកតញ្ញុ បោសស្ស    និច្ចំ វិវរទស្សិនោ**
**សព្វញ្ចេ បឋវី ទជ្ជា    នេវ នំ អភិរាធយេ ។**

*បើទុកជាគេលើកយកនូវផែនដីទាំងមូលឲ្យដល់ជន អកតញ្ញូ ជាអ្នកឃើញនៅចន្លោះ ទោសជានិច្ចជាកាលក៏ដោយ គេក៏ពុំអាចញុំាងវាឲ្យរីករាយបានឡើយ ( ពីព្រោះវាចេះតែរាវរករឿងរកទោស ហាក់ដូចជាវាតបស្នងសងគុណវិញជានិច្ចនិរន្តរ៍ ) ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៧

*អកតញ្ញូលុបលាងគុណ    ឃោរឃៅជ្រុលស៊ុនឥតដឹងអ្វី*
*ទោះបីគេលើកយកផែនដី    រដ្ឋរាជបុរីឲ្យក៏ដោយ ។*
*វាក៏ឥតនឹកគុណតិចតួច    វាចេះតែផ្ដួចរករឿងញយ*
*ព្យាបាទផ្ដន្ទាពុំថយក្រោយ    វាឲ្យទុក្ខព្រួយវិញតបគុណ ។*
*ព្រះពុទ្ធប្រាប់ថាជនចិត្តទុស្ត    វាកាន់ក្ដីខុសជ្រុលហួសស៊ុន*
*ឥតគ្រូប្រដៅឲ្យដឹងគុណ    ទោះអ្នកមានបុណ្យក៏ទាល់ប្រាជ្ញ ។*
*ស្ដីថ្វីចំពោះជនល្ងង់ខ្លៅ    ត្រូវពោលសំដៅជនអង់អាច*
*ដែលលើកឲ្យវាខ្ពស់ត្រដាច    ក៏វាមិនខ្លាចតិចតួចឡើយ ៕៚*

# សេចក្ដីបញ្ជាក់បន្ថែម

*កាលព្រះសក្យមុនីសម្ពុទ្ធព្រះអង្គឋិតនៅក្នុងសភាពជាពោធិសត្វ វិបត្តិកំណើតកើតជាដំរីព្រៃមានភ្លុកទាំងពីរធំវែង ៦ ទន្លាំ ធន់ទ្រាំឲ្យព្រានព្រៃអារយកចុងភ្លុកទាំងពីរ ដោយខំប្រឹងធ្មេចភ្នែក ព្រានវាវិកយកចុងភ្លុកនោះទៅ, លុះគ្រាទីពីរ ព្រានព្រៃក៏មកអារម្ដងទៀត, ដំរីក៏ទ្រាំឲ្យវាអារភ្លុកបន្តមកទៀត ។ ក្នុងគ្រាចុងក្រោយបំផុត, ព្រានអកតញ្ញូកំណាចចង្រៃនោះ វាវាយសំពងដកយកភ្លុកទាំងស្រុង លុះត្រាតែដំរីនោះស្រុត គឺផុតរលត់ក្ស័យជីវិតទៅ, ផ្ទៃផែនដីដ៏ជ្រៅទ្រាំនឹងវាពុំបាន ក៏បែកសព្វែកហាស្រូបយកព្រានអកតញ្ញូឃោរឃៅនោះទៅ ។*

*ដោយហេតុដូចនេះឯង បានជាព្រះសក្យមុនីសម្ពុទ្ធជាបរមសាស្ដាទ្រង់ត្រាស់ពន្យល់ថា* **នេទ នំ អភិរាធ យេ** *ឥតអ្នកណាមួយអាចញ៉ាំង ជនអកតញ្ញូនោះឲ្យវារីករាយ ( ចម្លោះការទំនុកបម្រុងវានោះ ) បានឡើយ ។*

*តាមការណ៍ពិត, ជនអកតញ្ញូតែងតែពុំដែលរួចខ្លួនក្នុងជាតិនេះនិងជាតិខាងមុខសូម្បីម្នាក់ឡើយ ។*

## កាព្យបរិយោសាន

## បទកាកគតិ

*អកតញ្ញូ លុបលាងគុណគ្រូ មាតាបិតា*
*ទោះបីវាទៅ នៅក្នុងទីណា ឥតមានទេវ្ដា*
*ណាជួយវាឡើយ ។*

ផលទោសអាក្រក់ យោរយៅតក់ម៉ក់ តែងផ្តល់បង្អើយ
ឲ្យវាលិចលង់ ភ័ន្តផុងឥតស្បើយ ឥតមានកោះត្រើយ
ពឹងពួនជ្រកកោន ។

មានតែរងទុក្ខ គ្រប់បែបគ្រប់មុខ ខ្លួនវាក្រញោន
ទុក្ខចាប់គ្រញិក តត្រុនកំប្រោន ទីពឹងទីកោន
នៃវាគឺទុក្ខ ។

គួរសាធុជន តាំងចិត្តឲ្យធ្ងន់ យកគុណជាមុខ
កុំធ្វើលែនលន កុំស៊ុកគ្រលុក គុណជាជម្រុក
នៃក្តីសុខសាន្ត ។៚



# ន័យមួយយ៉ាងទៀតថា ៖

## បទកាកគតិ

*អកតញ្ញូ ពុំដឹងគុណគ្រូ មាតាបិតា*
*និងអ្នកមានគុណ ឯទៀតណាៗ ចិត្តវាហានក្លា*
*រករឿងចាប់ទោស ។*
*ទោះអ្នកមានគុណ មានចិត្តជាបុណ្យ អត់ឱនសន្តោស*
*សង្គ្រោះឲ្យវា រួចចាកទុក្ខទោស វានៅតែកោស*
*រូសរករឿងទៀត ។*
*ទោះលើកផែនដី ទាំងមូលឲ្យក្តី វានៅតែឆ្លៀត*
*រករឿងវ៉ារវិញ ដោយការជ្រែកជ្រៀត នាំជនឯទៀត*
*ឲ្យចូលដៃផង ។*
*នេះគឺជនពាល គំនិតរោលរាល អាក្រក់កន្លង*
*ទោះព្រះសម្ពុទ្ធ វិសុទ្ធឥតហ្មង ក៏អាចចម្លង*
*វាពុំបានឡើយ ។៚*

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃពុធ ទី ២៤ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**

# បុរាណភាសិត

## ( ប្រើតាមសម័យនិយមព្រេងនាយ )

# សំដីជាឯក លេខជាទោ អក្សរជាត្រី

*អត្ថន័យខ្លីថា ទោះនិយាយស្តីមាត់ទទេក្តី ទោះសរសេរសម្តីជាលាយលក្ខណ៍អក្សរក្តី សម្តី មានឋានៈ* **ជាឯក** *ទាំងខាងសម្រេចប្រយោជន៍ ទាំងខាងឥតប្រយោជន៍ ។ លេខនព្វន្ត, ក្នុងបុរាណសម័យ, មាននាទីត្រឹមតែខាងគណនា បូក គុណ ចែក សង ប៉ុណ្ណោះ ទោះបីសម័យវិទ្យានិយមសព្វថ្ងៃនេះ ដែលគេលើកលេខជាគណិតវិទ្យាមានឋានៈ* **ជាទោ** *ដូច ក្នុងសម័យបុរាណព្រេងនាយនោះដែរ ។ ឯអក្សរ, ពិតតែជាប្រភព ឬជាមេ ជាគ្រូនៃវិទ្យាទាំងពួងជាដើមក៏មែន ប៉ុន្តែមានឋានៈត្រឹមតែឲ្យវិទ្យាទាំងពួង និងសម្តីប្រើប្រាស់ប៉ុណ្ណោះ, ព្រោះហេតុនោះ អក្សរត្រូវមានឋានៈត្រឹមតែ* **ថ្នាក់ត្រី**...។

## ពាក្យកាព្យឲ្យងាយចាំ

## បទកាកគតិ

*សំដីជាឯក ក្នុងការជជែក ថ្លែងការណ៍នានា*
*បើអន់សំដី គប្បីយល់ថា ជជែកតវ៉ា*
*ជាដើមតែងភ្លាត់ ។*

*ទោះមានការយល់ តែស្តីមិនដល់ គ្រាន់តែហើបមាត់*
*ពីរបីបួនម៉ាត់ គេស្កាត់សង្កត់ ទៅជាបិទមាត់*
*ហើបហារមិនរួច ។*

សម្តីស្រួចស្រស់ កិច្ចការទាំងអស់ ឡើងខ្ពស់ត្រដួច
ក្នុងការជជែក រែករញែកចងក្អួច ក្រសោបក្របួច
ឲ្យជាប់កុនបាន ។

ហេតុនោះបានជា ភាសិតវាចា អ្នកប្រាជ្ញបុរាណ
ហ៊ានចងទុកមក យកតាមលំអាន ប្រាជ្ញមុនថាមាន
សម្តីជាឯក ។

ឯលេខនព្វន្ត ប្រើការគិតគន់ ចំនួនប្លែកៗ
លេខបូកលេខគុណ លេខសងលេខចែក មិនទុកជាឯក
ទុកថាជាទោ ។

ប៉ុន្តែសព្វថ្ងៃ នព្វន្តឡើងថ្លៃ គណិតសេដ្ឋោ
សម្រាប់ប្រើប្រាស់ គន់គិតរាវរក គំនិតគាំងគ
គណិតអាចប្រាប់ ។

អ្នករៀនវិទ្យា នេះទាំងអស់គ្នា បើមិនប្រញាប់
ខំប្រឹងសិក្សា វិទ្យានេះអាប់ ប្រឡងប្រុងជាប់
ត្រឡប់ជាយែត ។

លុះតែខិតខំ សិក្សាថែមផ្សំ ពិនិត្យសង្កេត
ប្រឡងក្រោយទៀត ទើបបានខានយែត ចិត្តខ្ពស់ត្រដែត
អរស្ញើរលោតហ៊ោ ។

អក្សរជាត្រី សរសេរសេចក្តី កើតជាអហោ
ប្រើពុំដែលអស់ ហាក់ស្រស់សន្ធោ ចេញមុខឆ្លោៗ
ជាគ្រូវិទ្យា ។

*វិទ្យាបវរ      បើឥតអក្សរ      បានអ្វីកត់ត្រា*
*ហេតុនេះលោករាប់      ថាជាសាស្ត្រា      ចំណោះនានា*
*អក្សរជាមេ ។*

*បើតាមន័យនេះ      ឃើញថាចំណោះ      ដែលប្រាជ្ញវិះរេ*
*សរសេកត់ត្រា      ក្រែងមាត់ទទេ      យូរទៅឆ្វេសទ្វេ*
*នឹងភ្លេចសូន្យបង់ ។*

*គួរលើកអក្សរ      ជាគ្រូបវរ      នេះឲ្យសមអង្គ*
*ឲ្យឡើងថ្នាក់ឯក      ឬទោទើបត្រង់      ត្រូវតាមទម្រង់*
*ដែលគួរសន្មត ។*

*ប៉ុន្តែអក្ខរា      បានជាចាស់ថា      សម្រាប់តែកត់*
*កុំឲ្យរសាយ      រលាយបែបបទ      ទើបចាស់កំណត់*
*ឲ្យជាត្រីវិញ ។*

*អ្នករៀនវិទ្យា      គួរពិចារណា      កុំមានក្តីម្នេញ*
*រឿងឯករឿងទោ      រឿងត្រីនេះមិញ      ឆ្ងល់គួរទន្ទេញ*
*កាព្យនេះឲ្យចាំ ។*

*គិតយូរៗទៅ      កុំតែសៅដៅ      នឹងអាចចំណាំ*
*បើយល់ន័យហើយ      ត្រូវនឹកឲ្យចាំ      ចាំស្ទាត់អាចនាំ*
*ឲ្យលែងឆ្ងៃឆ្ងល់ ។៚*

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី ២៤ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**

# អត្តសមុដ្ឋាន

## ការតាំងខ្លួនដោយខ្លួនឯងឲ្យរួចផុតពីទ័លក្រ

**អប្បកេនបិ មេធាវី   បាភតេន វិចក្ខណោ**
**សមុដ្ឋាបេតិ អត្តានំ   អណុំ អគ្គឹវ សន្ធមំ ។**

*មេធាវី គឺអ្នកប្រាជ្ញខាងការប្រើប្រាជ្ញាទម្លុះទម្លាយ ជាអ្នកចេះពិចារណា រិះរេ លៃលក អាចលើកតម្កើងខ្លួនបាន ដោយទ្រព្យជាដើមទុន សូម្បីបន្តិចបន្តួចស្តួចស្តើងសោះទេ ដូចគេផ្លុំបង្កាត់រងើកភ្លើងតូចមួយឲ្យកាត់ឆេះភ្លឺសន្ធោសន្ធៅឡើងបានដូច្នោះដែរ ។*

### ពាក្យកាព្យឲ្យងាយចាំ

### បទកាកគតិ

*វិមេធាវី ប្រាជ្ញប៉ុះពេញទី ឈ្លាសវៃប្រាកដ*
*ចេះសាងសន្សំ ទ្រព្យដោយហ្មត់ចត់ ព្យាយាមទៀងទាត់*
*តាំងខ្លួនឯងបាន ។*
*ដើមទុនតិចតួច ចេះលៃផ្តើមផ្តួច ឲ្យកើតធនធាន*
*ពីមុនក្រសោះ ផ្លោះឡើងជាមាន ពុំយូរប៉ុន្មាន*
*បានជាសេដ្ឋី ។*
*រងើកភ្លើងតូច ដែលប្រៀបប្រដូច នឹងភ្នែកមាន់ព្រៃ*
*គេផ្លុំបង្កាត់ ដោយការឃ្មាតឃ្មី ឆេះភ្លឺដូចថ្ងៃ*
*អាស្រ័យព្យាយាម ។*

រកស៊ីតក់ៗ ដូចកល់តំណក់ ទឹកភ្លោតស្រក់តាម
សភាពវាស្រក់ មិនញាប់ភ្លាមៗ យូរទៅបាននាម
ចាពេញបំពង់ ។
កុំចង់មានឆាប់ ប្រញឹកប្រញាប់ ប្រឹងហួសមាឌខ្លង់
ដល់ខ្ចីបុលគេ ចាយអស់ឥតគង់ ទាល់តែលិចលង់
ដើបក្បាលពុំរួច ។
ដំបូកតូចធំ កើតពីសង្គម កណ្ដៀរវាផ្ដួច
វាស្រុះគ្នាពូន ឡើងខ្ពស់ត្រដួច ពុំមែនព្រោះលួច
ទេព្រោះសន្សំ ។
ពុំនោះដូចឃ្មុំ ធ្វើឆ្កិតតូចធំ វាស្រុះគ្នាខំ
ហើរត្របកេសរ ផ្កាលាយច្រឡំ ប្រមូលមកផ្សំ
ធ្វើបានជាឆ្កិត ។
គួរជនទ័លក្រ សង្កេតសម្គាល់ យកជាគំនិត
ធ្វើការរកស៊ី ត្រូវខំប្រឹងគិត កុំទាល់គំនិត
យោបល់ឡើយហោង ។៚

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃសុក្រ ទី ២៦ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# ពុទ្ធភាសិត និង បុរាណភាសិត

## " បន្លាមុតយកបន្លាជោះ សេះដាច់យកសេះតាម "

*ពុទ្ធភាសិតថា* **កណ្ឌកេន កណ្ឌកុទ្ធរណំ** *" ជោះបន្លាដោយបន្លា " បុរាណភាសិតថា " សេះដាច់ ជិះសេះតាម " សេះមួយទាញបណ្ដោច់ខ្សែចំណងបោលបាត់ទៅ ត្រូវជិះសេះមួយផ្សេងតាមទើបនឹងបានទាន់សេះដែលដាច់នោះ " ។ អ្នកប្រាជ្ញបុរាណយកសុភាសិតទាំងពីរ មករួមបញ្ចូលគ្នា ដូចអត្ថបទខាងលើ ។ ភាសិតទាំងពីរ មានអត្ថន័យផ្សេងគ្នាខ្លះបន្តិចបន្តួច ប្រើខាងផ្លូវធម៌ក៏បាន ខាងផ្លូវលោកក៏បាន ។*

*ខាងផ្លូវធម៌ ដូចជា យករូបជោះរូប គឺអារម្មណ៍ ឬគំនិតរបស់ បុថុជ្ជន ដែលយល់ថារូបបុរសស្ត្រី ស្អាតល្អគួរស្រឡាញ់, ត្រូវប្រើគំនិតផ្សេងតាមការណ៍ពិតថា រូបសព្វាង្គកាយ នៃបុរសស្ត្រីសុទ្ធតែជាបដិកូល គួរខ្ពើមគួរឆ្អើម ដ្បិតតាមការណ៍ពិតរូបកាយទាំងស្រុងនៃបុរសស្ត្រី ទាំងខាងក្រៅទាំងខាងក្នុងសុទ្ធតែ កខ្វក់ស្មោគគ្រោក, ទោះញើសក្អែល និងទឹកមាត់ ស្លេស្ម កំហាក សំបោរ ដែលហៀរហូរ ដុស ខាក ស្ដោះខ្លួនឯង ខ្លួនក៏ពុំអាចលិទ្ធ លេបវិញឡើយ គឺខ្លួនខ្ពើមឆ្អើមខ្លួនឯង, ចំណង់បើរូបគេដទៃក្រៅពីខ្លួន តើខ្លួនមិនខ្ពើម ឆ្អើមទេឬ? គំនិតនេះជាបន្លាជោះបន្លា គឺជោះយកបន្លា គឺការយល់ឃើញរូបរាងកាយថា ស្អាតថាល្អនោះបាន ព្រោះហេតុនោះទើបសុភាសិតនោះថា* " **បន្លាមុតយក បន្លាជោះ** " ។

*ខាងផ្លូវលោក ដូចជាអាណិកជនណាៗ ដែលសង្កត់ពួកជនអ្នកមានជាតិកំណើតនៅប្រទេសណាមួយ ដោយមុខការរបរផ្សេងៗ មានពាណិជ្ជកម្មជាដើម ឲ្យលូតលាស់ចំរើនមិនរួច គឺឲ្យងើបក្បាលមិនរួច ព្រោះអាណិកជនគេសង្កត់ជាប់ឲ្យទាល់ផ្លូវ ងាប់គំនិត, ការសង្កត់ជាប់បែបនេះហៅថា បន្លាមុត, ត្រូវយកបន្លាជោះ*

បន្លានោះចេញ, តើដោះបែបណា ? ត្រូវយកបន្លាណាដោះ ? ត្រូវយកការដេញដើងជាបន្លាសម្រាប់ដោះ គឺជនអ្នកប្រទេសនេះត្រូវរៀនអក្សរ និងភាសានៃអានិកជននោះឲ្យបានចេះស្ទាត់ជំនាញ ទាំងត្រូវខំប្រឹងរៀន ប្រឹងសង្កេត ឲ្យយល់ជាក់នូវមុខការរបរមានពាណិជ្ជកម្មជាដើមនោះផង, បើពុំអាចចេះទាំងអស់គ្នាពេញទាំងប្រទេសរបស់ខ្លួន ក៏បុរស ស្ត្រី យុវជន យុវតី ត្រូវខំប្រឹងរៀនមែនទែន ឲ្យបានចេះច្រើនអ្នកឡើង ហើយធ្វើការពិសោធមើល, ព្រមទាំងជួយយោងគ្នាផងទៀត គឺ ជួយពន្យល់ណែនាំគ្នាឲ្យចេះកាន់ការតាមលំដាប់ តិច ច្រើន តូច ធំ និយមតាមគ្នាឡើង កុំក្បត់មិត្ត កុំក្បត់សង្គម ឬ សមាគម, ត្រូវយកតម្រាប់រុក្ខជាតិលតាជាតិដែលវាដុះក្នុងព្រៃឈើធំយោងឈើតូច, លតាជាតិលូតវែងតាមដើមឈើយ៉ាងនេះហៅថា យោងគ្នា ។ ការយោងគ្នាបែបនេះ ពុំមែនត្រឹមតែលូតលាស់ខ្ពស់ស្រោងប៉ុណ្ណោះឡើយ, ថែមទាំងនាំឲ្យត្រង់ ថែមទៀត ។ កលោបាយយ៉ាងនេះហៅថា បន្លាមុតយកបន្លាដោះ គឺយកការរៀនអក្សរ និងភាសាជាតិអាណិកជនដែលសង្កត់នោះជា បន្លាដោះបន្លា គឺការសង្កត់ដោយមុខការរបរ មានពាណិជ្ជកម្មជាដើមនោះបាន, បើយកវត្ថុមូលត្រមែលដោះ ប្រាកដជាដោះពុំកើតឡើយ ។ ឯវត្ថុមូលត្រមែលនោះគឺការទម្រន់ដំអក់មិនភ្ញាក់គំនិត មិនគិតប្រឹងរៀនអក្សរ និងភាសាជាតិអាណិកជនដែលប្រើកលល្បិចសង្កត់កនុះឯង ។ គួរប្រាបឲ្យជាក់ច្បាស់ថានេះ ឯងហើយដែលថា បន្លាមុតយកបន្លាដោះ ។ បើអស់លោក - អ្នកវិះរេគិតពិចារណាឲ្យ ដិតដល់ក៏គង់នឹងអាចយល់បាន ។

ឯសេះដាច់ជិះសេះតាមនោះ មានអត្ថន័យផ្សេងគ្នាខ្លះបន្តិចបន្តួចពីបន្លាមុតយកបន្លាដោះ, ដូចជាការខំប្រឹងរៀនទន្ទេញដេញតាមការភ្លេចភ្លាំង មិនចេះចាំស្ទាត់ជំនាញ ទន្ទេញ រំលឹកឲ្យចាំរត់មាត់ស្ទាត់ឡើងវិញ, ឬដូចអ្នកធ្លាប់បានធ្វើសមាធិធម៌ហើយ បែរជាធ្លាក់ចុះសាបសូន្យខានបានទៅវិញ ក៏ខំប្រឹងយ៉ាងម៉ឺងម៉ាត់ប្រតិបត្តិឲ្យសមាធិធម៌នោះកើតមានឡើង ទៀតដូចពីមុន, យ៉ាងនេះហៅថា សេះដាច់ជិះសេះតាម ខាងផ្លូវធម៌ ។ ឯខាងផ្លូវលោក ដូចជា យកទ្រព្យជាទុនផ្តល់បំពេញដេញ

តាមការខាតបង់ ឲ្យមានចំណេញឡើងវិញ ដូចបុរាណភាសិតមួយយ៉ាងផ្សេងទៀតថា " **គសំពៅមិនស្តាយដែក** " ។ល។ ទាំងផ្លូវធម៌ទាំងផ្លូវលោក ដែលគេប្រតិបត្តិបែបនេះហៅថា " **សេះដាច់ជិះសេះតាម** " ។ គួរអស់លោក - អ្នកឧបាយកោសល ត្រិះរិះពិចារណាឲ្យបានដិតដល់ហ្មត់ចត់ឲ្យសុភាសិតនេះ មានអត្ថន័យទូលំទូលាយជាងនេះទៅទៀតផងចុះ ។

## ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៧

បន្លាមុតត្រូវយកបន្លាជួស　　សេះដាច់បោលផ្ដោះជិះសេះតាម
ទ័លក្រត្រូវប្រើក្ដីព្យាយាម　　ដោះភ្លាមទុកស្មើដូចបន្លា ។
បើអាណិកជនណាសង្កត់　　ដោយបទបំភ្លៃគៃបែបណា
ត្រូវរៀនអក្សរនិងភាសា　　នៃអាណិកជននោះឲ្យចេះ ។
ខាងមុខជំនួញតូចនិងធំ　　និយមយកការមានចំណេះ
ទុកដូចបន្លាឬដូចសេះ　　សំរាប់ដោះជិះដោយសេរី ។
យកឈើត្រមែលដោះបន្លា　　ឬឡើងជិះគោជិះក្របី
បោលលោតអន្ទ្រាមហុយតែដី　　ឥតបីដោះបានឬទាន់សេះ ។
ត្រូវរៀនបែបបទពាណិជ្ជផង　　កុំរកស៊ីផ្សងព្រេងឥតចេះ
របរច្រេចភ្នែករៃងរបេះ　　អ្នកឥតចំណេះច្រើនលិចលង់ ។
មុខការរបរគេអ្នកឈ្លាស　　ផុតក្ដីវិនាសច្រើនមានទ្រង់
ពីព្រោះការថ្មើកជួយផ្គត់ផ្គង់　　ជិះជាន់អ្នកល្ងង់ឲ្យដុនដាប ។

*គេក្រោកឈរដើររត់ប៉ផាប់ ចាប់ផ្ចួលសង្កត់ឯងឲ្យក្រាប*
*ផើបក្បាលមិនរួចក្រោកទ្រឹបទ្រាប អ៊ឹកអ៊ាកអាបឡាបភាពទន់ខ្សោយ ។*
*ហេតុនេះត្រូវប្រឹងរៀនវិទ្យា អក្សរភាសាគេកុំធ្លោយ*
*រៀនពាណិជ្ជកម្មកុំបណ្តោយ ឲ្យអាណិកជនសង្កត់ជាប់ ។*
*លុះតែប្រព្រឹត្តតាមបែបនេះ ទើបគេមិនជិះជាន់កែងជាប់*
*មួយយ៉ាងកុំអាងតែទម្លាប់ ជាប់កុនមិនកើតទេត្រូវរាង ។*
*ត្រូវរៀនអក្សរនិងភាសា នៃអាណិកជនឲ្យវៃវាង*
*លុះតែយ៉ាងនេះទើបអ្នកនាង រំលាងដោះយកបន្លាបាន ។*
*ត្រូវទុកវិទ្យាជាបន្លា ដោះយកបន្លាដែលមុតប្រាណ*
*ឬទុកដូចសេះមានកែបអាន ជិះបានពង្រឹតទាន់សេះដាច់ ។*
*ខ្ញុំតែងកាព្យនេះគ្រាន់អ្នកអាន ចង់អានកំសាន្តដោយចាំបាច់*
*គួរអានម្តងៗហើយសំរេច សម្រួលអត្ថន័យតាមគួរចុះ ។៚*

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃសៅរ៍ ទី ២៧ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.វ**



# បុរាណភាសិត

## ត្រុកៗអ្នកស្រុកមើលងាយ រលាស់គូទខ្ចាយ មានឱតមានត័ន្ត

*អត្ថន័យនៃបុរាណភាសិតនេះថា មនុស្សណាមួយ ជាអ្នកមានប្រាជ្ញា យោបល់ និង សំដីថ្វីមាត់ហ្មត់ចត់ ក៏ប៉ុន្តែជាមនុស្សចេះអត់ចេះធន់ មានចិត្តធ្ងន់ធ្ងរ នឹងធឹង គេពុំងាយនឹងជាខឹង ឬប្រើអាការកិរិយាញើមៗ ត្រុកៗ, ពួកជនអ្នកនៅក្នុងស្រុកភូមិផងរបងជាមួយនិងអ្នកនៅភូមិជិតខាងគ្នា ច្រើនតែមានយោបល់យល់ថា អ្នកនោះឯងជាមនុស្សទុយមុយ មិនមែនជាអ្នកអង់អាច រលុះរលាញ ខាងសំដីសំដៅអ្វីទេគ្រាន់តែជាមនុស្ស សុភំសុភាពរាបទាបប៉ុណ្ណោះ, ស្រាប់តែនៅពេលមួយ អ្នកនោះឯងបញ្ចេញសំដីវោហារ ជជែកតវ៉ាក្នុងរឿងអ្វីមួយក្នុងទីប្រជុំមហាជន ដែលមានការជជែកវែកញែក ដោះស្រាយកម្ចាយសំដីដ៏កម្រឲ្យឃើញជាក់ច្បាស់ស្រឡះស្រឡំបាន, ជនទាំងឡាយក៏ដូចជាភ័ន្តភាំង ស្ងើចសរសើរនៅពេលនោះតែម្តង, ក៏លែងមើលងាយរៀងមក ។ ព្រោះហេតុនោះ បានជាមានបុរាណភាសិតថា ៖* **ត្រុកៗអ្នកស្រុកមើលងាយ រលាស់គូទខ្ចាយ មានឱតមានត័ន្ត ។**

*មានបុរាណភាសិតមួយយ៉ាងផ្សេង ប៉ុន្តែមានអត្ថន័យស្រដៀងគ្នាដូចនឹងភាសិតខាង លើដែរថា ៖* **ត្រូវគ្រាប់កុកសាប់ កុំគ្រាប់កុកស** *មានអត្ថន័យថា កុកសាប់មានមាឌតូចបន្តិចជាង កុកស, មានខ្នង ស្លឹកស្លាបសម្បុរត្រសក់ស្រអាប់, កាលបើវាទំលើទ្រនំ, មើលទៅឃើញច្រឡំនឹងស្លឹកឈើ ស្ទើតែមើលមិនឃើញច្បាស់ជាកុកឡើយ ។ ឯកុកស ទោះវាទំលើទ្រនំក្តី វាហើរក្តី ឃើញតែសម្បុរសដូចគ្នា ព្រោះវាមានតែសម្បុរសមួយយ៉ាង ។ អត្ថន័យវែងទាំងនេះ ស្រដៀងគ្នានឹងបុរាណភាសិតខាងលើថា* **ត្រុកៗអ្នកស្រុកមើលងាយ...** *នោះដែរ។ល។*

# ពាក្យកាព្យឲ្យងាយចាំ
# បទកាកគតិ

ឬកពាត្រុកៗ ជននៅក្នុងស្រុក គេច្រើនមើលងាយ
កណ្តាលជំនុំ ស្រាប់តែកម្វាយ កិច្ចកលឧបាយ
មានឱតមានភ័ន្ត ។

បញ្ចេញសំដី មានពាក្យវែងខ្លី រាបទាបស្រទន់
មានឱតញ្ញខ្លាំង ម្តងៗមិនស្លន់ រាល់ម៉ាត់ឥតអន់
សុទ្ធតែបានការ ។

ពុំដែលមានឈ្មោះ ថាខ្លួនអ្នកនោះ ជាគ្រូអាចារ្យ
ឬជាអ្នកចេះ ចំណេះធមិអាថិ សោះទេមានការណ៍
ក៏ចេញប្រាជ្ញប្រុះ ។

ប្រាជ្ញាយង់យល់ សំដីនិម្មល យោបល់ឈ្លាសឆ្លុះ
អ្នកស្តាប់ស្ញប់ស្ញែង ព្រោះឃើញស្តែងនុះ ទម្លាយទម្លុះ
ការក្រសម្វាយ ។

នេះហៅត្រុកៗ ត្រាតែអ្នកស្រុក ភូមិផងមើលងាយ
ស្រាប់តែមានការណ៍ ដែលត្រូវដោះស្រាយ រលាស់គូទខ្លាយ
មានឱតមានភ័ន្ត ។

ឬដូចកុកសាប់ ស្លាបក្រៅស្រអាប់ ឥតសសាន់វុំណ្ណ
កាលបើវាហើរ ឃើញសជាក់ស្បាន់ ចាស់ថាត្រូវកាន់
តម្រាប់កុកសាប់ ។

*វីឯកុកស ទំក៏ឃើញស ឥតឃើញស្រអាប់*
*ហើរក៏ឃើញស ផ្ទុយពីកុកសាប់ ខ្នងស្លាបស្រអាប់*
*នៅពេលដែលទំ ។*

*ហេតុនោះបានជា ពួកចាស់ព្រឹទ្ធា ថាឲ្យនិយម*
*តាមបែបកុកសាប់ ជាការសមរម្យ កុំឲ្យនិយម*
*តាមកុកសឡើយ ។*

*បើសាធុជន វិះរេគិតគុណ យល់ន័យនេះហើយ*
*ពេញចិត្តប្រព្រឹត្ត ពិនិត្យរឿយៗ ប្រើប្លុកជឿយៗ*
*មិនប្រើអំនួត ។*

*ក៏ទៅដោយយ៉ាង ពីព្រោះមានអាង ថាមិនបាច់អួត*
*ចាំដល់នៅពេល ប្រណាំងប្រកួត គង់មានគេអួត*
*ជួសខ្លួនយើងទេ ។៚*

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃចន្ទ្រ ទី២៩ កក្កដា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណា ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**

# ជីវប្បដិជីព

## ការឲ្យពរគ្នាទៅវិញទៅមកនៅវេលាដែលជនម្នាក់កណ្ដាស់ឆែតឡើង , ជនឯទៀតឲ្យពរថា “ ចូរមានអាយុវែង ! ”

មានប្រពៃណីតាំងពីក្នុងបុរាណសម័យព្រេងនាយរៀងមកថា កាលបើជនណាម្នាក់កណ្ដាស់ឆែតឡើង, ជនអ្នកនៅជិតគ្នានោះតែងឲ្យពរទៅអ្នកកណ្ដាស់នោះថា ៖ “ ស្បើយ ! ” ឬថា “ មានអាយុវែង ! ” ឯចំណែកអ្នកដែលកណ្ដាស់ក៏ត្រូវឲ្យពរតបវិញ ដូចគេឲ្យពរមកខ្លួននោះដែរ, នេះជាទម្លាប់របស់ខ្មែរ ។ ឯអ្នកជម្ពូទ្វីប ( ឥណ្ឌា ) មិនឲ្យពរថា៖ “ ស្បើយ ! ” ទេ, គេឲ្យពរថា ៖ “ ចូរមានអាយុវែង ! ” ឬថា ៖ “ ចូរមានអាយុមួយរយ ! ” ជួនកាលថា ៖ “ ចូរមានអាយុមួយរយម្ភៃឆ្នាំ ! ” ។

ក្នុងភគ្គជាតក **ទុកនិបាត** ត្រង់ **ឧឡ្ហវគ្គវណ្ណនា** មាននិទានថា **ជីវ វស្សសតំ ភគ្គាតិ ឥទំ សត្ថា ជេតវនសមីបេ បសេនទិកោសលរញ្ញោ ការិតេ រាជការាមេ វិហរន្តោ អត្តនោ ខិបិតកំ អារព្ភ កថេសិ** ព្រះបរមសាស្ដាទ្រង់គង់នៅក្នុងរាជិការាម ដែលព្រះបាទបសេនទិកោសលទ្រង់មានព្រះរាជបញ្ជាឲ្យកសាងជិតគ្នានឹងវត្តជេតពន, ទ្រង់សំដែងនូវភគ្គ-ជាតក មានបាទគាថា ថា ៖ **ជីវ វស្សតំ ភគ្គ** នេះជាដើម ប្រារព្ធចម្លោះការកណ្ដាស់ឆែតឡើងនៃព្រះអង្គ ។

**ឯកស្មឹ ហិ ទិវសេ** ក្នុងសម័យថ្ងៃមួយ ព្រះបរមសាស្ដាទ្រង់គង់សម្ដែងធម៌កណ្ដាលពុទ្ធបរិស័ទទាំង ៤ គឺ ៖ ភិក្ខុ, ភិក្ខុនី, ឧបាសក, ឧបាសិកា **នារាជិការាម** ជួនជាព្រះអង្គកណ្ដាស់ឆែតឡើង **ភិក្ខូ ភន្តេ ជីវតុ សុគតោតិ ឧច្ចាសទ្ទំ មហាសទ្ទំ អកំសុ** ភិក្ខុទាំងឡាយស្រែកថ្វាយពរព្រះអង្គថា ៖ “ សូមព្រះអង្គមានព្រះជន្ម !, សូមព្រះសុគតមានព្រះជន្ម ! ” ។ ព្រះភគវ័កទ្រង់ត្រាស់សួរថា ៖ ម្នាលភិក្ខុទាំងឡាយ, ចុះកាលបើគេគ្រាន់តែកណ្ដាស់ ហើយមានអ្នកឲ្យពរបែបនេះ តើអ្នកដែលកណ្ដាស់នោះអាចរស់នៅបានយូរ ឬត្រូវតែគេចមិនផុតពីស្លាប់ដែរ ? ពួកភិក្ខុក្រាបទូលថា ៖ **នោ ហេតំ ភន្តេ** ! សូមទ្រង់មេត្តាប្រោស, ពុំមែនដូចពរ

ដែលឲ្យនោះទេ ! ព្រះសម្ពុទ្ធទ្រង់បញ្ញត្តថា ៖ **ន ហិ ភិក្ខ វេ ខិបិតេ ជីវាតិ វត្តព្វំ, យោ វទេយ្យ អាបត្តិ ទុក្កដស្ស** ម្នាលភិក្ខុទាំងឡាយ, កាលបើគេកណ្តាស់, ភិក្ខុមិនត្រូវពោលឲ្យពរគេថា ៖ " ចូររស់នៅ ! " ទេ, ភិក្ខុណាពោល, ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

សម័យមួយក្រោយពីទ្រង់បញ្ញតនោះមក, ពួកភិក្ខុខ្លះកណ្តាស់ដែតឡើង, ពួកគ្រហស្ថគេឲ្យពរថា ៖ **ជីវថ ភន្តេ** ! " មានជន្មាយុវែង ! ទានប្រោស ! " ។ ពួកភិក្ខុទាំងនោះនៅស្ងៀមមិនឲ្យពរតបទៅគេវិញ ។ គ្រហស្ថទាំងអស់នោះគេនិយាយរិះគន់ថា សព្វបើគ្រាន់តែឲ្យពរតបទៅគេវិញប៉ុណ្ណឹងក៏ពួកភិក្ខុមិនចេះថាដែរ ។ លុះព្រះសម្ពុទ្ធទ្រង់បានជ្រាបការណ៍នេះទើបព្រះអង្គទ្រង់អនុញ្ញាតដោយអនុលោមតាមប្រពៃណីនិយមថា ៖ **គិហី ភិក្ខវេ មង្គលិកា, អនុជានាមិ ភិក្ខវេ គិហិនា ជីវថ ភន្តេតិ វុច្ចមានេន ចិរំ ជីវាតិ វត្តុំ** ម្នាលភិក្ខុទាំងឡាយ, ពួកគ្រហស្ថគេតែងតែត្រូវការដោយមង្គល, ម្នាលភិក្ខុទាំងឡាយ, អញតថាគតអនុញ្ញាត, កាលបើគ្រហស្ថគេពោលឲ្យពរថា ៖ " ចូរមានជន្មាយុវែង ទានប្រោស ! ", ភិក្ខុត្រូវពោលឲ្យពរតបទៅគេវិញថា ៖ " ចូរមានអាយុវែង ! " ដូចគេឲ្យពរមកខ្លួននោះចុះ ។

លំដាប់នោះ, ពួកភិក្ខុក្រាបទូលសួរព្រះអង្គថា ៖ **ភន្តេ ជីវប្បដិជីវំ នាម កទា ឧប្បន្នំ** ? សូមទ្រង់ព្រះមេត្តាប្រោស, ចុះការឲ្យពរតបពរវិញថា ៖ " ចូរមានអាយុវែង ! " នេះតើកើតមានពីក្នុងកាលណាមក ? ព្រះសព្វញ្ញូសម្ពុទ្ធទ្រង់ត្រាស់ថា ៖ ម្នាលភិក្ខុទាំងឡាយ, ជីវប្បដិជីព ការឲ្យពរតបពរថា ៖ " ចូរមានអាយុវែង ! " នេះធ្លាប់មានតាំងពីក្នុងបុរាណកាលព្រេងនាយយូរអង្វែងមក ហើយជាប់ជាប្រពៃណីរៀងរហូតមកដល់សម័យសព្វថ្ងៃនេះ ។ ពួកភិក្ខុក្រាបទូលអារាធនា ។ ព្រះអង្គទ្រង់សម្តែងអតីតនិទានថា ៖

ក្នុងអតីតកាល ព្រេងនាយយូរអង្វែងណាស់ទៅហើយ, ព្រះបាទព្រហ្មទត្តសោយរាជ្យគ្រប់គ្រងក្រុងពារាណសីកាសិករដ្ឋ, កាលណោះព្រះពោធិសត្វអន្ទោលយោនយកកំណើតកើតក្នុងត្រកូលព្រាហ្មណ៍មួយក្នុងកសិករដ្ឋនោះឯង ។ បិតារបស់ពោធិសត្វនោះជាអ្នកជំនួញ ។ កាលដែលពោធិសត្វជាបុត្រមានអាយុ ១៦ ឆ្នាំ, ក្នុងសម័យមួយ, បិតាបាននាំទំនិញទៅលក់តាមនិគមជនបទជាមួយនឹងពោធិសត្វជាបុត្រ, បានទៅដល់ទ្វាក្រុងពារាណសី ក្នុងវេលាថ្ងៃល្ងាច

*ទាប, ឈប់ចំអិនអាហារបរិភោគជិតផ្ទះឆ្មាំទ្វារក្រុងនោះ លុះរួចរាល់សព្វគ្រប់ហើយ ក៏សួរឆ្មាំទ្វាររកកន្លែងសំណាក់, ឆ្មាំទ្វារប្រាប់ថា៖ ឥតមានកន្លែងសំរាប់ឲ្យអ្នកដំណើរសំណាក់ទេគេធ្លាប់តែស្នាក់តាមមានតាមបាន, មានសាលាមួយដែរនៅក្រៅក្រុង ប៉ុន្តែសាលានោះមានយក្សបិសាចកាចណាស់នៅគ្រប់គ្រងរក្សា ឥតអ្នកណាមួយហ៊ានស្នាក់ក្នុងសាលានោះទេ, បើអ្នកឯងមិនខ្លាចយក្សបិសាចនោះទេ ទៅស្នាក់នៅសាលានោះចុះ ។ ព្រាហ្មណ៍ជាឪពុកឮឆ្មាំទ្វារនិយាយប្រាប់ដូច្នោះ ក៏នឹកខ្លាចខ្មោចបិសាចនោះ ប៉ុន្តែពោធិសត្វជាកូនប្រុសមិនខ្លាចក៏និយាយថា ៖ ខ្ញុំមិនខ្លាចទេឪ, ទៅ ! យើងទៅស្នាក់សាលាហ្នឹងចុះ ! ឪកុំខ្លាចយក្សបិសាចកំណាចហ្នឹង ! ខ្ញុំនឹងទូន្មានវា ឲ្យវាចូលមកក្រាបជិតបាតជើងឪឲ្យត្រាតែបាន, មកទៅ ! ឪកុំខ្លាច, ឥតបើអីទេ ! ។ ថាហើយក៏នាំគ្នាទៅ ។ លុះទៅដល់សាលានោះហើយ, ព្រាហ្មណ៍ជាឪពុកដេកលើផែនក្តារសាលា, ពោធិសត្វជាកូនអង្គុយច្របាច់ជើងឲ្យអាពុក ។*

*និយាយពីយក្សបិសាច[១] នោះដែលវាបានទៅបម្រើបម្រាស់ ព្រះបាទកុវេរៈវេស្សវ័ណអស់រយៈកាល ១២ ឆ្នាំ, វាបានសាលានោះជាលំនៅ ដោយព្រះបាទវេស្សវ័ណលោកបាលទេវរាជបើកសិទ្ធិឲ្យវាថា បណ្តាមនុស្សទាំងឡាយ, បើមនុស្សណាចូលមកស្នាក់ក្នុងសាលានេះហើយបើមនុស្សម្នាក់កណ្តាស់ឆែតឡើង មនុស្សដែលនៅជិតខាងបានពោលឲ្យពរថា ៖ " ចូរមានអាយុវែង ! " ហើយបើអ្នកដែលកណ្តាស់នោះក៏បានពោលឲ្យពរតបមកវិញថា ៖ " ចូរមានអាយុវែង ! " ដូចគេឲ្យពរដែរ, យ៉ាងនេះ, យក្សបិសាចនោះមិនត្រូវហ៊ានស៊ីគេឡើយ, បើមនុស្សពុំបានឲ្យពរគ្នាទេ, យក្សបិសាចនោះត្រូវមានសិទ្ធិស៊ីគេបាន គឺត្រូវបឺតជញ្ជាក់ឈាមមនុស្សទាំងនោះចុះ ( ចំពោះតែមនុស្សទាំងឡាយណាដែលចូលមកស្នាក់ក្នុងសាលានោះប៉ុណ្ណោះ ក្រៅពីក្នុងសាលានោះ ស៊ីគេពុំបានឡើយ ) ។*

*យក្សបិសាចនោះវានៅលើធ្នឹមសាលា, វាបម្រុងនឹងឲ្យព្រាហ្មណ៍ជាឪពុកពោធិសត្វកណ្តាស់, វាប្រើអានុភាពវាភ្លាម, វារោយកម្ទេចល្អិតផង់ចុះមកឲ្យត្រូវចំច្រមុះព្រាហ្មណ៍នោះ,*

---

*(១) យក្ស ឬ យក្ខ ស្រីជា យក្សិណី ឬ យក្ខិណី ប្រែថា " អទិស្សមានកាយដែលមនុស្សគេខ្លាច គេតែងតែបូជា " ជានាមនៃ ទេពតា ភូត បិសាចទាំងពួង ។ ក្នុងទីនេះខ្ញុំហៅថា យក្សបិសាច ឲ្យងាយយល់ ។*

គាត់ក៏កណ្តាស់ឆែតឡើង, ពោធិសត្វជាកូនអង្គុយស្ងៀមមិនពោលឲ្យពរឪពុកថា ៖ " ចូរមានអាយុវែងឡើយ ! " ។ យក្សបិសាចនោះវាចុះពីធ្នឹមសាលាមក ដោយវាសម្តែងខ្លួនឲ្យពោធិសត្វមើលឃើញ, វានឹងចាប់ស៊ី ។ ពោធិសត្វដឹងទាន់ភ្លាមថា យក្សបិសាចនេះវាធ្វើឲ្យឪពុកអញគាត់កណ្តាស់, ហើយអញពុំបានឲ្យពរគាត់ថា ៖ " ចូរមានអាយុវែង ! " ដូច្នេះហើយវានឹងស៊ីអញទេដឹង ? ពោធិសត្វគិតឃើញភ្លាមក៏ឲ្យពរទៅអាពុកថា ៖

**ជីវ វស្សសតំ ភគ្គ** **អបរានិ ច វីសតិ**
**មា មំ បិសាចា ខាទន្តុ** **ជីវ ត្វំ សរទោសតំ** !

" ភគ្គៈ(១) , ចូរមានអាយុមួយរយឆ្នាំ ផ្សំថ្កៃថែមទៀតជា ១២០ ឆ្នាំ ! បិសាចចូរកុំស៊ីអញឡើយ ! ឪ, ចូររស់នៅជាងមួយរយឆ្នាំចុះ ! "

លុះយក្សបិសាចនោះ បានឮសម្តីពោធិសត្វឲ្យពរអាពុកដូច្នេះហើយ ក៏ពុំហ៊ានស៊ីពោធិសត្វឡើយ, វាគិតថា ៖ " អញស៊ីវានេះពុំបានឡើយ ! អញត្រូវស៊ីអាពុកវាវិញ " ។ វាគិតហើយ ក៏រោយផង់ល្អិតចុះមកម្តងទៀតឲ្យត្រូវចំច្រមុះពោធិសត្វ ។ ពោធិសត្វបានឃើញអំពើរបស់វាក៏ប្រុងខ្លួន, រំពេចនោះក៏កណ្តាស់ឆែតឡើង ។ ព្រាហ្មណ៍ជាអាពុកយល់ច្បាស់ថា បើអញមិនឲ្យពរទេ បិសាចនេះនឹងស៊ីឥឡូវនេះពុំខាន ។ គិតឃើញភ្លាមក៏ឲ្យពរទៅកូនថា ៖

**ត្វម្បិ វស្សសតំ ជីវ** **អបរានិ ច វីសតិ**
**វិសំ បិសាចាខាទន្តុ** **ជីវ ត្វំ សរទោសតំ** !

" ចូរកូនឯងក៏មានអាយុមួយរយឆ្នាំដែរ ផ្សំថ្កៃថែមទៀតជា ១២០ ឆ្នាំ ! បិសាចចូរស៊ីថ្នាំពិសចុះ ! កូនឯងចូររស់នៅជាងមួយរយឆ្នាំចុះ ! "

**យក្ខោ តស្ស វចនំ សុត្វា** យក្សបិសាចបានឮសម្តីពោធិសត្វហើយក៏គិតឃើញថា ៖ **ឧភោបិ មេ ន សក្កា ខាទិតុំ** អញមិនអាចស៊ីវាទាំងពីរអ្នកនេះទេ, គិតឃើញហើយក៏ឡើងទៅនៅលើធ្នឹមសាលាវិញ ។ **អថ នំ ពោធិសត្តោ បុច្ឆិ** លំដាប់នោះ ពោធិសត្វសួរយក្សបិសាចនោះថា ៖ **ភោ យក្ខ, កស្មា ឥមំ សាលំ បវិដ្ឋមនុស្សេ ខាទសិ** ? នៃយក្សបិសាច, ហេតុអ្វីបានជាអ្នកឯងស៊ីមនុស្សទាំងឡាយដែលចូលមកកាន់សាលានេះ ? យក្សបិសាចឆ្លើយ

(១)ពាក្យថា "ភគ្គៈ" នេះជាឈ្មោះនៃបិតា គឺពោធិសត្វពោលចេញឈ្មោះបិតារបស់ខ្លួន ដូចជាពាក្យថា "ឪ" ដែរ ។

ថា ៖ **ទ្វាទសវស្សានិ វេស្សវណំ ឧបដ្ឋហិត្វា លទ្ធត្ថា** ខ្ញុំបានសិទ្ធិនេះ ពីព្រោះខ្ញុំបានទៅបម្រើបម្រាស់ព្រះបាទវេស្សវ័ណអស់រយៈកាល ១២ ឆ្នាំ គឺព្រះបាទវេស្សវ័ណបានបើកអំណាចឲ្យខ្ញុំ ។ ពោធិសត្វ សួរថា៖ **កឹ បន សព្វេ ខាទិតុំ លភសិ** ? ចុះអ្នកឯងត្រូវបានស៊ីមនុស្សទាំងអស់ តាមតែអ្នកណាក៏ដោយឬ ? យក្សបិសាចឆ្លើយថា ៖ **ជីវប្បដិជីវភាណិ នោ ឋបេត្វា អវសេសេ ខាទាមិ** លើកលែងតែមនុស្សទាំងឡាយដែលចេះពោលពាក្យឲ្យពរគ្នាទៅវិញទៅមក ( នៅពេលដែលកណ្តាស់ ) ថា ៖ " ចូរមានអាយុវែង ! " ឯមនុស្សក្រៅពីនោះខ្ញុំត្រូវស៊ី[១], ( បីតជញ្ជាក់ត្រឹមតែឈាម ) ។

ពោធិសត្វបានទូន្មានយក្សបិសាចនោះថា៖ " នែយក្ស, កាលពីជាតិមុន អ្នកឯងបានធ្វើអកុសល កម្មដ៏លាមកអាក្រក់បានជាអ្នកឯងមកចាប់កំណើតជាយក្សបិសាចកាច ឃោរឃៅអាក្រក់យ៉ាងនេះ, ឥឡូវនេះ អ្នកឯងទទួចធ្វើកម្មអាក្រក់នោះតទៅទៀត **តមោ តមបរាយនោ ភវិស្សសិ** អ្នកឯងឈ្មោះថាសត្វងងឹត ប្រព្រឹត្តទៅខាងងងឹតសូន្យសុង, នែយក្ស, ព្រោះហេតុនោះ, ចាប់តាំងពីថ្ងៃនេះតទៅ អ្នកឯងចូរវៀរចាកអំពើអាក្រក់ មានបាណាតិបាតកម្មជាដើមឲ្យជ្រះស្រឡះចេញ ។ លុះពោធិសត្វទូន្មានយ៉ាងនេះហើយ ក៏គំរាមយក្សបិសាចឲ្យឃើញភ័យក្នុងនរកជាក់ស្តែង ញ៉ាំងយក្សបិសាចឲ្យទទួលកាន់សីល ៥ ហើយញ៉ាំងយក្សបិសាចឲ្យទទួលចុះចូលប្រគល់ខ្លួនធ្វើដូចជាអ្នកបម្រើបម្រាស់ គឺជាអ្នកជួយទំនុកបម្រុងតរៀងទៅ ។

---

(១) យក្ស-បិសាច ទោះនៅលើទីគោកដែលគេតែងហៅថា បិសាចព្រៃ ឬ អារក្សព្រៃ ឬ ក៏ខ្មោចព្រៃនោះក្តី ទោះនៅទីទឹកដែលគេហៅថា បិសាចទឹក ឬ អារក្សទឹកឬក៏ខ្មោចទឹកនោះក្តី សុទ្ធតែនៅក្រោមអំណាចនៃព្រះបាទកុវេរៈ ដែលហៅថាព្រះបាទវេស្សវ័ណព្រោះជាម្ចាស់ក្រុងវិស្សាណា ជាលោកបាលមហារាជនៅទិសឧត្តរនៃភ្នំសិនេរុក្នុងមហារាជិកសួគ៌ កាលបើយក្ស-បិសាចដែលព្រះបាទវេស្សវ័ណបានបើកសិទ្ធិអំណាចឲ្យ ត្រង់ទីមានកម្រិតត្រឹមណា អាចបៀតបៀនមនុស្ស ឬ សត្វតិរច្ឆានបានចំពោះតែត្រង់ទីត្រឹមណោះ ហួសពីកម្រិតនោះសូម្បីតែត្រឹមមួយឆ្នាប់ក៏ពុំអាចបៀតបៀនគេបានឡើយដោយដាច់ខាត, សឹងមានរឿងតំណាលប្រាប់ច្រើនអន្លើក្នុងគម្ពីរជាតកផ្សេងៗ ។ ដោយហេតុនេះឯង បានជាបណ្ឌិតទាំងឡាយតែងតែចៀសចាកភយន្តរាយមិនឲ្យយក្ស-បិសាចទាំងនោះបៀតបៀនបាន ដូចរឿងនិទានក្នុងភគ្គជាតកនេះជានិទស្សនៈគឺជាឧទាហរណ៍ស្រាប់ ។ គួរតែសាធុជនពិចារណាមើលដោយវិចារណប្បញ្ញាដ៏ល្អិតល្អន់ផងចុះ ។ បើយល់ថាពិតដូចរឿង ទាំងនោះមែន, គួរតែប្រយ័ត្នកុំឲ្យពួកយក្ស-បិសាចវាធ្វើទុក្ខបានគឺ ត្រូវប្រយ័ត្នព្រៃ និងកំពង់យកជើងកប ។

**បុន ទិវសេ សញ្ចរន្តា មនុស្សា** លុះដល់ថ្ងៃស្អែកឡើង, មនុស្សទាំងឡាយដែលសញ្ចារទៅមកត្រង់ទីនោះ បានដឹងការណ៍នោះជាក់ប្រាកដ, បានដឹងឮតៗគ្នាពីមួយទៅមួយហើយ អ្នកខ្លះក៏ចូលទៅក្រាបទូលព្រះរាជា, លុះស្តេចទ្រង់ជ្រាបរឿងនេះសព្វគ្រប់ហើយ ព្រះអង្គមានព្រះរាជតម្រាស់ឲ្យ ហៅព្រាហ្មណ៍ជាអាពុកនិងពោធិសត្វជាកូនចូលមកគាល់, ទ្រង់បញ្ជាក់បានជ្រាបការណ៍សព្វគ្រប់ហើយ ស្តេចពេញព្រះរាជហឬទ័យណាស់ ដោយព្រះអង្គជ្រាបមកយូរហើយថា យក្សបិសាចនោះវាបៀតបៀនមនុស្សដែលមកស្នាក់ក្នុងសាលា នោះឲ្យវិនាសអន្តរាយជីវិតច្រើនណាស់ហើយ, ព្រះអង្គក៏បានប្រទានឲ្យពោធិសត្វមានយសស័ក្តិជាសេនាបតី, ទ្រង់ប្រោសព្រះរាជទានទ្រព្យសម្បត្តិយសបរិវារដល់ព្រាហ្មណ៍ជាបិតានៃពោធិសត្វនោះផង ដោយសារគុណានុភាពនៃពោធិសត្វជាបុត្រដែលបានទូន្មានយក្សបិសាចនោះឲ្យស្លូតតទៅ ។

ព្រះរាជាបានតាំងយក្សបិសាចនោះឲ្យមានឋានៈជាពលិប្បដិគ្គាហក គឺឲ្យជាអទិស្សមានកាយអ្នកទទួលពលិការអំពីមនុស្សទាំងឡាយ, ឲ្យជាអ្នកជួយទំនុកបម្រុងកាសិករដ្ឋឲ្យបានសុខសប្បាយតរៀងទៅ ។ ព្រះមហាក្សត្រិយ៍អង្គនេះទ្រង់ឋិតនៅក្នុងឱវាទ គឺជឿស្តាប់ពោធិសត្វជាសេនាបតី ទ្រង់បំពេញការកុសលមានទានជាដើម ដរាបដល់ព្រះអង្គបាននូវសគ្គបទ គឺផ្លូវនៃឋានសួគ៌ ក្នុងអវសានកាលនៃព្រះជន្មាយុ ។

**សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា ជីវប្បដិជីវន្តា តស្មឹ កាលេ ឧប្បន្នន្តិ វត្វា ជាតកំ សមោធានេសិ** ព្រះសម្ពុទ្ធជាបរមសាស្តាទ្រង់សម្តែងព្រះធម៌ទេសនានេះហើយ ព្រះអង្គបញ្ជាក់សេចក្តីថា ៖ " **ជីវប្បដិជីព** " កើតមានតាំងពីក្នុងកាលណោះមក, ហើយព្រះអង្គភ្ជាប់ជាតកថា ៖ **តទា រាជា អានន្ទោ អហោសិ, បិតា កស្សបោ, បុត្តោ បន អហមេវ** ព្រះរាជាក្នុងកាលណោះចេរវិលវិលអន្ទោលជាតិមក កើតជាអានន្ទ, ព្រាហ្មណ៍ជាបិតា ( នៃពោធិសត្វ ) អន្ទោលជាតិមកកើតជាមហាកស្សប, ឯបុត្រ ( នៃព្រាហ្មណ៍នោះ ) គឺអញតថាគតនេះឯង ។

**គគ្គជាតកំ និដ្ឋិតំ**

គគ្គជាតកចប់តែប៉ុណ្ណោះ ៕

# បរិយាយបញ្ចាក់ថែម

*រឿងក្នុងសាស្ត្រាល្បែង ឬ រឿងប្រលោមលោក ជារឿងប្រតិដ្ឋប្រដូចសម្រាប់អានកំសាន្តសប្បាយ ឬ រាំល្ខោនដែលគេស្នាច់រូបមុខហៅថា " មុខយក្ស " មានសណ្ឋានខុសពីមុខមនុស្ស និងមុខទេពតាឆ្ងាយណាស់ ឯតាមការពិតមិនមែនដូច្នោះទេ, ពាក្យថា " យក្សឬយក្ខ " នេះសំស្ក្រឹតនិងបាលីប្រែមកពីប្រភពដើមថា "* **យជ** *" ប្រើជា " បូជា, កោតខ្លាច, គោរព " សម្រេចរូបជានាម នាមជាយក្ខឬយក្ស ប្រែថា ៖ " អទិស្សមាន-កាយ ដែលគេកោតខ្លាច, គេ គោរពបូជា, គេបន់ស្រន់, គេសែនព្រេន " មានអត្ថន័យថា ៖ អមនុស្សឬ អទិស្សមានកាយ ដែលកើតក្នុងរូបភព មានរូបកាយដែរប៉ុន្តែល្អិតណាស់ មនុស្សយើងមើលពុំឃើញ បើគេចង់ឲ្យយើងឃើញ មនុស្សយើងក៏អាចមើលឃើញដែរ ជាពិសេសម្ដងៗ ឬឮតែសំឡេងមិនឃើញរូប ក៏មានដែរ ។ ភូតបិសាច, អសុរកាយ, ភុម្មទេវតា, រុក្ខទេវតា, វត្ថុទេវតា, សមុទ្ទទេវតា, ទេវតារក្សា មហាស្វេតច្ឆត្រ...ទោះទាំងព្រះឥន្ទ និងទេវតាទាំងអស់ដែលនៅក្នុងឋានសួគ៌ បើហៅដោយរួបរួមជាយក្ខ ឬ យក្សដូចគ្នា មិនមែនមានរូបរាងដូចយើងធ្លាប់ចំណាំនោះឡើយ ។*

*ក្នុងគម្ពីរនានាខាងព្រះពុទ្ធ ទោះព្រះត្រៃបិដកក្តី អដ្ឋកថាក្តី ជាតកជាដើមក្តីមាននិយាយពីយក្ខនេះច្រើនអន្លើណាស់ ។ ក្នុងមហាបរិនិព្វានសូត្រ មានតំណាលថា ៖ នៅពេល ដែលព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ផ្ទំលើបរិនិព្វានមញ្ចាសនៈ គឺលើគ្រែផ្ទំបរិនិព្វាន, ឧបវាណា ភិក្ខុកំពុងបក់តិចៗថ្វាយ, ព្រះអង្គមានព្រះបញ្ជាឲ្យថយចេញដោយអាការហាក់ដូចជា បណ្ដេញឲ្យចេញពីទីជិតព្រះអង្គ, ព្រះមហាអានន្ទក្រាបបង្គំទូលសួរហេតុនោះ, ព្រះអង្គត្រាស់ថា ៖ ឧបវាណាភិក្ខុឥតមានកំហុសអ្វីក្នុងការបក់នេះទេ ប៉ុន្តែមានពួកទេវតាច្រើនណាស់ ណែនណាន់តាន់តាប់ និមិតខ្លួនតូចៗ*

ឈរប្រជ្រៀតគ្នា ងើតមើលរូបកាយអញតថាគតជា បច្ឆិមទស្សនៈឃើញចុងក្រោយបំផុត, ឧបវាណាភិក្ខុអង្គុយបក់បាំងភ្នែកពួកទេវតា នាំឲ្យទាស់អធ្យាស្រ័យគេ, អញតថាគតត្រូវការឲ្យទីជិតនេះស្រឡះស្រឡំ បើកឱកាសឲ្យពួកទេវតាគេឃើញអញតថាគតច្បាស់ចុះដ្បិតអំណើះពីថ្ងៃនេះទៅ គេលែងបានឃើញអញតថាគតទៀតហើយ ! ។ល។ យើងជាពុទ្ធសាសនិក ដែលមានគារវភាពចំពោះព្រះអង្គ, កាលបើនឹកឃើញរឿងនេះ ក៏រែងមានចិត្តអាណោចលន្លោចដោយនឹកស្ដាយអាល័យព្រះអង្គ ! ។

នៅទីបញ្ចប់នេះ, សុំបញ្ជាក់ថា អំពីពាក្យថា ៖ យក្ស ឬយក្ខ, យក្សិណី ឬយក្ខិណី " យក្សប្រុស, យក្សស្រី " នេះអស់លោក - អ្នកអានដែលពុំធ្លាប់គិត ឬដែលធ្លាប់បានគិតដែរ ប៉ុន្តែមានយោបល់ត្រឹមតែយក្សល្ខោននោះ គួរប្រើវិចារណប្បញ្ញាឲ្យប្រព្រឹត្តទៅតាមន័យដែល បានពោលហើយអំពីពាក្យថា " យក្ខ " ជាសាធារណនាមនៃអភិស្សមានកាយទូទៅនោះចុះ ៕

**-ចប់-**

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យ ទី២០ តុលា ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្ដេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# សេវនាសេវនតា

## " ការគួរសេពគប់និងមិនគួរសេពគប់ "

## ព្រះបរមពុទ្ធោវាទ

**អសេវនា ច ពាលា នំ** *កុំសេពគប់ពួកជនពាល*, **បណ្ឌិតានញ្ច សេវនា** *គួរសេពគប់ពួកជនជាបណ្ឌិត ។ ពាក្យថា "* **ពាល** *" មានប្រភពដើមថា* **ទ្វិ** " **ពីរ** " *និង* **លុ** " **កាត់** ", *ផ្លាស់* **ទ្វិ** *ជា* **ពា**, *ផ្លាស់* **ល** *ជា* **ឡ** *ផ្សំជា* **ពាល** *ប្រែថា " អ្នកកាន់ប្រយោជន៍ពីរ គឺប្រយោជន៍ខ្លួនឯងនិងប្រយោជន៍អ្នកដទៃ, ឬ ប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍បរលោក " ។* **ពាល** *បើជាគុណបទប្រែថា " ក្មេង, ទន់, ល្ងង់ " ។ ពាក្យថា* **បណ្ឌិត** *មានប្រភពដើមថា* **បឌិ** *ចេញមកជា* **បណ្ឌា** *ប្រែថា " ប្រាជ្ញារក្សាខ្លួនឲ្យគេចចៀសវាង ផុតចាកទុច្ចរិត " ផ្សំជាមួយនឹង* **ឥត** ( **បច្ច័យ** ) *សម្រេចរូបជា* **បណ្ឌិត** *ប្រែថា " អ្នកមានប្រាជ្ញារក្សាខ្លួនឲ្យគេចចៀសវាងផុតចាកទុច្ចរិត គឺអ្នកកាន់សុចរិតខ្ជាប់ខ្ជួន ", ប្រែឲ្យខ្លីថា " អ្នកប្រាជ្ញ គឺអ្នកមានគំនិត ប្រាជ្ញាយល់ខុសត្រូវព្រមទាំងប្រព្រឹត្តកាន់សុចរិតយុត្តិធម៌ខ្ជាប់ខ្ជួនផង " ។ ផ្ទុយគ្នានឹងពាក្យថា* **ពាល** *។ បណ្តាពាក្យទាំងពីរនេះ, បុព្វបុរសពុទ្ធសាសនិកខ្មែរយើងនិយមប្រើពាក្យ* **ពាល** *ថាអ្នកល្ងង់ខ្លៅ, ប្រើពាក្យ* **បណ្ឌិត** *ថាអ្នកចេះដឹង, ដោយហេតុនេះបានជាបព្វជិតពុទ្ធសាសនិកដែលលាចាកផ្នួស ទើបនឹងសឹកថ្មីៗ គេហៅថា* **បណ្ឌិត** *ហៅឃ្លាតមកថា* **អន្ទិត** ( *ស្រដៀងនឹងសម្តីប្រាក្រឹតនៅប្រទេសឥណ្ឌា* ), *បានជាគេហៅយ៉ាងនេះ ព្រោះគេយល់ថា " អ្នកត្រឹមត្រូវ, អ្នកចេះដឹង, អ្នកហ្មត់ចត់ដ្បិតទើបនឹងលាចេញមក ពីវត្តអារាមដែលជាកន្លែងហ្មត់ចត់ ទាំងកំពុងប្រព្រឹត្តសុចរិត ខ្ជាប់ខ្ជួនផង "* ( *ពិតឬពុំពិតដូចគេហៅនោះ ជានាទីរបស់អ្នកទើបនឹងសឹកនោះឯង, គួរណាស់តែប្រព្រឹត្តធម៌កាន់សីលឲ្យបានហ្មត់ចត់ខ្ជាប់ខ្ជួនតរៀងទៅ កុំឲ្យអ្នកផងគេរិះគន់និន្ទាខ្លួនបាន, កុំឲ្យចុះក្នុងតម្រាថា " អន្ទិតគោលោត ឲ្យស្រីបញ្ឆោត អស់ពោតមួយចម្ការ " ដែលមានរឿងដំណាលថា សឹកមកដាំពោត, មានស្រីម្នាក់បញ្ឆោតទិញពោតជឿ, តមក, ឥតបានសងថ្លៃពោតទាល់តែសោះ, កើតទុក្ខ សំកុកសម្កុល, ខ្មាសគេសន្ធឹក* ) ។

# ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៧

| | | |
|---|---|---|
| គប់ពាលរឹងរាលទៅរកខុស | គប់ប្រាជ្ញស្រីប្រុសរឹងបានត្រូវ | |
| គប់មិត្រអបលក្សណ៍រឹងអាស្រូវ | ខុសត្រូវមានព្រោះការសេពគប់ | ។ |
| គួរជ្រើសរើសរកជនប្រុសស្រី | តើមានធម៌អ្វីជាប្រភព | |
| បើឃើញច្បាស់ហើយសឹមសេពគប់ | ឬត្រូវតែឈប់កុំរវល់ | ។ |
| បើតាមឱវាទព្រះសម្ពុទ្ធ | វិសុទ្ធទ្រង់ធម៌និរមល | |
| គួរដឹងថាបើឃើញបុគ្គល | យល់ខុសពុំគួរសេពគប់ឡើយ | ។ |
| សូវនៅម្នាក់ឯងប្រសើរជាង | ត្រូវតែចៀសវាងជនតោះតើយ | |
| មិនកាន់តាមធម៌ជាកោះត្រើយ | ព្រងើយដោយយល់ថាខ្លួនត្រូវ | ។ |
| មកពីច្រឡំភ័ន្តគំនិត | ភ្លាត់គិតបែរយល់ព្រៃជាផ្លូវ | |
| យកធម៌សុចរិតជាសត្រូវ | ក្រឡូវតម្កើងឯទុច្ចរិត | ។ |
| ផ្ទុយទេខុសទេគួរបោះបង់ | គួរខំផ្ចិតផ្ចង់កាន់សុចរិត | |
| កុំអាងថាស្រេចតែដឹងចិត្ត | គួរតែអាណិតខ្លួនទើបសម | ។ |
| ព្រោះការសេពគប់នេះសំខាន់ | ប្រយ័ត្នកុំភ័ន្តកុំច្រឡំ | |
| គប់ពាលបានពាលមិនបាច់ខំ | ដូចគេវាយដំឲ្យសន្លប់ | ។ |
| គប់មិត្របណ្ឌិតបានបណ្ឌិត | គំនិតត្រឹមត្រង់អាចបញ្ចប់ | |
| ឧបទ្រពចង្រៃឲ្យរម្ងាប់ | សុខស្ងប់អាចកើតមានឯងៗ | ។ |
| ព្រះសព្វញ្ញូទ្រង់ត្រាស់ថា | ជនណាជាមនុស្សពាលជាក់ស្ដែង | |
| ស្រាប់តែភ្ញាក់ខ្លួនថាអញឯង | ជាពាលក្រៃលែងទៅហើយតើ | ។ |
| ជននោះបានឈ្មោះថាបណ្ឌិត | ព្រោះភ្ញាក់គំនិតដោយអើពើ | |
| នឹងអាចញ៉ាំងខ្លួនឲ្យបានរើ | គំនិតសើរើឲ្យឃ្លាតឆ្ងាយ | ។ |

ផ្ទុយគ្នាស្រឡះពីជនពាល ពង្រីកពង្រាលផ្លូវអបាយ
ប្រមុខនៃទុក្ខភយន្តរាយ កម្ចាយសុខស្ងប់ឲ្យសាបសូន្យ ។
ឥតភ្ញាក់ខ្លួនសោះរឹតតែរឹត ឥតគិតអាណិតប្រពន្ធកូន
ទោះបីមិត្តភក្តិនិងបងប្អូន ទូន្មានរំលឹកក៏លែងកើត ។
ជននោះឈ្មោះថាមហាពាល ពេញសិប់ជាពាលត្បូងកឆើត
គួរសាធុជនកុំឈមអើត មិនកើតទេគុណាក្លាយជាទោស ។
គួរចៀសដូចចៀសផ្លូវរអិល ខ្វិចខ្វិលយ៉ាងណាដោយសន្តោស
កុំឈ្លោះប្រកាន់ឲ្យរឱស ក្រែងទោសនឹងមានព្រោះធ្វើគុណ។
អហំ **ជ.ណ. ជោតញ្ញាណោ** មានក្តីគោរពព្រះមានបុណ្យ
ពេលដែលខ្លួនចាស់កាន់តែស៊ុន ជីពជន្មគម្រប់ប៉ែតសិបប្រាំ ។
ភ្នកនឹកដល់ពុទ្ធភាសិត ថារូបយើងពិតជាមិនទ្រាំ
ដល់រយឆ្នាំទេរែងខ្ទេចខ្ទាំ ពុំទ្រាំរស់នៅតាមចង់ឡើយ ។
រូបបាត់សូន្យទៅនាមគង់នៅ ដោយសារចិត្តដៅពុំតោះតើយ
ប្រឹងកសាងកេរ្តិ៍ពុំព្រងើយ ខ្លួនបាត់ទៅហើយកេរ្តិ៍គង់នៅ ។
ហេតុនេះ **អ ហំ** រែងខំប្រឹង ទោះខ្លួនចាស់ម្ល៉ឹងមិនសៅដៅ
ធ្វើនេះរួចធ្វើនោះទៀតទៅ មិននៅយកស្រួលដោយទម្រន់ ។
មិនព្រមទម្រើសខ្លួនឲ្យធ្លាប់ តាំងចិត្តមាំខ្ជាប់ដោយគិតគណន៍
ឃើញថាករណីយ៍ទោះស្រាលធ្ងន់ កម្រពេកពន់ក៏ត្រូវប្រឹង ។
សមដូចភាសិតចែងប្រាប់ថា រូបតែងជរាមិនរឹងប៉ឹង
ប៉ុន្តែរូបកុំដេកសម្លឹង រង់ចាំតែពេលអស់ជីវិត ។
កិច្ចការខ្លះធ្វើបានដោយកាយ ខ្លះដោយវាចានិងចិត្តគិត
ទោះខ្លួនចាស់ត្រូវប្រឹងប្រព្រឹត្ត កុំគិតដេកចាំតែពេលស្លាប់ ។

ធ្វើទៅស្តីទៅគិតឲ្យសព្វ　　ការអ្វីគួរគាប់ត្រូវកាន់កាប់
ប្រយ័ត្នកុំឲ្យតែខុសច្បាប់　　បើច្បាប់បើកផ្លូវត្រូវប្រឹងធ្វើ ។
ប្រយ័ត្នមួយយ៉ាងកុំឲ្យប៉ះ　　ប្រទះត្រូវចំលើអំពើ
ជាកម្មអកុសលកុំខ្វល់ធ្វើ　　ព្រោះកាលបើធ្វើវែងបានទុក្ខ ។
កុំឃើញត្រឹមតែបច្ចុប្បន្ន　　ប្រយ័ត្នក្រែងភ័ន្តទៅខាងមុខ
កុំយល់ថាចេះតែបានសុខ　　ស្រណុកស្រណានគ្មានទុក្ខឡើយ ។
បានសុខត្រូវនឹកដល់ទុក្ខផង　　គិតឲ្យហ្មត់ហ្មងកុំតោះតើយ
សុខទុក្ខក្រវែលគ្នាឥតស្បើយ　　ល្ហើយត្រឹមប៉ុណ្ណឹងចុះចប់ហោង ។៚

**វត្តខុណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យ ទី ១ ធ្នូ ព.ស. ២៥១២ គ.ស ១៩៦៨**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# ទសពិធរាជធម៌ ១០

*ធម៌ ១០ យ៉ាងសម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងទ្រង់ណែនាំប្រជាពលនិករឲ្យប្រព្រឹត្តតាមលំអានព្រះអង្គផងហៅថា ទសពិធរាជធម៌ គឺ៖*

**១. ទាន** *ការធ្វើអំណោយ ;*

**២. សីល** *ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ (* **អតិរេកសីល** *) មួយផង មួយកាល ;*

**៣. បរិច្ចាគៈ** *ការចំណាយរាជទ្រព្យទំនុកបំរុងប្រទេសជាតិ ;*

**៤. អាជ្ជវៈ** *មានសេចក្តីត្រង់ ;*

**៥. មទ្ទវៈ** *មានសេចក្តីទន់ភ្លន់សុភំសុភាព ;*

**៦. តបៈ** *ការកាន់ឧបោសថសីល តាមកាលកំណត់ម្តងៗ ;*

**៧. អក្កោធនៈ** *មិនកម្ហៅក្រហាយអ្នកដទៃ ;*

**៨. អវិហឹសា** *មិនបៀតបៀនអ្នកដទៃ ;*

**៩. ខន្តី** *មានសេចក្តីអត់ធន់ ;*

**១០. អវិរោធនៈ** *មិនបំពានលើធម៌ លើច្បាប់ ; កាលបើប្រើក្នុងកាព្យមិនបាច់ប្រើយុគលពិន្ទុ ( ះ ) នេះក៏បាន តាមសម្ផស្សដែលកាព្យត្រូវចាប់ចួនគ្នា ។*

## ពាក្យកាព្យឲ្យងាយចាំ
## បទពាក្យ ៧

*ទសពិធរាជធម៌ដប់ ពីដើមដល់ចប់មានសេចក្តី*
*ដូចតទៅនេះជនប្រុសស្រី គប្បីចងចាំគ្រប់ៗគ្នា ។*
*ទីមួយបាលីហៅថាទាន អ្នកមានសទ្ធាគួរជ្រះថ្លា*
*សង្គ្រោះឆ្លោះជនអនាថា ទ័លក្រវេទនាឥតពំនាក់ ។*

| | |
|---|---|
| ទីពីរបាលីហៅថាសីល | ត្រូវកាន់កុំខ្ជិលមានប្រាំថ្នាក់ |
| គឺសីលទាំងប្រាំដែលមានជាក់ | ក្នុងច្បាប់ពុទ្ធចក្រនោះស្រេចស្រាប់។ |
| ទីបីបាលីហៅបរិច្ចាគ | លំបាកបន្តិចត្រង់លះទ្រព្យ |
| ចំណាយធ្វើការដែលគួរគាប់ | សម្រាប់ប្រទេសជាតិសាស្នា ។ |
| ទីបួនបាលីហៅអាជ្ជវៈ | មានវិគ្គហៈថាចិត្តជា |
| ទៀងត្រង់ទាំងកាយទាំងវាចា | ទាំងចិត្តអាត្មាក៏ស្មោះត្រង់ ។ |
| ទីប្រាំបាលីហៅមទ្ទវៈ | ដែលមានវិគ្គហៈថាផ្ចិតផ្ចង់ |
| ត្រៃទ្វារទន់ភ្លន់សមចំណង់ | នៃជនទាំងសង្ឃទាំងគ្រហស្ថ ។ |
| ប្រាំមួយបាលីហៅតបៈ | ដែលមានវិគ្គហៈថាជំទាស់ |
| នឹងកាមារម្មណ៍គ្រប់ទាំងអស់ | កម្តៅចិត្តស្រស់ឲ្យស្ងួតស្ងប់ ។ |
| ប្រាំពីរហៅអក្កោធនៈ | ដែលមានវិគ្គហៈថារម្ងាប់ |
| ក្តីក្រោធច្រឡោតឲ្យឆាប់ចប់ | កំហឹងសន្លប់ស្ងប់ភ្លាមៗ ។ |
| ប្រាំបីហៅអវិហឹសា | បិទកាយវាចាដោយចិត្តហាម |
| មិនឲ្យបៀតបៀនសព្វសត្វតាម | ទម្លាប់នៃចិត្តឥតមេត្តា ។ |
| ប្រាំបួនមានឈ្មោះថាខន្តី | ដែលមានសេចក្តីថាចិន្តា |
| ប៉ុនអត់ប៉ុនធន់ទោះម្តេចម្តា | ប្រើកាយវាចាចិត្តធន់ទ្រាំ ។ |
| ទីដប់អវិរោធនៈ | វិគ្គហៈថាទោះទោសជោគជាំ |
| កាន់ធម៌កាន់ច្បាប់ស៊ប់មែនមាំ | ប៉ុនទ្រាំពុំហ៊ានរំលោភច្បាប់ ។ |
| រីធម៌ទាំងដប់នេះព្រះពុទ្ធ | វិសេសវិសុទ្ធទ្រង់ត្រាស់ប្រាប់ |
| ថាមានតាំងពីបុរាណស្រាប់ | ជាច្បាប់ជាប់មានគ្រប់កាលមក ។ |
| ជាធម៌សម្រាប់ព្រះមហាក្សត្រិយ៍ | ព្រះអង្គប្រតិបត្តិមិនឲ្យឆ្លក |
| ប្រជាពលរដ្ឋក៏ប្រឹងរក | ក្បួនច្បាប់រៀនយកឲ្យចេះចាំ ។ |

ដើម្បីប្រព្រឹត្តឲ្យជិតដល់ ទោះមានកង្វល់ខ្លះក៏ទ្រាំ
ឆ្លៀតកាន់ធិមនេះមិនឲ្យខ្ជាំ នាំគ្នាប្រតិបត្តិតាមមហាក្សត្រិយ៍ ។
រាជធម៌បវរវិសេសផ្តល់ផល ឲ្យចៀសកង្វល់ចៀសវិបត្តិ
គ្រោះកាចរលាយរលុបខ្ចាត់ រសាត់ចេញឆ្ងាយទៅឯងៗ ។
ក្តីសុខចម្រើនកើតកើនឡើង ប្រទេសចុំថ្កើងឃើញជាក់ស្តែង
ប្រទេសជិតឆ្ងាយកោតស្ញប់ស្ញែង ថ្លែងការណ៍រាប់រកយកជាមិត្រ ។
មានមិត្រកល្យាណបានក្តីសុខ ស្រណុកកក់ក្តៅមិនព្រួយចិត្ត
បើឥតមានមិត្ររាប់ផ្តេកផ្តិត ទោះប្រិតប្រឹងប្រែងក៏ពុំកើត ។
ព្រះពុទ្ធទ្រង់ត្រាស់ពន្យល់ថា ចង់បានមិត្រភាពកល្យាណឆើត
ត្រូវប្រើការឲ្យទើបបានកើត កំណើតនៃមិត្រជិតស្និទ្ធស្នាល ។
មិត្រឲ្យអ្វីយើងត្រូវយើងឲ្យ ឲ្យមុនឲ្យក្រោយគង់ត្រកាល
ទោះតិចទោះច្រើនទាំងអម្បាល មានក្តីស្និទ្ធស្នាលជារសឆ្ងាញ់ ។
បុរាណថាទោះផ្ទះចង្អៀត អាចឆ្លៀតប៉ះប៉ុនផ្គត់ផ្គង់មិត្រ
បើចិត្តចង្អៀតវិញតាមពិត អាហារពិសិដ្ឋក៏ឥតឆ្ងាញ់ ។
ព្រះពុទ្ធជាគ្រូទ្រង់ត្រាស់ថា ឥតរស់ជាតិណាស្មើសម្លាញ់
រាប់រកស្និទ្ធជិតឥតគ្នាន់ក្នាញ់ ឆ្ងាញ់ក្រៃលែងឆ្ងាញ់ក្រប្រៀបបាន ។
ហេតុនោះយើងគួរតែសេពគប់ មិនដែលគ្រាន់គ្រប់ចេះរាប់អាន
មាត់ថាដូចម្តេចចិត្តក៏បាន មិនប្រានយើងចោលមិនថ្កោលទោស។
មិត្រនេះហៅថាមិត្រកល្យាណ ចិត្តបានហើយចេះមានសន្តោស
រាប់រកមិត្រភ័ក្តិឥតរឱស ពុំដែលចាប់ទោសកំហុសឡើយ ។
អ ហំ ថ្លែងរាប់រៀបប៉ុណ្ណោះ អ្នកអានល្មមចេះចាំដែរហើយ
បើអានបានយល់កុំតោះតើយ ចប់ហើយត្រឹមតែប៉ុណ្ណោះហោង ។៚

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យ ទី១ ធ្នូ ព.ស. ២៥១២ គ.ស ១៩៦៨**
**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**
**ប.អ.ស - អ.ម.រ**

# សីលានិសំសជាតក

## " ជាតកនិយាយពីអានិសង្សសីល "

**( ព្រមទាំងនិគមគាថានិងកាព្យពាក្យ ៧ ផង )**

**បស្ស សទ្ធាយ សីលស្សាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ ឯកំ សទ្ធំ ឧបាសកំ អារព្ភ កថេសិ** *ព្រះបរមសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់សម្តែងនូវសីលានិសំសជាតកនេះ មាន គាថាបាលីថា* **បស្ស សទ្ធា សីលស្ស** *ជាដើម ប្រារព្ធចំពោះឧបាសកម្នាក់ជាអ្នកមានសទ្ធា ។*

*មានរឿងដំណាលថា ឧបាសកនោះជាអរិយសាវ័កអ្នកមានសទ្ធាជ្រះថ្លាណាស់, ថ្ងៃមួយ ឧបាសកនោះធ្វើដំណើរទៅកាន់វត្តជេតពន នៅវេលារសៀលទាប, បានដល់ទៅត្រើយម្ខាង នៃទន្លេអចិរវតី, មិនឃើញមានទូកនឹងឆ្លងទៅត្រើយនាយសោះ ពីព្រោះអ្នកមានទូកទាំងអស់ ដែលធ្លាប់តែចម្លងមនុស្ស គេឆ្លងទៅចតឯត្រើយខាងនាយហើយ គេទៅស្តាប់ព្រះធម្មទេសនា ឯវត្តជេតពនអស់ទៅ ។ ឧបាសកនោះ នឹករំពឹងព្រះពុទ្ធគុណយកជាអារម្មណ៍ដ៏មុតមាំក្នុងចិត្ត កើតមានបីតិដ៏ខ្លាំងក្លា ក៏ដើរលើខ្នងទឹកដូចគេដើរលើផែនដី ដើម្បីឆ្លងទៅឲ្យបានដល់ ត្រើយនាយ ឥតមានផុងជើង ឬទទឹកជើងឡើយ, កំពុងដើរលើទឹកដល់ទៅពាក់កណ្តាលទន្លេ បានឃើញរលកទឹកយោលខ្ទោលៗ បីតិដ៏មានកម្លាំងនោះក៏បែរជាទន់ខ្សោយបន្តិច ទៅវិញ, ជើងទាំងពីររកកលនឹងផុងទៅក្នុងទឹក, គាត់ខំរំពឹងព្រះពុទ្ធគុណឲ្យកើតបីតិខ្លាំងឡើងវិញទៀត គាត់ក៏ដើរលើខ្នងទឹកបានងាយស្រួលដូចពីមុន, ចេះតែដើរស្រូតរហូតដល់បានឆ្លងផុតទឹកទៅ ដល់ត្រើយម្ខាង រួចហើយដើរចូលទៅវត្តជេតពនក្រាបថ្វាយបង្គំព្រះបរមសាស្តា ហើយគាត់ ក៏អង្គុយត្រង់ទីមួយដ៏សមគួរ ។*

*ព្រះសម្ពុទ្ធបរមសាស្តាទ្រង់ធ្វើបដិសន្ថារៈ តាមការគួរជាមួយនឹងគាត់ហើយ ព្រះអង្គទ្រង់ត្រាស់សួរថា ៖ ម្នាលឧបាសក, អ្នកឯងមកតាមផ្លូវមិនសូវមានក្តីពិបាកទេឬ ? - គាត់ក្រាបទូលថា ៖ សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំព្រះអង្គញុំាងបីតិមានព្រះពុទ្ធគុណជាអារម្មណ៍នឹងរឹងប៉ឹងក៏ដើរលើខ្នងទឹកមកហាក់ដូចជាគេដើរជាន់លើផ្ទៃដីឥតបីលំបាកទេ រហូតមកដល់ទីនេះ ។ ព្រះបរមសាស្តាទ្រង់ត្រាស់តបវិញថា ៖ អើឧបាសក, ដែលអ្នកឯងនឹកគុណព្រះពុទ្ធ យកពុទ្ធគុណជាអារម្មណ៍ចាំក្នុងចិត្តយ៉ាងនេះ ពុំមែនមានត្រឹមតែអ្នកឯងក្នុងកាលនេះប៉ុណ្ណោះទេ, ធ្លាប់មានរឿងតាំងពីបុរាណកាលព្រេងនាយមកហើយដែរ, ពីព្រេងនាយមានឧបាសកទាំងឡាយបានធ្វើដំណើរតាមសមុទ្រ, សំពៅបានបែកធ្លាយក្នុងកណ្តាលលំហសមុទ្រ, គេទាំងអស់គ្នារំលឹកគុណដល់ពុទ្ធគុណទាំងឡាយ ក៏បាននូវទីពំនាក់ដូចអ្នកឯងឥឡូវនេះដែរ ។ ឧបាសកនោះក៏ក្រាបទូលអារាធនា, ព្រះអង្គសម្តែងអតីតនិទានថា ៖*

**អតីតេ កស្សបសម្មាសម្ពុទ្ធកាលេ សោតាបន្នោ អរិយសាវកោ ឯកេន នហាបិតកុដុម្ពិកេន សទ្ធឹ នាវំ អភិរូហិ** *ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធកស្សប ដែលកន្លងយូរណាស់ទៅហើយ, មានឧបាសកសោតាបន្នបុគ្គលជាអរិយសាវកម្នាក់ បានចុះសំពៅជាមួយនឹងកុដុម្ពិកជាជាងកោរកាត់សក់ម្នាក់, ភរិយារបស់ជាងកោរកាត់សក់នោះបាននិយាយផ្ទុកផ្តាក់ផ្តាំផ្ញើនឹងឧបាសកនោះថា ៖ " សុខទុក្ខរបស់ប្តីខ្ញុំ ជាភារៈនៃអ្នកទាំងអស់ ( ខ្ញុំទុកចិត្តលើអ្នក ) " ។*

*លុះសំពៅចេញទៅបាន ៧ ថ្ងៃក៏បែកធ្លាយក្នុងកណ្តាលលំហសមុទ្រ ។ ជនទាំងពីរអ្នកបានដេកផ្ងារលើបន្ទះក្តារមួយបន្ទះជាមួយគ្នា បន្ទះក្តារក៏រសាត់ទៅដល់កោះតូចមួយហើយក៏នាំគ្នាឡើងទៅនៅលើកោះនោះ ។ ជាងកោរកាត់សក់បានសម្លាប់សត្វស្លាបទាំងឡាយយកមកអាំងស៊ី, បានចែកឲ្យឧបាសកនោះផង ប៉ុន្តែឧបាសកប្រកែកមិនព្រមទទួលយកមកបរិភោគទេ, គាត់គិតឃើញថា ៖ ក្នុងទីនេះក្រៅពីត្រៃសរណៈឥតមានអ្វីជាទីពឹងពំនាក់របស់យើងឡើយ, គិតឃើញយ៉ាងនេះហើយគាត់ក៏ចេះតែរំលឹកគុណទាំងឡាយ នៃព្រះរត្នត្រ័យជានិច្ចនិរន្តរ៍ ។ កាលដែលឧបាសកនោះរំលឹកគុណព្រះរត្នត្រ័យយ៉ាងនេះ;* **តស្មឹ ទីបកេ និព្វត្តោ នាគរាជា អត្តនោ សរីរំ មហានាវំ កត្វា មាបេសិ** *នាគរាជដែលកើតនៅក្នុងកោះតូចនោះក៏និម្មិតកាយខ្លួនធ្វើជាសំពៅធំ ។* **សមុទ្ទទេវតា និយាមកោ មាណវោ អហោសិ** *សមុទ្ទទេវតាកាឡាខ្លួនជាមាណពអ្នកកាច់ចង្កូត ។* **នាវា សត្តរតនេហិ បូរយិត្ថ** *សំពៅនោះ*

ផ្ទុកពេញដោយរតនៈ ៧ ប្រការ ។ **តយោ កូបកា ឥន្ទនីលមណិមយា អហេសុំ** ដងក្ដោងទាំង ៣ សុទ្ធតែជាកែវឥន្ទនីល **សោវណ្ណមយោ លង្ការោ** ស្លាបក្ដោងសុទ្ធតែជាមាស **រជតមយានិ យោត្តានិ** ខ្សែលុត ខ្សែលៀវសុទ្ធតែជាប្រាក់ **សោវណ្ណមយានិ ឃដ្ឋិយានិ** ដងសាវទាំងឡាយ សុទ្ធតែជាមាស ។ **សមុទ្ទ ទេវតា នាវាយបត្វា អត្ថិ ជម្ពុទីបំ គមិកាតិ ឃោសេតិ** សមុទ្ទទេវតាបើកសំពៅមកចតក្បែរកោះតូចនោះ ស្រែកឮខ្លាំងៗសួរថា ៖ " មានអ្នកណាត្រូវការទៅជម្ពូទ្វីប[១] ដែរឬទេ? " ។ **ឧបាសកោ មយំ គមិស្សាមាតិ អាហ** ឧបាសកនិយាយថា ៖ " យើងត្រូវការទៅ " ។ **តេនហិ ឯហិ នាវំ អភិរូហាតិ** សមុទ្ទទេវតាថា ៖ " មក៍, បើដូច្នោះចុះសំពៅមក៍ ! " ។ ឧបាសកនោះចុះសំពៅ ហើយក៏ស្រែកហៅជាងកោរកាត់សក់ឲ្យចុះមកជាមួយផង ។ សមុទ្ទទេវតានិយាយថា ៖ " ចុះមកបានតែអ្នកឯងប៉ុណ្ណឹង, មិនឲ្យអ្នកនោះចុះមកជាមួយផងទេ ! " **កឹការណាតិ** ? ឧបាសកសួរថា ៖ " ម៉េចក៏មិនឲ្យគាត់ចុះមកផង ? " សមុទ្ទទេវតាឆ្លើយថា ៖ " ពីព្រោះគាត់ហ្នឹងគ្មានសីលាចារគុណ, ព្រោះហេតុនោះខ្ញុំបើកសំពៅមកយកតែអ្នកឯងម្នាក់ប៉ុណ្ណឹង, មិនបំរុងនឹងយកអ្នកម្នាក់ហ្នឹងផងទេ ។ **ហោតុ, អហំ អត្តនោ ទិន្នទានេន រក្ខិតសីលេន ភាវិតភាវនាយ ឯតស្ស បត្តឹ ទម្មិ** ឧបាសកនិយាយថា ៖ " ឱ! បើដូច្នោះ, ខ្ញុំឲ្យចំណែកផលបុណ្យដែលខ្ញុំបានឲ្យទាន បានរក្សាសីល បានចំរើនភាវនាដល់អ្នកហ្នឹងផងចុះ " ។ **នហាបិ តោ អនុមោទាមីតិ អាហ** ជាងកោរកាត់សក់ថា ៖ " ខ្ញុំសូមទទួលអនុមោទនា ! " គឺគាត់តាំងចិត្តត្រេកអរ ចំពោះផលបុណ្យដែលឧបាសកនោះបានចែកឲ្យគាត់ ។ សមុទ្ទទេវតា ក៏យល់ព្រមឲ្យជាងកោរកាត់សក់នោះចុះសំពៅមកផងដែរហើយក៏បើកសំពៅត្រាតែចេញផុតពីសមុទ្រចូលមកតាមដងទន្លេគង្គារ[២] បានដល់ទៅក្រុងពារាណសី ហើយប្រើឫទ្ធានុភាពរបស់ខ្លួនជាទេវតា នាំយកទ្រព្យទាំងអស់ទៅដាក់ឯផ្ទះនៃជនទាំងពីរនាក់ ហើយនិយាយរំលឹកថា ៖ **បណ្ឌិតេហេវ សទ្ធឹ សំសគ្គោ នាម ភាតព្វោ សចេ ឥមស្ស នហា បិតស្ស ឥមិនា ឧបាសកេន សទ្ធឹ សំសគ្គោ នាភវិស្ស, សមុទ្ទមជ្ឈេយេវ នស្សិស្សតីតិ បណ្ឌិតសំសគ្គស្ស គុណោ កថយមានា ឥមា គាថា អវោច** " បុគ្គលគួរធ្វើការសេពគប់រាប់រក

(១) ជម្ពូទ្វីបនេះ គឺជាប្រទេសឥណ្ឌាសព្វថ្ងៃ ។

(២) គួរយល់ថា ដោយឫទ្ធានុភាពនៃទេវតា ឥតមានអ្នកណាមើលសំពៅនេះឃើញទេ ។

យកបណ្ឌិតជាមិត្រ ជាគ្នា, ជាងកោរកាត់សក់បើកុំតែបានសេពគប់រាប់រកយកឧបាសកនេះជាគ្នា, កុំអីវិនាសអន្តរាយក្នុងកណ្ដាលលំហសមុទ្រទៅហើយ !" សមុទ្ទទេវតាថ្លែងគុណនៃបណ្ឌិតសំសត្តធម៌គឺធម៌សេពគប់រាប់រកយកបណ្ឌិតសប្បុរសជាមិត្រ ជាគ្នាតែត្រឹមប៉ុណ្ណោះហើយក៏ពោលគាថាពីរនេះថា ៖

**បស្ស សទ្ធាយ សីលស្ស ចាគស្ស ច អយំ[១] ផលំ**
**នាគោ នាវាយ វណ្ណេន សទ្ធំ វហតិ ឧបាសកំ[២]។**

ចូរមើលចុះ ! នេះគឺជាផលានិសង្សនៃ សទ្ធា, សីល, បរិច្ចាគ ។ នាគដែលកាឡាខ្លួនជាសំពៅមកនាំឧបាសកអ្នកមានសទ្ធា ( ក៏ព្រោះតែសីលាទិគុណនេះឯង ) ។

**សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ**
**សតំ ហិ សន្និវាសេន សោត្ថី គច្ឆតិ នហាបិតោ ។**

បុគ្គលគួរសេពគប់រាប់រកយកសប្បុរសទាំងឡាយជាគ្នា, គួរធ្វើនូវមិត្តសន្ថវៈគឺគួររាប់រកយកសប្បុរសជនជាមិត្រ, ដូចជាជាងកោកាត់សក់បាននូវសួស្តីសិរីចម្រើន ដោយសារការនៅរួបរួមកម្សត់កម្រជាមួយនឹងឧបាសកជាសប្បុរសជននេះឯង ។

សមុទ្ទទេវតាឋិតនៅឯអាកាស សម្តែងពាក្យទូន្មានយ៉ាងនេះហើយក៏នាំនាគរាជទៅកាន់ឋានវិមានរបស់ខ្លួនវិញ ។

ព្រះសក្យមុនីសម្ពុទ្ធជាបរមសាស្តា ទ្រង់សម្តែងរឿងជាអតីតនិទាននេះចប់ហើយព្រះអង្គប្រកាសនូវអរិយសច្ចធម៌ទាំង ៤ លុះចប់អរិយសច្ចធម៌ហើយ ឧបាសកនោះក៏បានសម្រេចដល់សកទាគាមិផល ។ ព្រះបរមសាស្តាទ្រង់ភ្ជុំជាតកថា ឧបាសកសោតាបន្នជាអរិយសាវ័កក្នុងកាលនៃព្រះពុទ្ធកស្សបនោះ បានចម្រើននូវអរិយមគ្គតៗទៅទៀត ត្រាតែបានសំរេចអរហត្តផលហើយចូលបរិនិព្វានទៅ ។ ឯចំណែកនាគរាជក្នុងកាលណោះក៏អន្ទោលជាតិមកកើតជាព្រះសារីបុត្ត, ឯសមុទ្ទទេវតា គឺអញតថាគតនេះឯង ។

(១) **ឥទន្តិ ឥមិស្សំ អដ្ឋកថាយំ លិខិតំ ។**
(២) **វហតុបាសកន្តិបិ ។**

**សីលានិសំសជាតកទី ១០ ក្នុងអសទិសវគ្គទី ៤ នៃទុកនិបាតវណ្ណនា**

**ចប់**

# និគមពាក្យ

**និគមវចនេន បនិមា ឥន្ទវិសនិពន្ធគាថា**
**ជ.ណ ជោតញ្ញាណេន សង្ឃរាជេន រចិតា មយា ៖**

**បស្សន្តុ សាធូ អតិសេវនំ កតំ**
**បោរាណធម្មំ សុគតេន ទេសិតំ**
**សុត្វាបិ សក្កច្ច ករោថ សេវនំ**
**សីលានិសំសោ បដិទេតិ ឦទិសំ ។**
**ឯវម្បិ សីលំ អតិតេជវន្តកំ**
**តស្មា ហិ រក្ខេយ្យ អន្ធូនកំ សទា**
**សីលញ្ហិ យោគិស្ស ផលប្បទាយកំ**
**សីលប្បិយោ ទេវនិកាយរក្ខកោ ។**
**កាលេបិ ទុក្ខំ អនុភោតិ យោ នរោ**
**សោត្ថានិសំសំ លភតេវ សោ នរោ**
**ទេវានុរក្ខញ្ហិ លភេតិ បណ្ឌិតោ**
**បោរាណវត្ថុម្ហិ ឧបាសកោ យថាតិ ។**

*ចូរសាធុសប្បុរសទាំងឡាយ រមិលមើលនូវការសេពគប់រាប់រកគ្នាដែលគេបានធ្វើទុកហើយឲ្យជាតម្រាប់ ជាធម៌ដែលគេកាន់រក្សាក្នុងសម័យបុរាណព្រេងនាយ ដែលព្រះសុគតបរមសាស្តាទ្រង់សម្តែងប្រទាននេះចុះ ។ បើអស់លោកអ្នកបានអាន បានស្តាប់ហើយ ចូរធ្វើនូវការសេពគប់ឲ្យស៊ប់ ( ចំពោះតែ ជនសប្បុរស, កុំសេពគប់ជនជាអសប្បុរសឡើយ ), សីលានិសង្សតែងតែផ្តល់ផលជាសុខចម្រើនឲ្យដូចរឿងនិទានក្នុងសីលានិសំសជាតកនេះឯង។ សីលមានតេជៈជាក់ស្តែងក្រៃលែងយ៉ាងនេះ, ហេតុនេះគួរតែសាធុជនរក្សាសីលរាល់កាលជានិច្ចកុំឲ្យខ្វះខ្វាត, សីលជាគុណជាតិផ្តល់ផលឲ្យដល់យោគីអ្នកកាន់សីលខ្ជាប់, ជនអ្នកមាន*

*សីលជាទីស្រឡាញ់ពួកទេពតាតែងតែបីបាច់ថែរក្សា ។ ជនអ្នកកាន់សីលណា បើមានទុក្ខព្រួយមួយដងមួយកាល, ជននោះតែងតែបាននូវសាត្ថានិសង្ស គឺអានិសង្សជាសុខសួស្តីសិរីចម្រើន, បណ្ឌិត ( អ្នកកាន់សីលដ៏ឧក្រិដ្ឋ ) តែងតែបាននូវទេវានុរក្ស គឺការបីបាច់រក្សានៃទេពតាដូចជាឧបាសក ( លិចសំពៅ ) ក្នុងរឿងនិទានសម័យបុរាណ ( ដែលបានពោលរួចហើយ ) នោះឯង ។*

## ពាក្យកាព្យសម្រាយឲ្យងាយចាំ

## បទពាក្យ ៧

*កាន់សីលមានសីលជាទីពឹង　　ពំនឹងថាជាមិត្រមេត្រី*
*ប្រសើរជាងមិត្រនាលោកីយ៍　　សីលចេះតែថ្មីឥតចេះចាស់　　។*
*កាលពីព្រេងនាយសីលក៏ថ្មី　　ឥឡូវនេះក្តីនៅជាក់ច្បាស់*
*ព្រោះសីលបរិសុទ្ធប្រសើរណាស់　　ឥតចាស់ទេនៅថ្មីសន្លាង　　។*
*ព្រះពុទ្ធត្រាស់ថាក្រៅពីសីល　　មានចាស់រេចរិលព្រោះរូបរាង*
*តែងតែគ្រាំគ្រាឥតគ្រឿងអាង　　មិនថ្មីសន្លាងដូចសីលឡើយ　　។*
*កុំពោលថាសីលមានថ្មីចាស់　　ពោលនោះខុសណាស់ពេកទៅហើយ*
*បើសីលមានចាស់មែនម្តេចឡើយ　　យើងកាន់ក្រោយគេនឹងបានបុណ្យ?។*
*អ្នកណាគេកាន់ជាប្រក្រតី　　សីលគេថ្មីៗឥតមានស្កុន*
*អ្នកនោះគេមានសីលជាគុណ　　ផ្តល់បុណ្យឲ្យគេបានសុខា　　។*
*សីលមានទ្រង់ចេតនាវៀរ-　　ចាកចិត្តចង់ពៀរកម្មពុំជា*
*សីលនៅគ្រងវិរចិត្តា　　ព្រះពុទ្ធហៅថាជាតួសីល(១)　　។*

---

(១) *ព្រះពុទ្ធតម្រាស់ថា* : **ចេតនាហំ ភិក្ខវេ សីលំ វទាមិ** *" ម្នាលភិក្ខុទាំងឡាយ, អាត្មាតថាគត ហៅ* **វិរតិ ចេតនា** *ថាជាតួសីល " ។*

ពុំមែនហៅសីលត្រង់មាត់ថា    ទោះថាច្រើនចប់ប៉ុន្តែខិល
មិនកាន់តាមមាត់ថាកាន់សីល    សីលរេចសីលវិលព្រោះមិនកាន់។
កាន់សីលឧក្រិដ្ឋវែងមានផល    ផ្តល់សុខឲ្យឃើញប្រត្យក្សស្បាន់
ទោះមានគ្រោះកាចមិនភ័យភ័ន្ត    មិនស្លន់មិនស្លុតឲ្យសៅហ្មង ។
ដូចរឿងនិទានឧបាសក    ដែលជាងកាត់សក់គាត់បានផ្គង
យកសាច់អាំងឆ្អិនឲ្យស៊ីផង    ខ្លាចសីលសៅហ្មងមិនព្រមស៊ី ។
ស្រឡាញ់សីលណាស់ជាងជីវិត    មិនគិតប៉ុន្មានដល់ជីវី
ខំផ្ចង់កាន់សីលតាមវិធី    មុនីបណ្ឌិតពិតទៀងត្រង់ ។
បានជាស្តេចនាគនិងទេព្តា    រក្សាសមុទ្រប្លែងរូបអង្គ
ជានាវាធំបើកតម្រង់    ផ្ចង់មកនាំយកទៅដល់ឋាន ។
**អហំ ជ.ណា ជោតញ្ញាណោ**    បានស្រង់និទានតាមលំអាន
គម្ពីរជាតកពីបុរាណ    ដែលព្រះទ្រង់ញាណប្រទានប្រាប់។
ប្រសិនបើលោក-អ្នកអាចកាន់    សីលឲ្យជាក់ស្បាន់តាមសណ្តាប់
នៃអ្នកប្រាជ្ញព្រេងនាយជាតម្រាប់    នឹងបានផលគាប់ប្រសើរហោង ៕ល៚

**វត្តខ្ទណ្ឌាលោម ក្រុងភ្នំពេញ, ថ្ងៃពុធ ទី ២៨ ធ្នូ ព.ស. ២៥១២ គ.ស ១៩៦៨**
**សម្តេចព្រះសង្ឃរាជ ជ.ណា ជោតញ្ញាណោ**
**ប.អ.ស - អ.ម.រ**



# កាព្យពោលពីញៀន

**" ដោយសង្ខេប "**

## បទកាកគតិ

*ញៀនក្នុងលោកីយ៍ ពុំអាចដើម្បី ស្រដីពណ៌នា*
*ញៀនជក់បារី ញៀនជាប់ស៊ីស្លា ញៀនផឹកសុរា*
*ញៀនជក់អាភៀន ។*

*ញៀនល្បែងស៊ីសង ញៀនក្រែកន្លង ញៀនខំសូធ្យរៀន*
*ញៀនដើរលេងយប់ តាមច្រកតាមកៀន មួយយ៉ាងហៅញៀន*
*ជក់មើលមហោស្រព។*

*ញៀនលេងចត្រង្គ ញៀនតែងរូបអង្គ ញៀនលាបទឹកអប់*
*ញៀនជក់កញ្ឆា និងញៀនទាំងគ្រប់ ពណ៌នាពុំចប់*
*សុទ្ធតែហៅញៀន ។*

*ញៀនអស់ទាំងនេះ មានញៀនខ្លះចេះ បំពេញការរៀន*
*ឲ្យមានចំណេះ វិជ្ជារបៀន បែបនេះហៅញៀន*
*បំពេញប្រយោជន៍ ។*

*ញៀនធ្វើការងារ ធ្វើស្រែចំការ មិនឲ្យខ្វះហោច*
*នេះត្រូវញៀនចុះ ព្រោះមានប្រយោជន៍ បើមានការហោច*
*កុំបីញៀនឡើយ ។*

*ញៀនដុសខាត់ចិត្ត កាន់សីលសុចរិត ញុំាងចិត្តឲ្យស្បើយ*
*ចាកក្តីសាំញុំា រង់ចាំដល់ត្រើយ មានសុខកន្តើយ*
*ហៅញៀនផ្លូវធម៌ ។*

*អ្នកប្រាជ្ញសរសើរ ជនចេះរៀនដើរ តាមផ្លូវបវរ*
*ព្រះឥន្ទទេព្តា នាំគ្នាឲ្យពរ ឃ្លាតក្តីវិវរ*
*ព្រោះរៀនត្រូវផ្លូវ ។៚*

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអង្គារ ទី ៣១ ធ្នូ ព.ស. ២៥១២ គ.ស ១៩៦៨**
**សម្តេចព្រះសង្ឃរាជ ជ.ណា ជោតញ្ញាណោ**
**ប.អ.ស - អ.ម.រ**



# អក្សរខ្មែរ

## " កាព្យរំលឹកអំពីអក្សរ "

## បទពាក្យ ៧

*អក្សរខ្មែររុងរឿងដោយសារខ្មែរ ពុំហ៊ានបំបែរឲ្យភ្លាត់ខុស*
*ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស ពុំហ៊ានបង្ហុសឲ្យខូចបង់ ។*
*ជនខ្មែរស្រុះគ្នាលើកតម្កើង ដំឡើងពាក្យពេចន៍ដោយផ្ចិតផ្ចង់*
*ខ្មែរជាគ្រហស្ថខ្មែរជាសង្ឃ ខំប្រឹងតម្រង់អក្សរជាតិ ។*
*អក្សរវិបត្តិជាតិវិបត្តិ ខ្មាយខ្មាត់រាត់រាយក្លាយឃ្លៀងឃ្លាត*
*ហេតុនេះខ្មែរយើងកុំរវាត ត្រូវរក្សាជាតិឲ្យរឹងប៉ឹង ។*
*បើដឹងមិនដល់កុំធ្វើចេះ ចំណេះតិចតួចស្តួចស្តើងស្តឹង*
*បើចង់ច្បាស់លាស់ត្រូវខំប្រឹង កុំដេកសម្លឹងឲ្យចេះឯង ។*
*ចំណេះកើតមានព្រោះការរៀន កម្ជិលអៀនប្រៀនកុំសម្តែង*
*ធ្វើឲ្យគេស្ញើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ ។*
*ត្រូវរិះគន់ខ្លួនឯងជាមុន កុំឲ្យស៊ីយស៊ុនខុសទទេ*
*បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតថោកអ្វីទេថ្លៃទេតើ ។*
*បុរាណថាថោកអ្វីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើរើ*
*រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះប្រសើរណាស់ ។*
*ចាស់ថាបើល្ងង់កុំធ្វើចេះ បើមានចំណេះឲ្យជាក់ច្បាស់*
*បើស្តើងហើយចង់ឲ្យបានក្រាស់ ត្រូវថែមកម្រាស់ផ្សំសាច់គ្នា ។*
*អមស្នូបប៉ះប៉ុនយកកម្រាស់ កុំចាំងកុំច្រាស់ហួសមាត្រា*
*ប៉ះផ្សំផ្គុំផ្ចិតទើបកើតជា ទោលឬបន្ទាវម្ហូនជាងមុន ។*
*បើចេះអក្សរនិងភាសា នៃជាតិណាៗកុំច្រុលស៊ុន*

ងាប់ស័ព្ទប្រែស្រាយក្លាយជាប់កុន សុនត្រុនប្រែស្រាយឃ្លាតការពិត ។
កាលដែលប្រារព្ធនឹងប្រែស្រាយ ត្រូវគិតនាយអោយដោយពិនិត្យ
ឲ្យឃើញសេចក្ដីជាខ្មែរពិត សឹមប្រែកុំផ្ចិតតាមពាក្យគេ ។
ត្រូវប្រែឲ្យមកជាសេចក្ដី ដែលខ្មែរប្រុសស្រីអាចរិះរេ
ស្ដាប់យល់មិនឆ្ងល់ទើបហៅប្រែ ត្រឹមត្រូវតាមរូបសេចក្ដីពិត ។
អ្នករៀនភាសាជនបរទេស ទ្វេធ្វេសដោយការឥតបើគិត
កាលខ្លួនកំពុងរៀនប្រឹងប្រិត ប្រែផ្ចិតឲ្យចំតាមរូបស័ព្ទ ។
ភ្លេចនឹកគិតមកភាសាខ្លួន ឲ្យយល់សំនួនដែលងាយស្ដាប់
សម្លឹងសង្កេតតែរូបស័ព្ទ ក៏ស្រាប់តែប្រែខុសទាំងស្រុង ។
អ្នករៀនសំស្ក្រឹតឬបាលី ប្រែខុសសេចក្ដីព្រោះភ័ន្តផុង
យល់ខុសទទេទាំងដើមចុង ចូលក្នុងវិងស៊ុងខ្មាសអ្នកផង ។
តិដ្ឋៈបាលីប្រែថាឈរ អ្នករៀនឈ្លក់វរភ័ន្តម្ដងៗ
ត្រង់មានសេចក្ដីថាស្លូនគ្រង ប្រែឆ្គងថាឈរហៅងាប់ស័ព្ទ ។
បារាំងពារ៍កតេស្លូរល៉ាតែត ខ្មែរឆ្អែតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនចេះឲ្យគ្នាស្ដាប់ បង្គាប់ថាឲ្យកាន់លើក្បាល ។
មិនប្រាប់ឲ្យគ្នាដឹងថាទូល នេះហៅស្រមូលពុំត្រកាល
ពាក្យខ្មែរថាទូលក៏លើក្បាល ត្រអាលប្រែខុសពីពាក្យខ្លួន ។
តែងកាព្យឲ្យត្រូវតាមសម្ផស្ស តាមកាព្យចាស់ៗដែលមានចួន
កុំចេះតែតែងតាមចិត្តខ្លួន ឲ្យកាព្យមានចួនខុសមាត្រា ។
ពាក្យអឺយនិងអើយ[១]សួរផ្សេងគ្នា ដូចជាប្អូនអើយ[២]ម្ដេចឡើយថា
ស្ដាប់បងមិនឮឬស្ងួនភ្ងា ធ្វើជាមិនឮព្រោះរឹងខ្លួន ? ។

---

(១) អានថា អ្ហ៊ើយ កុំថា អើយឬអឺយ ឡើយ ។

(២) អានថា ប្អូន អ្ហ៊ើយឬប្អូន ណើយ កុំថា ប្អូនអឺយ ។

ព្រះបាទសម្តេចព្រះហរិរ័ក្ស ទ្រង់បានបញ្ជាក់ដោយផ្ទួនៗ
ក្នុងកាព្យព្រះអង្គដែលមានចូន សំនួនសម្ផស្សឥតមានឆ្គង ។
កវីគួរតែយកតម្រាប់ ពុំគួរប្រញាប់កាត់រំលង
រំលុបបែបនោះមិនត្រាប់ត្រង ខុសពីបំណងអ្នកប្រាជ្ញចាស់ ។
មានអ្នកតែងកាព្យខ្លះហ៊ានថា ម្តេចមិនវាចាឲ្យជាក់ច្បាស់
ប្រើជាកិរិយាស័ព្ទខុសណាស់ គួរផ្លាស់សម្ដីនេះចោលចេញ ។៚



# បទកាកគតិ

ខ្មែរពីព្រេងនាយ ចង់បានឲ្យងាយ ប្រើពាក្យរីងៗ
ត្រង់ពាក្យដែលត្រូវ ប្រើគ្រឹង្គឬស្រឹង្គ អ្នកអានពុំនឹង
ពាក្យទាំងពីរនេះ ។

តើគ្រឹង្គឬស្រឹង្គ?[១] ដោយពុំបានដឹង ព្រោះខ្លួនពុំចេះ
នាំឲ្យច្រឡំ ជ្រិតឥតចំណោះ សំស្រឹតមិនចេះ
ធ្វើម្តេចនឹងយល់ ។

ហេតុនេះបានជា ខ្មែរទាំងអស់គ្នា ក្នុងគ្រាឆ្ងៃឆ្ងល់
នាំគ្នាលុបតួ "**គ**"[២] មិនឲ្យសល់ ថែមទាំងលុបដល់
"**ម**"[៣] នេះទៀតផង ។

ព្រោះសទាំងបី អានឮសម្តី ដូចគ្នាតែម្តង
តើទុកធ្វើអ្វី នាំឲ្យតែឆ្គង លុបចោលរំលង
កុំឲ្យចង្អៀត ។

ចំណែកខាងលាវ សម័យព្រាវៗ ក៏នាំគ្នាឆ្លៀត
លុបតួអក្សរ ដប់ពីរបង់សៀត កម្រនឹងឆ្លៀត
បង្កើតវិញបាន ។

លាវលុបតួ "**ឃ**" និងតួ "**ឆ-ឈ**" វគ្គ "**ង**" ប៉ុន្មាន
និងតួ "**ធ-ភ**" "**គ-ម**" ពីរប្រាណ បូករួមទៅបាន
ដប់ពីរអក្សរ ។

---

(១) សំ. គ្ឫង្គ > គ្រឹង្គ; បា.សិង្គ ស្នែង, ផ្នុងត្រី ។

(២) អ.ថ. ស ( ç )

(៣) អ.ថ. ( S )

*សម័យនេះលាវ　　សរសេរព្រាវៗ　　អស់ភាពបវរ*
*ត្រង់ពាក្យប្រើ "ឃ"　　ប្រើ "គ"(១) អក្សរ　　លាវឃ្លាតអំណរ*
*រកត្រូវទៅហើយ ។*

*ហេតុនោះខ្មែរយើង　　កុំធ្វើទើងមើង　　យល់ការល្ងើយៗ*
*គិតលុបអក្សរ　　តួខ្លះចោលឡើយ　　បើលុបច្រោះហើយ*
*ទៅជាមនុស្សព្រៃ ។*

*ប្រទេសធំៗ　　គេប្រឹងនិយម　　រាល់យប់រាល់ថ្ងៃ*
*អក្សរភាសា　　ជាតិគេឲ្យថ្លៃ　　កុំឲ្យចង្រៃ*
*រូបរឹតជាតិបាន ។*

*បណ្ឌិត្យសភា　　គេលើកឲ្យជា　　បណ្ឌិត្យដ្ឋាន*
*សម្រាប់ឲ្យជាតិ　　ឡើងខ្ពស់ថ្កើនថ្កាន　　ទើបជាតិគេបាន*
*ច្កុំថ្កើងជានិច្ច ៕ល៚*

---

*(១) ព្រោះលាវយល់ឃើញថាមាន សូរសំឡេងដូចគ្នា ត្រូវលុបចោលខ្លះទៅ ។*

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃ ទី ២២ មករា ព.ស. ២៥១២ គ.ស ១៩៦៩**

**សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ**

**ប.អ.ស - អ.ម.រ**



# ព្រះរាជជីវប្រវត្តិ
## នៃ
## សម្ដេចព្រះមហាសុមេធាធិបតី ជួន ណាត
## ព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ

**សម្ដេច** ទ្រង់បានប្រសូតនៅថ្ងៃអង្គារ ១១ រោចខែផល្គុន ព.ស.២៤២៧ គឺថ្ងៃទី ១១ មីនា១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខែត្រកំពង់ស្ពឺ ព្រះបិតានាម **ជួន** ព្រះមាតានាម **យក់** ។ គ្រួសារនេះ មានបុត្រតែពីរគត់គឺ **សម្ដេច** និងឧកញ៉ាសោភណមន្ត្រី **ជួន នុត** ។

កាលនៅជាកុមារ បានសិក្សាអក្សរនិងលេខដរាបដល់ជន្មាយុ ១៨ ឆ្នាំ បានបួសជាសាមណេរក្នុងថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំចសំរិទ្ធស័ក ព.ស. ២៤៤១ ( ឧសភា ១៨៩៧ ) នៅវត្តពោធិព្រឹក្ស ( ហៅវត្តពោល្យំ ) សង្កាត់រលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ បួសជាសាមណេរបានពីរឆ្នាំ ក្នុង ព.ស. ២៤៤៣ គ.ស. ១៨៩៩ **សម្ដេច** បានចូលសិក្សាព្រះបរិយត្តិធម៌នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ លុះបានជន្មាយុគ្រប់ ២១ ឆ្នាំ បានទៅសូមបំពេញឧបសម្បទាជាភិក្ខុនៅថ្ងៃ ១៤ កើតខែជេស្ឋ ឆ្នាំរោងឆស័ក ព.ស.២៤៤៨ ( មិថុនា ១៩០៤ ) នៅវត្តពោធិព្រឹក្សដែលជាវត្តដើម បាននិមន្តព្រះតេជគុណ ព្រះពុទ្ធឃោសាចារ្យ **ម៉ា កេត** សុវណ្ណប្បញ្ញោ កាលនៅជាចៅអធិការវត្តពោធិព្រឹក្ស ជាឧបជ្ឈាយ៍ ព្រះតេជព្រះគុណ **កែ ម៉ម** មិស្សនាគោ ជាគ្រូសូត្រធម្មវាចារ្យ និងព្រះតេជគុណ **អ៊ុន ខឹម** តិក្ខប្បញ្ញោ ជាគ្រូសូត្រអនុស្សាវនាចារ្យ ។ **សម្ដេច** ទ្រង់បានទទួលនាមប្បញ្ញត្តិជា **ជោតញ្ញាណោ** ។ បានទ្រង់បំពេញជាភិក្ខុហើយ **សម្ដេច** និមន្តត្រឡប់មកគង់នៅវត្តឧណ្ណាលោមវិញ ។

# ចំណេះវិជ្ជា
# និងកិច្ចការដែលទ្រង់បានបំពេញក្នុងព្រះពុទ្ធសាសនា

ក្រៅពីភាសាខ្មែរដែល **សម្តេច** ទ្រង់បានស្រាវជ្រាវយង់យល់ឫសគល់ពិតប្រាកដ **សម្តេច** ចេះភាសាបាលីអាចអានឬសន្ធនាតាមសំនៀងជាតិបរទេសទាំងអស់គឺ សំនៀងលង្កា ភូមា មន សៀម និងលាវ បានឥតមានទើសទាក់ ។

នៅ ព.ស. ២៤៦៦ និង ២៤៦៧ ( ១៩២២-១៩២៣ ) កាលនៅជាព្រះគ្រូសង្ឃសត្ថា បានទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និងអក្សរសិលាចារិកជាដើម នៅសាលាបារាំងសែសចុងបូព៌ាប្រទេសនាក្រុងហាណូយ ( យួនខាងជើង ) ក្នុងសំណាក់លោក ល្វី ហ្វី ណូ្ហត ជាតិបារាំងសែសជាចាងហ្វាងសាលានេះ ។

**សម្តេច** ទ្រង់ចេះអក្សរ និងភាសាសៀម លាវ យ៉ាងជាក់លាក់និងភាសាបារាំងសែសល្មមប្រាស្រ័យការបានដោយសំនៀងគួរឲ្យសរសើរ ភាសាអង់គ្លេស និងភាសាយួនផង ។

នៅ ព.ស. ២៤៥៧ គ.ស. ១៩១៣ **សម្តេច** ទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោ-សថរតនារាម ( ព្រះវិហារព្រះកែវមរកត ) ចំពោះព្រះភ័ក្ត្រព្រះករុណាព្រះបាទ **សម្តេច ព្រះស៊ីសុវត្ថិ** បាន៤ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ ។

ព.ស. ២៤៥៩ គ.ស. ១៩១៥ **សម្តេច** ទ្រង់បានប្រឡងជាប់លេខ ២ បានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ព.ស. ២៤៦៣ គ.ស. ១៩១៩ **សម្តេច** ទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់លុះត្រាបានចប់ចុងចប់ដើម ។

ព.ស. ២៤៦៩ គ.ស. ១៩២៥ **សម្តេច** ទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យសេចក្តីខុសត្រូវនៃសៀវភៅនានា ដែលសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយ ។

ព.ស. ២៤៧០ គ.ស. ១៩២៦ តមកជាច្រើនឆ្នាំ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាមេប្រយោគ ក្នុងការប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាខ្មែរ និងការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់បារាំង-ខ្មែរ នៅក្រុងភ្នំពេញ ។

ព.ស. ២៤៧១ គ.ស. ១៩២៧ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំផ្ទៀងសម្រេចវចនានុក្រមខ្មែរហើយ **សម្តេច** ទ្រង់បានទទួលធ្វើវចនានុក្រមតែមួយព្រះអង្គឯងដរាបដល់បានចប់សព្វគ្រប់ បានបោះពុម្ពផ្សាយទាំងភាគ ១ និងភាគ ២ ។

ក្នុងឆ្នាំដដែលនេះ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាលជំនុំផ្តាច់ឆ្នាំសម្រាប់ព្រះរាជបណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃហៅថា បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ។

ព.ស. ២៤៧៤ គ.ស. ១៩៣០ **សម្តេច** ទ្រង់បានទទួលការតែងតាំងក្នុងមុខងារជាចាងហ្វាងរងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ហើយនៅក្នុងឆ្នាំដដែលនោះ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យទៀតផង ។

ព.ស. ២៤៧៦ គ.ស. ១៩៣២ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសរកពាក្យពេចន៍ក្នុងផ្ទៃនៃកវីនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនានុក្រមខ្មែរ ។

ព.ស. ២៤៧៧ គ.ស. ១៩៣៣ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ។

ព.ស. ២៤៧៨ គ.ស. ១៩៣៤ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំងសម្រាប់ប្រើក្នុងកិច្ចការរាជការ ។

ព.ស. ២៤៧៩ គ.ស. ១៩៣៥ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹត ខ្មែរ និងលាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។

ព.ស. ២៤៨៦ គ.ស. ១៩៤២ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ( ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត ) ។

ព.ស. ២៤៨៨ គ.ស. ១៩៤៤ **សម្តេច** ទ្រង់បានទទួលការតែងតាំងជាចៅអធិការ វត្តឧណ្ណាលោម ។

ព.ស. ២៤៨៩ គ.ស. ១៩៤៥ **សម្តេច** ទ្រង់បានទទួលនាទីជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់ព្រះសង្ឃ ។

ព.ស. ២៤៩១ គ.ស. ១៩៤៧ **សម្តេច** ទ្រង់បានទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ផ្នែកអក្សរ (ក ) នៃគណៈកម្មការជាតិខាងការសិក្សា ។

ព.ស. ២៤៩២ គ.ស. ១៩៤៨ **សម្តេច** ទ្រង់បានទទួលនាទីជាប្រធាននៃគណៈកម្មការធម្មវិន័យពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យក្នុងព្រះរាជាណាចក្រ ។

ព.ស. ២៥០៥ គ.ស. ១៩៦១ រហូតមក **សម្តេច** ទ្រង់ប្រោសមេត្តាទទួលនិមន្តន៍ពីសមាគមអ្នកនិពន្ធខ្មែរ ធ្វើជាប្រធាននៃការសម្ភាសន៍អក្សរសាស្រ្ត ផ្សាយតាមសម្លេងវិទ្យុជាតិរាល់ថ្ងៃសុក្រ ។

គ.ស. ១៩៦៨ ទ្រង់បានទទួលព្រះឋានៈជាប្រធាននៃគណៈកម្មការពិនិត្យស្នាដៃអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្រ្តខ្មែរ ។

គ.ស. ១៩៦៩ ព្រះអង្គទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យនិងកំណត់អំពីន័យរបស់ទង់ជាតិខ្មែរ ។

# ព្រះរាជកិច្ច
# ដែលបានបំពេញក្នុងព្រះពុទ្ធសាសនា នៅបរទេស

នៅ ព.ស. ២៤៧៥ គ.ស. ១៩៣១ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូនៃមន្ត្រីសង្ឃទៅកាន់ក្រុងវៀងចន្ទន៍និងហ្លួងព្រះបាង ប្រទេសលាវ ដើម្បីរួបរួមក្នុងពិធីសម្ពោធពុទ្ធសាសនបណ្ឌិត្យប្រទេសលាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សាសម្រាប់សាលាបាលីរងនៅប្រទេសលាវផង ។

នៅ ព.ស. ២៤៧៧ គ.ស. ១៩៣៣ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូព្រះសង្ឃខ្មែរទៅធ្វើទស្សនាចរណ៍ចំពោះវត្តខ្មែរទាំងឡាយក្នុងដែនកូសាំងស៊ីន ប្រទេសយួនខាងត្បូង ។

នៅ ព.ស. ២៤៨៣ គ.ស. ១៩៣៩ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសលាវម្តងទៀត ដើម្បីប្រជុំប្រឹក្សាកិច្ចការនៃពុទ្ធសាសនបណ្ឌិត្យប្រទេសលាវ និងការសិក្សាសម្រាប់សាលាបាលីនៅប្រទេសលាវផងដើម្បីជួយរំលឹកដាស់តឿនប្រជាជាតិលាវនៅក្នុងទីប្រជុំជន ក្នុងខែត្រនានានៃព្រះរាជាណាចក្រលាវ ឲ្យខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការសិក្សា និងការប្រតិបត្តិឲ្យបានត្រឹមត្រង់តាមគន្លងព្រះពុទ្ធសាសនាផង ។

នៅ ព.ស. ២៤៨៧ គ.ស. ១៩៤៣ **សម្តេច** ទ្រង់បានទទួលជាសមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ហើយនៅ ព.ស. ២៤៩២ គ.ស. ១៩៤៨ **សម្តេច** ទ្រង់បានទទួលនាទីជាសមាជិកកិត្តិយស នៃសាលានេះដរាបរៀងមក ។

នៅ ព.ស. ២៤៩៤ គ.ស. ១៩៥០ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅប្រជុំសន្និសីទអន្តរជាតិ ដើម្បីបង្កើតពុទ្ធិកសមសគមពិភពលោក នៅក្រុងកោលម្បូលលង្កាទ្វីប ។

នៅ ព.ស. ២៤៩៧ គ.ស. ១៩៥៣ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅបំពេញបេសកកម្មសុឆន្ទៈ ប្រឹក្សាសំរេចរឿងធ្វើឆដ្ឋសង្គាយនា នៅក្រុងរង្គូន សហភាពភូមា ។

នៅ ព.ស. ២៤៩៨ គ.ស. ១៩៥៤ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅចូលរួបរួមប្រជុំធ្វើឆដ្ឋសង្គាយនាសម័យប្រជុំដំបូង នាក្រុងរង្គូនប្រទេសភូមាម្តងទៀត ។

នៅ ព.ស. ២៤៩៩ គ.ស. ១៩៥៥ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ទីធ្វើឆដ្ឋសង្គាយនា ក្រុងរង្គូនប្រទេសភូមាជាលើកទីបី ដើម្បីប្រជុំហើយបិទពេលប្រជុំប្រចាំឆ្នាំ ។

នៅ ព.ស. ២៥០៣ គ.ស. ១៩៥៩ **សម្តេច** ទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ក្រុងដេកតាំ និងក្រុងសីម៉ារ៉ាំងកោះជ្វា ប្រទេសឥណ្ឌូនេស៊ី ដើម្បីរួបរួមក្នុងពិធីបុណ្យវិសាខបូជា និងពិធីបញ្ចុះខណ្ឌសីមា ព្រមទាំងពិធីសន្ទត់រោងឧបោសថ និងជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្រអ្នកប្រទេសនោះចំនួន៣រូបផង ។

# សមណស័ក្តិ
# ដែលសម្តេចបានទទួល

ដោយព្រះមហាវិរិយភាពក្នុងកិច្ចការដ៏ធំៗ **សម្តេច** បានឡើងសមណស័ក្តិ ជាលំដាប់លំដោយដូចតទៅ ៖

ព.ស. ២៤៥៤ គ.ស. ១៩១០ ជាព្រះបាទ្បាត់សាក្យបុត្តិយ៍ ( បាឡាត់របស់ព្រះសាក្យវង្ស **នុត** វត្តឧណ្ណាលោម ) ។

ព.ស. ២៤៥៦ គ.ស. ១៩១២ **សម្តេច** បានទទួលសមណស័ក្តិជាព្រះគ្រូសង្ឃសត្ថា ( ទីឋានានុក្រមសម្រាប់ឯករបស់ **សម្តេច** ព្រះមហាសង្ឃរាជព្រះនាម **ទៀង** ) ។

ព.ស. ២៤៧៥ គ.ស. ១៩៣១ **សម្តេច** បានឡើងសមណស័ក្តិជា ព្រះសាសនសោភ័ណ ( រាជាគណៈកិត្តិយស ) ។

ព.ស. ២៤៨៤ គ.ស. ១៩៤០ **សម្តេច** បានឡើងសមណស័ក្តិជា ព្រះពុទ្ធឃោសាចារ្យ ( រាជាគណៈថ្នាក់ទោ ) ។

ព.ស. ២៤៨៨ គ.ស. ១៩៤៤ **សម្តេច** បានឡើងសមណស័ក្តិជា ព្រះពោធិវ័ង្ស ( រាជាគណៈថ្នាក់ឯក ) ។

ព.ស. ២៤៩២ គ.ស. ១៩៤៨ **សម្តេច** បានឡើងសមណស័ក្តិជាន់ខ្ពស់បំផុតជា ព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ។

ព.ស. ២៤៩៤ គ.ស. ១៩៥០ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់បានប្រោសព្រះរាជទានព្រះឋានៈជា **សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ** ។

មួយវិញទៀត រដ្ឋាភិបាលនៃសហភាពភូមា បានប្រគេនព្រះឋានៈ **សម្តេច** ជាព្រះអគ្គមហាបណ្ឌិតនៃសហភាពភូមានៅ ព.ស. ២៤៩៨ គ.ស. ១៩៥៤ ។

លុះមកដល់ ព.ស. ២៥០១ គ.ស. ១៩៥៧ រដ្ឋាភិបាលនៃសហភាពភូមាបានសុំតម្លើងព្រះឋានៈ **សម្តេច** ជាព្រះអភិធជមហារដ្ឋគុរុ នៃសហភាពភូមា ដែលជាសមណស័ក្តិដ៏ខ្ពង់ខ្ពស់បំផុតមានតែមួយអង្គក្នុងសហភាពភូមា ។

ក្នុងខែកុម្ភៈ គ.ស. ១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់បានថ្វាយឋានៈព្រះអង្គជា ព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ និងជាសមាជិកកិត្តិយសនៃសមាគមអ្នកនិពន្ធខ្មែរផង ។

ព.ស. ២៥០៧ គ.ស. ១៩៦៣ **សម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ** នៃប្រទេសកម្ពុជាទ្រង់បានប្រោសព្រះរាជទានប្រគេនព្រះឋានៈ **សម្តេច** ជា **សម្តេចព្រះសង្ឃរាជ ថ្នាក់ទី ១** ។

**សម្តេចព្រះសង្ឃរាជ** ជាម្ចាស់ទ្រង់បានទទួលសញ្ញាប័ត្រ បណ្ឌិតអក្សរសាស្ត្រពេញលក្ខណៈ ពី **សម្តេចព្រះប្រមុខរដ្ឋ** ក្នុងនាមនៃមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រនៃភូមិន្ទសាកលវិទ្យាល័យពីថ្ងៃទី ២៨ ឧសភា ១៩៦៧ ។

# គ្រឿងឥស្សរិយយស

**សម្តេច** បានទទួលគ្រឿងឥស្សរិយយសដូចតទៅ :

- មេដាយអស្សរិទ្ធិមុនីសារាភរណ៍នៅ ព.ស.២៤៦១ គ.ស. ១៩១៧ ;
- មេដាយអស្សរិទ្ធិព្រះរាជាណាចក្រកម្ពុជា ព.ស.២៤៧៦ គ.ស. ១៩៣២ ;
- មេដាយអស្សរិទ្ធិដំរីមួយលាន និងស្វេតច្ឆ័ត្រ ប្រទេសលាវ នៅ ព.ស.២៤៧៦ គ.ស. ១៩៣២ ;
- មេដាយសេនានៃបណ្ឌិតសភា សាធារណរដ្ឋបារាំង នៅ ព.ស.២៤៨១ គ.ស. ១៩៣៧ ;
- មេដាយអស្សរិទ្ធិ ដឺឡាឡេស្យុងដូណ្ណើរ នៃ សាធារណរដ្ឋបារាំង នៅ ព.ស.២៤៨៦ គ.ស.១៩៤២;
- មេដាយ សេនានៃព្រះរាជាណាចក្រកម្ពុជា ព.ស.២៤៨៨ គ.ស. ១៩៤៤ ;
- មេដាយ សេនា ដឺឡាឡេស្យុងដូណ្ណើរ នៃ សាធារណរដ្ឋបារាំង នៅ ព.ស.២៤៩២ គ.ស.១៩៤៨;
- មេដាយ មហាសិរីវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា ព.ស.២៥០៥ គ.ស. ១៩៦២ ;
- មេដាយ មហាសិរីវឌ្ឍន៍សុវត្ថារា ព.ស.២៥០៦ គ.ស. ១៩៦៣ ;
- មេដាយជាតូបការដែលជាគ្រឿងឥស្សរិយយសធំបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជានៅ ព.ស. ២៥១៣ គ.ស. ១៩៦៩ ;



# កិច្ចការជាស្នាព្រះហស្តនៃសម្តេច

កិច្ចការឯទៀតក្រៅពីមុខការខាងលើនេះ ដែលសុទ្ធសឹងតែជាការមានប្រយោជន៍ ជាសាធារណៈ ក្នុងព្រះពុទ្ធសាសនា និងប្រទេសជាតិនោះ នៅមានច្រើនជាអនេកនិយាយដោយសង្ខេបគឺចាប់តាំងពីឆ្នាំឆ្លូវ សប្តស័ក ព.ស.២៤៧០ គ.ស.១៩២៥ រៀងមក **សម្តេច** បានទ្រង់ធ្វើការឧបត្ថម វត្តពោធិព្រឹក្ស ( ហៅពោល្យំ ) ក្នុងសង្កាត់រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ជាប់គ្នានឹងសង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាទីជាតិភូមិរបស់ **សម្តេច** ដោយ **សម្តេច** បានជាវទីដីជុំវិញវត្តចំនួនជាងបីហិកតា ពង្រីកទីវត្តឲ្យបានធំទូលាយច្រើនជាងពីដើម ។

- បានជួយឧបត្ថម្ភលើកថ្នល់ភ្ជាប់ពីថ្នល់ជាតិមកចូលវត្តសុរភី និងវត្តពោធិព្រឹក្សរួមចម្ងាយ ៣ គីឡូម៉ែត្រព្រមទាំងបានឧបត្ថម្ភឲ្យថ្នល់លំនេះបានចាក់គ្រួសបាយគ្រៀមអាចឲ្យប្រើការដោយងាយស្រួលផង ;
- បានស្ថាបនាវិហារបេតុងអារម៉េ ពុទ្ធិកបឋមសិក្សានិងរៀបចំទីវត្តទាំងមូលឲ្យមានទេសភាពសមរម្យគួរជាទីរីករាយ ទៅតាមសម័យនិយម ;
- បានស្ថាបនាស្ពានធំ ១ តូច ១ សុទ្ធតែបេតុងអារម៉េ ឆ្លងស្ទឹងតូច រាំងព្រំប្រទល់សង្កាត់រកាកោះ និងសង្កាត់រលាំងកែន ;
- បានស្ថាបនាសាលាបឋមសិក្សាបំពេញវិជ្ជា ( សុរភី-ពោធិព្រឹក្ស ) ៣ ខ្នង តាំងពី គ.ស. ១៩៤៨ ហើយទ្រង់បានជួយឧបត្ថម្ភសាលានេះរហូតដល់ឡើងដល់ថ្នាក់ទី ៧ ទំនើបសម្រាប់ឲ្យកូនចៅអ្នកស្រុកចំណុះវត្តសុរភី និងវត្តពោធិព្រឹករៀនសូត្រ ;
- បានស្ថាបនាខ្លោងទ្វារបេតុងអារម៉េ, បានស្ថាបនាអាវសថសាលា ( សាលាសំណាក់ ) ២ ខ្នង ;
- បានឲ្យជីកស្រះ ១ ទំហំ ១០០ម៉ែត្រ ៤ ជ្រុង ;
- បានជួយឧបត្ថម្ភឲ្យជីកអណ្តូងយោង ១៦កន្លែង, អណ្តូងបុកប្រើស្នប់ ៣កន្លែង ;
- បានស្ថាបនាគិលានដ្ឋាន ១ខ្នង, ប្រសូត្រគ្រឹះ ( មន្ទីរសម្ភព ) ១ខ្នង ដោយបេតុងអារម៉េ និងកំពែងបេតុងអារម៉េបណ្តោយ ១០០ម៉ែត្រ ទទឹង ៥២ ម៉ែត្រ ព័ទ្ធជុំវិញមន្ទីរទាំងពីរខ្នងនេះ ;
- បានស្ថាបនាអាគារគព្ភិនីសំណាក់ ក្នុងកំពែងនេះដែរ ;
- បានស្ថាបនាអាគារបេតុងអារម៉េ ២ ខ្នង សម្រាប់គិលានសមណៈ នៅក្រៅកំពែងនោះ ;
- បានស្ថាបនាអាគារបេតុងអារម៉េប្រក់ស័ង្កសី ១ ខ្នង សម្រាប់ធ្វើពិធីបុណ្យផ្សេងៗ ;

- បានជាវទីដីចំនួន ៣ ហិកតាហើយទ្រង់សព្វព្រះហឫទ័យ លះបង់ទីដីដែលបានជាវហើយនេះ ជូនទៅព្រះរាជរដ្ឋាភិបាល ឲ្យស្ថាបនាអាគារមណ្ឌលនីតិកម្ម ( ប៉ុស្តិ៍ប៉ូលិស ) និងមន្ទីរាជសហករណ៍ ;

- បានចាត់ការឲ្យលើកទំនប់ទឹកមួយកន្លែង មានបណ្តោយ ៩០០ ម៉ែត្រ ទទឹង ៨០០ ម៉ែត្រ ;

- បានឲ្យវេយ្យាវច្ចករដាំដំណាំ នៅលើដីជិតអាស្រម មនោរម្យ ដើម្បីជាប្រយោជន៍ដល់គិលានដ្ឋាន និងប្រសូតិគ្រឹះ នៅក្នុងអនាគតកាល ។ល។

( ស្ថាបនកម្មទាំងនេះ នៅក្នុងភូមិស្រែបន្ទាយ សង្កាត់រកាកោះ )

# កិច្ចការជាស្នាព្រះហស្តខាងអក្សរសាស្ត្រ

**សម្តេច** បានកសាងគម្ពីរដីការជាច្រើន បានទាំងប្រែភាសាបាលី ហើយរៀបរៀងធ្វើជាសៀវភៅដែលកម្រនឹងធ្វើកើតដែលមានប្រយោជន៍ច្រើននោះគឺ ៖

- សាមណេរវិន័យក្នុង ព.ស. ២៤៦០ គ.ស. ១៩១៧ ;

- វចនានុក្រមខ្មែរ ភាគ១និងភាគ២ ព.ស. ២៤៦១ គ.ស. ១៩១៨ និងឆ្នាំតៗរៀងមក ;

- កច្ចាយនូបត្ថម្ភកៈ ( វេយ្យាករណ៍បាលី )មាន ២ ភាគ ចាប់ផ្តើមធ្វើនៅ ព.ស. ២៤៦២ ត្រូវនឹង គ.ស ១៩២០ ;

- គិហិបដិបត្តិក្នុង ព.ស. ២៤៦៨ គ.ស. ១៩២៦ ;

- បាតិមោក្ខសង្ខេប ( សម្រាយ ) ព.ស. ២៤៧០ គ.ស. ១៩២៨ មានសៀវភៅឯទៀតៗជាច្រើនដែលជាការបន្ទាប់បន្សំគឺ ៖

- នាគោបមាទិកថា ព.ស. ២៤៧៥ គ.ស. ១៩៣៣ ;

- សុភមង្គលគាថា បឋ្យាវត្ត ៧ គាថា ជាភាសាបាលីនិងប្រែ សម្រាប់សូត្រថ្វាយសុភមង្គលសិរីសួស្តីចំពោះព្រះករុណា **ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន** ក្នុងព.ស. ២៤៨៤ គ.ស. ១៩៤១ ;

- អត្ថបទផ្សេងៗជាច្រើនក្នុងទស្សនាវដ្តី " កម្ពុជសុរិយា " របស់ពុទ្ធសាសនបណ្ឌិត្យតាំងពីក្នុងឆ្នាំ ១៩២៦ ;

- កាព្យលោកធម៌ បោះពុម្ពដំបូងក្នុង ព.ស. ២៥០០ គ.ស. ១៩៥៧ ;

- បព្វជ្ជូបសម្បទា ព.ស. ២៥០០ គ.ស. ១៩៥៧ ;

- អត្ថបទផ្សេងៗក្នុងទស្សនាវដ្តី ពន្លឺពុទ្ធចក្ររបស់ពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជរដ្ឋ ;

ជាពិសេស ស្នាព្រះហស្តដែលរំលឹកឃើញរាល់ថ្ងៃ គឺព្រះរាជនិពន្ធបទនគររាជសម្រាប់ភ្លេងជាតិខ្មែរ ព្រះរាជនិពន្ធពីថ្ងៃទី ២០ ខែកក្កដា ១៩៤១ និងបទសរភញ្ញ ដែលទ្រង់បាននិពន្ធក្នុងឱកាសបុណ្យពុទ្ធសករាជ ២៥០០ ។

# អវសានកាល

នៅពេលរសៀលនៃថ្ងៃអង្គារ ១២ កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៣ កញ្ញា ១៩៦៩ វេលាម៉ោង ១៥និង៤៥ នាទី **សម្តេច** ទ្រង់ព្រះប្រឈួនក្រោយពេលដែលគ្រូពេទ្យទាំងឡាយ បានចូលមកព្យាបាល ឃើញថាព្រះអាការរោគមិនជាធ្ងន់ប៉ុន្មាន ប៉ុន្តែក្រសួងសុខាភិបាលក៏បានចាត់គ្រូពេទ្យឲ្យមករក្សាព្រះអាការរោគ និងប្រកបឱសថថ្វាយជាដរាប, រហូតដល់ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង២០ នាទីព្រះអស្សាសប្បស្សាសៈនៃព្រះអង្គ បានចាកចេញពីព្រះកាយ ទ្រង់សោយទិវង្គតដោយស្ងប់ស្ងៀមនៅដំណាក់ព្រះអង្គនា វត្តឧណ្ណាលោម ។

ក្នុងរយៈកាលដែល **សម្តេច** ទ្រង់ព្រះប្រឈួននេះ ឯកឧត្តម **អ៊ឹង ហុងសាធ** តាមព្រះរាជបញ្ជានៃ **សម្តេចព្រះប្រមុខរដ្ឋ** បានចាត់អស់លោកវេជ្ជបណ្ឌិតខ្មែរ បារាំងដ៏ជំនាញៗទាំងឡាយឲ្យខ្វល់ខ្វាយព្យាបាលព្រះអាការរោគព្រះអង្គយ៉ាងពេញសមត្ថភាព ប៉ុន្តែធ្វើម្តេចឡើយនឹងយកជ័យជំនះលើស្តេចមច្ចុបាន ។

**សម្តេច** ព្រះសង្ឃរាជជាអម្ចាស់ ទ្រង់បានដឹងព្រះអង្គជាមុនចាប់តាំងពីថ្ងៃព្រះប្រឈួន ទ្រង់មានព្រះបន្ទូលប្រាប់ព្រះសង្ឃនិងអស់លោកដែលមកថ្វាយបង្គំសាកសួរព្រះសុខភាពថា៖ ខ្ញុំកូណា អាត្មាហាក់ដូចជាគ្មានសង្ឃឹមទេ... ព្រះរាជបន្ទូលនេះធ្វើឲ្យយើងរាល់គ្នាមានសេចក្តីរន្ធត់តក់ស្លុតពន់ពេក ប៉ុន្តែយើងរាល់គ្នានៅតែជឿជាក់ថា ព្រះអង្គនឹងនៅគង់ព្រះជន្មាយុតទៅទៀត ព្រោះបានសង្កេតឃើញព្រះសិរីរាការៈរបស់ព្រះអង្គពុំមានប្រែប្រួលអ្វីប៉ុន្មាន ទ្រង់មានព្រះស្មារតីរឹងប៉ឹងល្អណាស់អាចមានព្រះបន្ទូលសាសងសំណេះសំណាលជាហូរហែអំពីសិង្គុតរចេតិយ និងអំពីការបោះពុម្ពវចនានុក្រមខ្មែរ ដែលព្រះអង្គបានខិតខំកែសម្រួលបន្ថែមពាក្យជាច្រើនទៀត ជាមួយនិងអស់លោកដែលមកក្រាបបង្គំគាល់សាកសួរព្រះសុខភាពរបស់ព្រះអង្គ មិនគួរឡើយប្រែប្រួលទៅជាសោយទិវង្គតសោះ ។

យើងរាល់គ្នាមានសេចក្តីសោកស្តាយអាឡោះអាល័យនឹងរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ។

ភ្នំពេញ, ថ្ងៃទី ៧ វិច្ឆិកា ព.ស. ២៥១៣ ត្រូវនឹង គ.ស. ១៩៦៩

**នខ លន់**

លេខាធិការនៃពុទ្ធិកសមាគម **កម្ពុជរដ្ឋ**

# គុណសោកកថា

## បទកាកគតិ

យើងខ្ញុំបង្គំ ក្រួញក្រាបប្រណម្យ ក្រោមព្រះបាទា
នៃអង្គសម្តេច ព្រះសង្ឃរាជា អគ្គមេធា
មហាវីរៈ ។
កំពូលអ្នកប្រាជ្ញ ព្រះទ័យអង់អាច វាងវៃប្រត្យក្ស
ទាំងអក្សរសាស្ត្រ ទាំងពុទ្ធចក្រ ទ្រង់ជាឯកអគ្គ[១]
អ្នកបដិវត្ត ។
រៀបរៀងធម៌អាថ៌ វិន័យសិក្ខា ដែលមានភ្លាំងភ្លាត់
ឲ្យបានត្រឹមត្រូវ ត្រង់ដូចបន្ទាត់ ព្រះសង្ឃរាល់វត្ត
ប្រតិបត្តិសិក្សា ។
អក្សរសាស្ត្រជាតិ ព្រះអង្គខ្មីឃ្មាត សង្ខាតរចនា
សើរើរៀបរៀង ផ្ទៀងផ្ទាត់ភាសា ឲ្យមានលក្ខណា
ថ្លៃថ្លាពិសី ។
ទោះមានឧបសគ្គ ពើបពះគ្រោះថ្នាក់ បង្អាក់ម្តេចក្តី
ព្រះអង្គឥតរា ពុះពារឃ្មាតខ្មី ប្រយោជន៍ដើម្បី
សិរីខេមរា ។
ប្រកបព្រះគុណ គុណគាប់មហាធ្ងន់ ធ្ងន់ឥតឧបមា
ទាំងផែនការជាតិ ទាំងផ្នែកសាសនា ទ្រង់ព្រះឧស្សាហ៍
ពុំមានរសាយ ។
ទោះទ្រង់ជរា តែត្រង់ការងារ ពុំមានជិនណាយ
ឥតទ្រង់តម្រិះ ដល់ព្រះអង្គកាយ ព្រះទ័យខ្វល់ខ្វាយ
និងជាតិសាសនា ។

---

(១) អានថា ឯកអាក់ ។

កិច្ចការឧត្តម ដែលទ្រង់ខិតខំ ប្រើព្រះប្រាជ្ញា
បំពេញទុកឲ្យ អ្នកក្រោយសិក្សា មានច្រើនប្រការ
ហួសនឹងអធិប្បាយ ។

ព្រះទ័យមេត្តា អាសូរករុណា មនុស្សសត្វទាំងឡាយ
ស្មោះស្មើទូទៅ ទោះនៅជិតឆ្ងាយ គ្រប់ក្រុមនិកាយ
ស្រស់ស្រាយរាក់ទាក់ ។

ឥឡូវព្រះអង្គ ប្រសើរសីលទ្រង់ ឯកអង្គអគ្គៈ
ទ្រង់ទិវង្គត រលត់ជន្មជាក់ ខានយល់ព្រះភក្ត្រ
ព្រះអង្គទៀតហើយ ។

ពីថ្ងៃនេះទៅ យើងខ្ញុំរស់នៅ សោកសៅឥតស្បើយ
អាទ្បោះអាល័យ ម្ចាស់ថ្លៃខ្ញុំអើយ (១) ពីនេះទៅហើយ
ខានយល់ភក្ត្រា ។

ខានត្រងខានត្រាប់ ខានឮខានស្តាប់ ព្រះរាជឱង្ការ
ឮតែសូរសៀង ស័ព្ទព្រះវាចា តាមឃោសនាការ
ពីអក្សរសាស្ត្រ ។

ដែលទ្រង់បរិយាយ ពន្យល់ដោះស្រាយ ដោយក្តីវៃឆ្លាស
វែកញែកហេតុផល ផ្តល់នៃប្រកាស ដោយព្រះតម្រាស់
ជាក់ច្បាស់ក្បោះក្បាយ ។

ព្រះកាយបាត់ទៅ ព្រះកេរ្តិ៍គង់នៅ ឲ្យយើងទាំងឡាយ
រៀនសូត្រសិក្សារ ភ្លឺថ្លាពណ្ណរាយ នឹកឡើងសែនស្តាយ
ស្តាយឥតឧបមា ។

ឱអម្ចាស់ថ្លៃ យើងខ្ញុំអាល័យ អាទ្បោះសោកា
រន្ធត់តក់ស្លុត ស្រយុតចិន្តា ក្តួលក្តៅខ្លោចផ្សា
ពុំមានស្រាកស្រាន ។

---

(១) អានថា ខ្ញុំម៉ើយ ។

អ្នកនិពន្ធ ព្រឹទ្ធបាលឯក **ខា ម៉ូរ**
ការិយាល័យទី ៥ នៃ អ .ស .យ .ខ .ក .

# សមាសភាពចូលរួម

១. លោក **វ៉ាត សុគន្ធ** ( Sokun Vat)

២. លោក **វ៉ាត តារា** ( **ធីធី** ) ( Tara Vat)

៣. លោក **វ៉ាតម៉ូលីវណ្ណា** ( Molywan Vat)

៤. លោក **ប៊ុនច័ន្ទ ស្ទីវិន** ( Steven Bunchan )

៥. កញ្ញា **វ៉ាត វារីយ៉ា** (Vearya Vat)



# នាមសប្បុរសជន
## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យ
## ដើម្បីបោះពុម្ពសៀវភៅជាធម្មទាន ៖

. ព្រះភិក្ខុ **ធឹង ធីម** ( **ចន្ទគ្គេរ** ) ចៅអធិការវត្ត **ធម្មិការាម**
. ព្រះភិក្ខុ **ហ៊ុន ឃួយ** វត្ត **ធម្មិការាម**
. ព្រះភិក្ខុ **ប៉ាវ សែន** វត្ត **ពុទ្ធស្ថានខ្មែរម៉ុងរេអាល** Anjou
. លោក **កែវ សម៉នឈាង**
. ពុទ្ធបរិស័ទ **វង្ស តក្របូរីយ៍**
. លោកយាយ **ចាន ផាន់**
. លោកយាយ **ដាន យុតហ្វ**
. លោកយាយ **ភូ ស៊ីវលន់**
. លោកតា **ម៉ុញ មឿន**
. លោកយាយ **ស៊ុត គិមមាន**
. លោកយាយ **នូ លឹម**
. ឧបាសិកា **ឡុត យឿម**
. ឧបាសក **ប៉ែន សារឿន** និងឧបាសិកា **ឡាំ ឈួម**
. ឧបាសក **ម៉ុញ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា**
. ឧបាសិកា **ម៉ៅ វេង**
. ឧបាសក **ផាន សុផុន** និងឧបាសិកា **ឈឿង យ៉ាវ**
. លោក **ផាន សុផៃរតនៈ**
. លោកស្រី **ផាន ម៉ារីសុរិយា**
. ឧបាសក **អ៊ូ សុផុន** និងឧបាសិកា **អ៊ូ សុខន**

. ឧបាសក **ហ៊ុន ហេង** និងឧបាសិកា **ឆាង រ៉ែម**

. ឧបាសិកា **អោយ យាន** ព្រមទាំងកូនចៅ

. ឧបាសិកា **អ៊ុន យូឡេង**

. អ្នកស្រី **អ៊ុន យូសេង**

. ឧបាសក **ខាំផាន់ ម៉ាលីថៃ** និងឧបាសិកា **ម៉ា ថងអន**

. ឧបាសិកា **ទេព ឆុង**

. ឧបាសិកា **អ៊ាច គិមជា**

. ឧបាសិកា **ស៊ុយ ជាមួយ**

. ឧបាសិកា **អ៊ុង ឆាយហ៊ុន**

. ឧបាសិកា **តែ ឆឹងអ៊ុ**

. ឧបាសក **អ៊ឹម កុសល** និងឧបាសិកា **តែ ឆឹងលាភ**

. យុវជន **អ៊ឹម ច័ន្ទតារា**

. ឧបាសក **ខាយ ប៊ុនគីម** និងឧបាសិកា **ស សុខឆេង**

. ឧបាសក **ម៉ម លន់** និងឧបាសិកា **ថ្លែង ធឿន**

. ឧបាសក **អ៊ឹម សាម៉ៃ** និងឧបាសិកា **ភូច ធឿន**

. ឧបាសក **ផល់ ផាន់** និងឧបាសិកា **យូ ហ៊ី**

. ឧបាសិកា **ជា នាង**

. ឧបាសិកា **ជា ស្រីយុទ្ធថូ**

. អ្នកស្រី **ម៉ៀច ស៊ីថុល**

. ឧបាសក **ហ៊ុន លឹមហ៊ាង**

. លោក **សិម សារឿន** និងអ្នកស្រី **ចាន់ ដារី**

. លោក **ពេជ្រ សារឿម** និងអ្នកស្រី **សិម ចាន់ដារ៉ា**

. លោក **សិម សទ្ធា** និងអ្នកស្រី **ពេជ្រ រីលីន**

. យុវជន **សិម រតនា**

. លោក **តាយ យ៉ន** និងអ្នកស្រី **សិម ចាន់នី**

. លោក **ឃឹត សុណាត** និងអ្នកស្រី **ហ៊ុន ម៉ារ៉ានី**

. ឧបាសិកា **ថ្លាង ធុច**

. លោក **កែវ ប៊ុនហាន** និងអ្នកស្រី **លី ឆេងលន់**

. លោក **ម៉ម ជីវ័ត្ត** និងអ្នកស្រី **រស់ ឧត្តី**

. លោក **សិម វី** និងអ្នកស្រី **សិម ចិន្តា**

. លោក **ខៃ ឃុនហៃ** និងអ្នកស្រី **សិម ចាន់ធូរ៉ាណា**

. យុវជន **សិម រីឆា**

. លោក **សិម សុមេរ៉ា**

. អ្នកស្រី **ជា ពិសី**

. កុមារា **សិម ប៊ីលី**

. កុមារា **សិម លីណូ**

. អ្នកស្រី **សិម ទេវី**

. អ្នកស្រី **ស៊ុំ យ៉ាង**

. អ្នកស្រី **ណាវ វ៉ាន់នី**

. លោក **ជួប បុរីវុទ្ធ** និងអ្នកស្រី **សួស ចាន់សីម៉ា**

. លោក **មួង សុធា** និងអ្នកស្រី **ច៉ែត ផាន់នី**

. អ្នកស្រី **តាយ តិរម្យ**

. យុវនារី **តាយ តាវី**

. លោក **លី វីមុត** និងអ្នកស្រី **សិម ចាន់ណារី**

. លោក **សួស ប៉ុណ្ណាវុធ** និងអ្នកស្រី **សិម វិច្ឆិកា**

. កុមារា **សិម ឡេអូ**

. កុមារា **សិម ប៊ីលីយ៉ាម**

. លោក **ចៅ សុខ** និងអ្នកស្រី **ឈឹម សុនី**

. លោក **ទូច សាន** និងអ្នកស្រី **ស៊ុយ សាម៉ុន**

. លោក **នុន ស្បែ** និងអ្នកស្រី **នុន ណាន់ថា**

. លោក **លី សាម៉ន** និងអ្នកស្រី **ញឹក ស្រីភាព**

. លោក **អ៊ួន ហ៊ាង** និងអ្នកស្រី **វ៉ែន យិម**

. លោក **លី គាង** និងអ្នកស្រី **អ៊ុក គិមហ៊ាង**

. លោក **នូ ស៊ីយឿន** និងអ្នកស្រី **លី សុភី**

. លោក **តិច នូភាន** និងអ្នកស្រី **សេម ស៊ីភាឆូក**

. លោក **អៀម រឿន** និងអ្នកស្រី **ភី រិម**

. អ្នកស្រី **ផាត់ សាវឡា**

. លោក **ផាត់ សុភឡិត** និងអ្នកស្រី **ឆៃ សុតិន**

. លោក **សក្តិ ផល្លា** និងអ្នកស្រី **ចាន់ សុម៉ាលី**

. យុវជន **ផល្លា ពិសិដ្ឋ**

. លោក **យន់ សាវុធ** និងអ្នកស្រី **ណាម នី**

. អ្នកស្រី **ហ៊ុន ហ៊ាង**

. លោក **ពិន ឃឹមខុន** និងអ្នកស្រី **ប្រែង ហូវ**

. លោក **ហេង ចាន់ថា** និងអ្នកស្រី **អ៊ុំ គឿន**

. លោក **ឃុំ ម៉ែន**

. អ្នកស្រី **គ្លឹម ហ៊ុត**

. លោក **ឃុំ មាន** និងអ្នកស្រី **សួន ស៊ីសុវណ្ណា**

. លោក **ខួន សុវណ្ណា** និងអ្នកស្រី **ឃុំ ហៃម**

. លោក **ហួត គិមគាវ** និងអ្នកស្រី **តិច ស៊ីនួន**

. លោក **ឌិប ច័ន្ទា** និងអ្នកស្រី **លៀម សុភាព**

. លោក **សេក សារុន**
. លោក **នូ សារឿន**
. លោក **ជួន កែវ** និងអ្នកស្រី **ហាច់ សំអឿន**
. លោក **អែម ណារី** និងអ្នកស្រី **អាត សំណាង**
. លោក **អ៊ុំ ហំ** និងអ្នកស្រី **ឌិម ណារី**
. លោក **ជី ស៊ុនហេង** និងអ្នកស្រី **អាង ពៅ**
. លោក **ជិន ចាន់ដារ៉ា** និងអ្នកស្រី **សេង វ៉ាន់នី**
. លោក **ខួន សារុន** និងអ្នកស្រី **ហ្វូ ចាន់ណា**
. លោក **ឌិម សៀប** និងអ្នកស្រី **អ៊ុម វ៉ាន**
. អ្នកស្រី **ខួច ជីវសេង**
. អ្នកស្រី **លិម មួយគិច**
. អ្នកស្រី **ហាន គិម**
. លោក **គិម ដេត**
. អ្នកស្រី **គិម ហាន**
. យុវជន **ប្រាក់ ចាន់តារ៉ា**
. យុវនារី **ប្រាក់ ចាន់ដារី**
. អ្នកស្រី **វ៉ាន់ ហាន**
. អ្នកស្រី **គិន សា**
. លោក **គិន ណាង**
. លោក **កង កុសល**
. អ្នកស្រី **មួយ**
. លោក **ម៉ុញ វ៉ាន់ថា** និងអ្នកស្រី **ជីវ សុផាន់នី**
. លោក **ទីន រតនៈ** និងអ្នកស្រី **កេង សោភា**
. លោក **វ៉ាត តិរត្ន** និងអ្នកស្រី **មៀច វណ្ណា**
. លោក **វ៉ាត តារា** (**ឌីឌី**)

. លោក **ម៉ាត ម៉ូលីវណ្ណា**
. កញ្ញា **ម៉ាត វារីយ៉ា**
. លោក **ម៉ាត សុគន្ធ**
. លោក **ថាំង សុធា**
. អ្នកស្រី **សូហ្វី**
. លោក **ឱក សុវៀត** និងអ្នកស្រី **ទេព វណ្ណា**
. លោក **មាស ឧត្តរោ** និងអ្នកស្រី **ជិន ចន្ថា**
. លោក **អ៊ុក ចាប** និងអ្នកស្រី **ហ៊ុន ផលវ័ន្ត**
. លោក **ថាវរី**
. លោក **ត្វូ ម៉េងហុង** និងអ្នកស្រី **ឱក គិមហ៊ាង**
. យុវជន **ត្វូ គិតឡាយ**
. យុវជន **ត្វូ គិតលី**
. យុវជន **ត្វូ គិតអាឡិចសង់ឌ្រឹះ**
. កញ្ញា **ត្វូ សុនដារីស**
. លោក **ចៅ ម៉ាន់**
. អ្នកស្រី **គុយ ឃួង**
. យុវជន **វាលសុន សខាយ**
. កញ្ញា **ផល់ សុខឌី**
. លោក **ជីវ សុខាល័យ** និងអ្នកស្រី **លៀម ស៊ីណាត**
. លោក **ថង ប៉ៃ** និងអ្នកស្រី **សាលួន ស៊ីសុវណ្ណា**
. លោក **យូ ផាន្នៀន** និងអ្នកស្រី **សិម លក្ខិណា**
. អ្នកស្រី **យឹម ច័ន្ទឌី**
. លោក **ស្ងួន ច័ន្ទវេហា**
. លោក **ប៊ុនច័ន្ទ ប្រែវដេរីក**
. លោក **ប៊ុនច័ន្ទ ស្ទីវិន**
. លោក **តិប វិបុល** និងអ្នកស្រី **ស៊ុំ សោភ័ណ្ឌា**

. លោក **ខ្វាន់ ប៊ុណ្ណា**

. លោក **ឡាំ ស៊្លីស** និងអ្នកស្រី **តិប សិរីសោភា**

. លោក **ទេង ណាំ** និងអ្នកស្រី **សក់ សាន់នី**

. លោក **ផាន ប៊ិត** និងអ្នកស្រី **លឹម ហួច**

. លោក **អ៊ុច ខ្ជួនវិសាល**

. លោក **អ៊ុច ខ្ជួនវិចត័រ**

. លោក **ឈឿង ឆាត** និងអ្នកស្រី **ផាន ដានី**

. ឧបាសក **ម៉ៅ សាន់** និងឧបាសិកា **មៀន ឈុំ**

. អ្នកស្រី **ឡាង ទេត**

. ឧបាសិកា **គង់ ញ៉ៅ**

. អ្នកស្រី **ជុំ រ៉ានី**

. ឧបាសក **គង់ យុទ្ធ** និងឧបាសិកា **តោ បៀន**

. លោក **ចឹម រឹមរ៉ុម** និងអ្នកស្រី **ឱក ចន្ទក្រិស្នា**

. កញ្ញា **ចឹម ពុទ្ធារុណ៍រខៀ**

. កញ្ញា **ចឹម ពិទុរ្យភិត្យា**

. លោក **លិម ប៉ាង** និងអ្នកស្រី **លឿង ទូច**

. លោក **ប្រាង សន** និងអ្នកស្រី **ខួន សុធីណា**

. ឧបាសិកា **ត្រឹង រ៉ែន**

. ឧបាសក **ឡាវ លាងថេង**

. ឧបាសិកា **ចំណាន**

. ឧបាសិកា Son Josie

. លោក **តាន់ ប៊ុនតិក** និងអ្នកស្រី **តាន់ ថានី**

. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សុភ័ណ**

. ឧបាសក **អៀត ហ៊ុត**

. លោក **ប៉េង គ្រី** និងអ្នកស្រី **ប៊ុនលី**

. ឧបាសិកា **អ៊ឹង គង់មន្ថា**
. ឧបាសិកា **ណោតសារុន**
. លោក **អ៊ុច ខ៊ុក** និងអ្នកស្រី **អាត់ រ៉ុម**
. លោក **លឹម ឆេងហ៊ន** និងអ្នកស្រី **ឈឿង សុខចេង**
. កញ្ញា **ហ៊ី ស៊ីលវី**
. កុមារា **ហ៊ី ហាក់សៀន**
. លោក **ស៊ុទ្ធ សារ៉ាក់** និងអ្នកស្រី **ឱត រ៉ុង**
. លោក **គី គីឡាំ** និងអ្នកស្រី **តាន់ វ៉ាន់នី**
. ឧបាសិកា **នី ហៀងឡាញ់**
. លោក **ភក់ គន** និងអ្នកស្រី **ប្រាង ប្រង**
. ឧបាសក **ម៉ែន សារ៉ាវៃ** និងឧបាសិកា **អ៊ុំម គឹមរ៉ុង**
. លោក **ឆោ មីនា** និងអ្នកស្រី **យិន ហ៊ួច**
. លោក **គី វណ្ណាធី** និងអ្នកស្រី **ជា ស៊ីវគាង**
. លោក **លឹម អាំងគី** និងអ្នកស្រី **ស សារឿន**
. ឧបាសក **ឈឹក ឈុំ**
. លោក **ម៉ី រុណ** និងអ្នកស្រី **ឈឿប ឡាពីន**
. លោក **អ៊ឹង ហុកខេង** និងអ្នកស្រី **តែ អួន**
. អ្នកស្រី **តុង ទីបេ**
. អ្នកស្រី **ប៉ុនធី លក្ខិណា**
. ឧបាសិកា **ឱក ស៊ុម** ព្រមទាំងគ្រួសារ
. លោក **ទិត្យ សំបូរ** និងភរិយា
. លោក **គិម សាក់ត្វាន** ព្រមទាំងគ្រួសារ
. លោក **អ៊ីវ ប៉ូលីប** និងអ្នកស្រី **ទេព ច័ន្ទសុថារី**
. ឧបាសិកា **ទី ភាយ៉ាន**
. ឧបាសិកា **សេង សុធានី**

. អ្នកស្រី **ជួម ស៊ីមន**

. អ្នកស្រី **ជួន តូសាលី**

. អ្នកស្រី **គួច ឡៀង**

. អ្នកស្រី **ហ៊ីង យូណា**

. អ្នកស្រី **ថុន**

. អ្នកស្រី **យូហ៊ួយ**

. ឧបាសិកា **ប្រាក់ គីម**

. លោក **ប៉ា ធី** និងអ្នកស្រី **យូ គាង**

. លោក **ជា សារឿន** និងអ្នកស្រី

. ឧបាសិកា **គីម មួយហៀង**

. លោក **ម៉ៅ សុខត្តិ**

. កញ្ញា **លីដែន**

. អ្នកស្រី **ងួន ពៅ**

. លោក **លឹម ពេជ្រ**

. ឧបាសិកា **ឡុង ខឹម**

. ឧបាសិកា **នង ប៉ោគីម**

. ឧបាសិកា **ទូច**

. អ្នកស្រី **សក់ សូនី**

. លោកយាយ **កែច ហៀក**

. ឧបាសិកា **ហេង គីមនី**

. អ្នកស្រី **ភឿង សុខ**

. លោក **សៀ ពាក**

. កុមារា **ឆែម រតមនី**

. កុមារា **ឆែម សាមនក្ខជ**

. អ្នកស្រី **ទូច នី**

. លោក **យឹម សុខហេង**

. អ្នកស្រី **ម៉ែន សារឿន**
. អ្នកស្រី **ម៉ែន តាំងអ៊ី**
. អ្នកស្រី **ជឹង គឹមស៊ាង**
. អ្នកស្រី **មិន ម៉ូរ៉ាត់**
. កញ្ញា **រចនា**
. អ្នកស្រី **លឿង ទូច**
. អ្នកស្រី **គឹម ដានី**
. អ្នកស្រី **សក់ សាលី**
. កញ្ញា **ដាវីន**
. អ្នកស្រី **សាក់ សារឿន**
. លោក Than Trong Thang
. អ្នកស្រី **សាយ ថាវី**
. កុមារា **ថាន់ រតនៈរស្មី**
. កុមារា **ថាន់ រតនៈគ្រីស្តូហ្វ៊ីរ**
. កុមារី **ថាន់ វិចតូរីយ៉ា អារូននី**
. លោក **ប៉ែន សារួម** និងអ្នកស្រី **អូន រ៉ាន់**
. ឧបាសិកា **ប៉ែន អ៊ុន**
. ឧបាសិកា **ប៉ែន អើន**
. លោក **គឹម ខៀកជី** និងអ្នកស្រី **ប៉ែន អួច** ហៅ **ពៅ**
. អ្នកស្រី **ហេង សុភាព**

* សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅនេះ
បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ
និង បានខួបនិស្ស័យរួចផុតចាកទុក្ខទាំងពួង
កុំបីឃ្លៀងឃ្លាតឡើយ !

**សូមអនុមោទនា** !!!

# សុខោ បុញ្ញស្ស ឧច្ចយោ

" ការសន្សំបុណ្យ រមែងនាំមកនូវសេចក្តីសុខ "

| | |
|---|---|
| កាន់សីលមានសីលជាទីពឹង | ពំនឹងថាជាមិត្រមេត្រី |
| ប្រសើរជាងមិត្រនាលោកីយ៍ | សីលចេះតែថ្មីឥតចេះចាស់ ។ |
| កាលពីព្រេងនាយសីលក៏ថ្មី | ឥឡូវនេះក្តីនៅជាក់ច្បាស់ |
| ព្រោះសីលបរិសុទ្ធប្រសើរណាស់ | ឥតចាស់ទេនៅថ្មីសន្លាង ។ |
| ព្រះពុទ្ធត្រាស់ថាក្រៅពីសីល | មានចាស់ឃើរិលព្រោះរូបរាង |
| តែងតែគ្រាំគ្រាឥតគ្រឿងអាង | មិនថ្មីសន្លាងដូចសីលឡើយ ។ |
| កុំពោលថាសីលមានថ្មីចាស់ | ពោលនោះខុសណាស់ពេកទៅហើយ |
| បើសីលមានចាស់មែនម្តេចឡើយ | យើងកាន់ក្រោយគេនឹងបានបុណ្យ ?.. |

**ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ វ៉ាត និរក្ស**



**សំរាប់ជាធម្មទាន**